BIC Bank

របាយការណ៍ ប្រចាំឆ្នាំ2023

អនាគតហិរញ្ញប្បទានតំបន់អាស៊ី

តារាងមាតិកា

1. សារពីប្រធានក្រុមប្រឹក្សាភិបាល

2. សារពីអគ្គនាយក

3. ទស្សនវិស័យសេដ្ឋកិច្ចកម្ពុជា និងទិដ្ឋភាពទូទៅនៃវិស័យធនាគារ

4. ព័ត៌មានអំពីធនាគារ
   - 4.1 បេសកកម្ម ចក្ខុវិស័យ គុណតម្លៃ

5. រចនាសម្ព័ន្ធ
   - 5.1 រចនាសម្ព័ន្ធនៃធនាគារ
   - 5.2 ក្រុមប្រឹក្សាភិបាល
   - 5.3 គណៈគ្រប់គ្រង
   - 5.4 ការអភិវឌ្ឍន៍ធនធានមនុស្ស

6. ការរីកចម្រើន និងសមិទ្ធិផល
   - 6.1 ព័ត៌មានហិរញ្ញវត្ថុសង្ខេប
   - 6.2 សកម្មភាពអាជីវកម្ម
   - 6.3 សកម្មភាពផ្នែកទីផ្សារ និងទំនាក់ទំនងសាធារណៈ
   - 6.4 សមិទ្ធិផលសំខាន់ៗ

7. អភិបាលកិច្ចសាជីវកម្ម

8. របាយការណ៍ហិរញ្ញវត្ថុ
   - 8.1 របាយការណ៍របស់ក្រុមប្រឹក្សាភិបាល
   - 8.2 របាយការណ៍របស់សវនករឯករាជ្យ
   - 8.3 របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
   - 8.4 របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ
   - 8.5 បាយការណ៍ស្តីពីបម្រែបម្រួលមូលធន
   - 8.6 របាយការណ៍លំហូរសាច់ប្រាក់
   - 8.7 កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ

1 សារពីប្រធានក្រុមប្រឹក្សាភិបាល

ឆ្នាំ 2023 គឺជាឆ្នាំនៃភាពមិនប្រាកដប្រជាផ្នែកសេដ្ឋកិច្ច ជាមួយនឹងបរិយាកាសនៃអត្រាការប្រាក់ដែលបន្តកើនឡើង ប៉ុន្តែធនាគារ ប៊ីអាយស៊ី នៅតែបន្តយកឈ្នះបញ្ហាប្រឈមជាច្រើននៅក្នុងឧស្សាហកម្ម។ វាបានទូទាត់យ៉ាងល្អ ព្រោះយើងបានគ្រប់គ្រងដើម្បីរក្សាប្រតិបត្តិការដ៏រឹងមាំ និងអនុវត្តយ៉ាងមុតមាំបើធៀបទៅនឹងដៃគូក្នុងឧស្សាហកម្មតាមរយៈវិធីសាស្ត្រទប់ទល់នឹងហានិភ័យដែលមានកម្រិតទាប។

នៅទូទាំងពិភពលោក អតិផរណាបានធ្លាក់ចុះបន្តិចបន្ទាប់ពីឡើងដល់កម្រិតខ្ពស់រយៈពេល 40 ឆ្នាំនៅសហរដ្ឋអាមេរិក ប៉ុន្តែភាពតានតឹងនៅមជ្ឈិមបូព៌ា និងរុស្ស៊ី - អ៊ុយក្រែនបានធ្វើឱ្យតម្លៃទំនិញមួយចំនួនឡើងខ្ពស់ដែលបណ្តាលឱ្យធនាគារកណ្តាលរឹតបន្តឹងគោលនយោបាយរូបិយវត្ថុរបស់ពួកគេ។ ភាពតានតឹងរវាងចិន និងសហរដ្ឋអាមេរិកក៏នៅតែមានកម្រិតខ្ពស់នៅឡើយ ប៉ុន្តែកំណើនរបស់កម្ពុជានៅតែបន្តមានភាពវិជ្ជមាននៅចុងឆ្នាំ 2022 ក្នុងអត្រាកំណើន 5%។

យើងជឿជាក់ថា ឆ្នាំ 2024 នឹងក្លាយជាឆ្នាំនៃកំណើនសេដ្ឋកិច្ច ដោយសារវិស័យទេសចរណ៍កើនឡើង ហើយកម្ពុជានៅតែបន្តបង្កើតភាពជាដៃគូអាជីវកម្មជាមួយក្រុមហ៊ុនអន្តរជាតិដែលបង្កើតប្រតិបត្តិការនៅក្នុងតំបន់ និងក្នុងស្រុក។ វិស័យអចលនទ្រព្យ សំណង់ និងឧស្សាហកម្មវាយនភណ្ឌនៅតែប្រឈមមុខនឹងបញ្ហាសំខាន់ៗ ដែលជម្រុញដោយកាតព្វកិច្ចបំណុលកើនឡើងខ្ពស់ ក៏ដូចជាការធ្លាក់ចុះនៃតម្រូវការខាងក្រៅពីសហភាពអឺរ៉ុប និងសហរដ្ឋអាមេរិក។

យោងតាមរបាយការណ៍ចេញដោយធនាគារជាតិនៃកម្ពុជាឆ្នាំ 2023 វិស័យទេសចរណ៍បានស្ទុះងើបឡើងវិញដល់ 82.5% ដែលពុំធ្លាប់មានក្នុងប្រវត្តិសាស្ត្រ។ វិស័យកសិកម្មមានអត្រាកំណើនទាប។ ប្រទេសកម្ពុជាមានឱនភាពតិចតួចត្រឹម 2.6% នៃផលិតផលក្នុងស្រុកសរុប (GDP) ចំពេលមានការធ្លាក់ចុះនៃការប្រមូលពន្ធ និងការចំណាយសារពើពន្ធខ្ពស់ទាក់ទងនឹងការរៀបចំការប្រកួតកីឡាស៊ីហ្គេម និងអាស៊ានប៉ារ៉ាហ្គេម។ បើទោះជាបែបនេះក៏ដោយអត្រាប្តូរប្រាក់រៀលនៅតែមានស្ថិរភាពធៀបទៅនឹងប្រាក់ដុល្លារអាមេរិក ហើយអតិផរណាបានធ្លាក់ចុះពី 5.4% មក 2.1% ភាគច្រើនដោយសារតែការធ្លាក់ចុះនៃតម្លៃប្រេង ដែលនាំឱ្យមានការថយចុះនៃអាហារ និងអតិផរណាស្នូល។

របាយការណ៍សេដ្ឋកិច្ចរបស់ធនាគារអភិវឌ្ឍន៍អាស៊ីបង្ហាញថា សេដ្ឋកិច្ចកម្ពុជាត្រូវបានព្យាករណ៍ថានឹងកើនឡើងក្នុងអត្រា 5.6% ក្នុងឆ្នាំ 2024 និង 6% នៅឆ្នាំ 2025 ដែលជម្រុញដោយការស្ទុះងើបឡើងវិញនៃវិស័យទេសចរណ៍ និងទស្សនវិស័យផលិតកម្មដ៏រឹងមាំ។ កម្ពុជាមានបំណងបង្កើនទុនបម្រុងបរទេស និងកាត់បន្ថយការពឹងផ្អែកលើប្រាក់ដុល្លារ តាមរយៈការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលក្នុងគោលបំណងផ្តល់ឱ្យប្រទេសកម្ពុជានូវគោលនយោបាយរូបិយវត្ថុឯករាជ្យបន្ថែមទៀតដើម្បីការពារពីវិបត្តិម៉ាក្រូសេដ្ឋកិច្ចពិភពលោក។

នៅក្នុងរយៈពេល 12 ខែ នៃការិយបរិច្ឆេទ គិតត្រឹមថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2023 ធនាគារ ប៊ីអាយស៊ី ទទួលបានប្រាក់ចំណេញសុទ្ធចំនួន 1.11 លានដុល្លារអាមេរិក កើនឡើងពី 0.09 លានដុល្លារអាមេរិក សម្រាប់រយៈពេលដូចគ្នាដែលបញ្ចប់នៅឆ្នាំ 2022។ ប្រាក់ចំណេញដុលមុនបង់ពន្ធមានចំនួន 1.24 លានដុល្លារអាមេរិក។ ចំណូលប្រតិបត្តិការរបស់ធនាគារធ្លាក់ចុះបន្តិចបន្តួចត្រឹម 15.46 លានដុល្លារអាមេរិក។ ទ្រព្យសកម្មសរុបបានកើនឡើងដល់ 521.60 លានដុល្លារអាមេរិក ពី 330.24 លានដុល្លារអាមេរិកក្នុងឆ្នាំ 2022 ជាមួយនឹងផលបត្រឥណទានមានសមាសភាគធំបំផុតចំនួន 171.24 លានដុល្លារអាមេរិក កើនឡើងពី 119.53 លានដុល្លារអាមេរិកក្នុងឆ្នាំ 2022។ ប្រាក់បញ្ញើពីអតិថិជន និងពីគ្រឹះស្ថានធនាគារ មានចំនួន 435.12 លានដុល្លារអាមេរិកសម្រាប់ការិយបរិច្ឆេទ 2023 ដែលកើនឡើងពី 250.10 លានដុល្លារអាមេរិកក្នុងឆ្នាំ 2022។

ការសម្រេចបានដ៏សំខាន់មួយទៀតនៅក្នុងឆ្នាំនេះ គឺសំដៅដល់លទ្ធផលល្អត្រូវបានជម្រុញដោយការអនុវត្តជោគជ័យរបស់ធនាគារ ប៊ីអាយស៊ី ទៅលើយុទ្ធសាស្ត្រអភិវឌ្ឍន៍ផ្នែកឌីជីថលរបស់ខ្លួន ដោយផ្តោតលើការផ្តល់សេវាធនាគារបែបឌីជីថល និងសេវាកម្មហិរញ្ញវត្ថុដ៏ពិសេសដល់អតិថិជនរបស់យើងក្នុងមូលដ្ឋាន និងទូទាំងតំបន់។

ភាគទុនិកនៃធនាគារ ប៊ីអាយស៊ី កំពុងរួមចំណែកដល់សេដ្ឋកិច្ចកម្ពុជាទាំងមូល តាមរយៈការបង្កើតសកម្មភាពសេដ្ឋកិច្ច ការបង្កើតការងារ ការផ្តល់សេវាធនាគារដល់អ្នកដែលមិនទាន់មានលទ្ធភាពទទួលបានសេវាធនាគារ និងការបន្តពង្រីកលទ្ធភាពនៃតម្រូវការហិរញ្ញវត្ថុដល់សហគ្រាសធុនតូច និងមធ្យម ព្រមទាំងតម្រូវការហិរញ្ញវត្ថុផ្ទាល់ខ្លួននៃឯកត្តបុគ្គលផងដែរ។

ក្រុមប្រឹក្សាភិបាលនៅតែបន្តភាពសកម្មដោយធានាថាយុទ្ធសាស្ត្ររបស់ធនាគារកំពុងត្រូវបានប្រតិបត្តិដោយយោងទៅលើការអនុវត្តប្រកបដោយស្តង់ដារល្អបំផុតក្នុងសកម្មភាពធនាគារ ហិរញ្ញវត្ថុ ការគ្រប់គ្រងហានិភ័យ និងអភិបាលកិច្ចសាជីវកម្ម។

ខ្ញុំសូមថ្លែងអំណរគុណចំពោះអតិថិជនដ៏មានតម្លៃរបស់យើង ភាគីពាក់ព័ន្ធ សមាជិកក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រងគ្រប់ជាន់ថ្នាក់ ព្រមទាំងបុគ្គលិកទាំងអស់ សម្រាប់ការបន្តការគាំទ្រ និងការយកចិត្តទុកដាក់របស់ពួកគេ។

ដោយក្តីគោរព និងកក់ក្តៅបំផុត

លោក យឹម លក្ខណ៍
ប្រធានក្រុមប្រឹក្សាភិបាល

2 សារពីអគ្គនាយក

ភាគទុនិក វិនិយោគិន និងអតិថិជនជាទីរាប់អាន!

ខ្ញុំមានសេចក្តីសោមនស្សរីករាយក្នុងការបង្ហាញពីសមិទ្ធិផលដែលធនាគារ ប៊ីអាយស៊ី សម្រេចបានក្នុងឆ្នាំ 2023។

ខ្ញុំនឹងចាប់ផ្តើមជាមួយនឹងព័ត៌មានសំខាន់ៗអំពីសមិទ្ធិផលហិរញ្ញវត្ថុសម្រាប់ឆ្នាំសារពើពន្ធដែលបញ្ចប់នៅថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2023។ ធនាគារ ប៊ីអាយស៊ី ទទួលបានប្រាក់ចំណេញសុទ្ធចំនួន 1.11 លានដុល្លារអាមេរិក កើនឡើងពី 0.09 លានដុល្លារអាមេរិក សម្រាប់រយៈពេលដូចគ្នាដែលបញ្ចប់នៅឆ្នាំ 2022។ ប្រាក់ចំណេញដុលមុនបង់ពន្ធមានចំនួន 1.24លានដុល្លារអាមេរិក។ ចំណូលប្រតិបត្តិការរបស់ធនាគារធ្លាក់ចុះបន្តិចបន្តួចត្រឹម 15.46 លានដុល្លារអាមេរិក។ ទ្រព្យសកម្មសរុបបានកើនឡើងដល់ 521.60លានដុល្លារអាមេរិក ពី 330.24 លានដុល្លារអាមេរិកក្នុងឆ្នាំ 2022 ជាមួយនឹងផលបត្រឥណទានមានសមាសភាគធំបំផុតចំនួន 171.24 លានដុល្លារអាមេរិក កើនឡើងពី 119.53 លានដុល្លារអាមេរិកក្នុងឆ្នាំ 2022។ ប្រាក់បញ្ញើពីអតិថិជន និងពីគ្រឹះស្ថានធនាគារ មានចំនួន 435.12 លានដុល្លារអាមេរិកសម្រាប់ការិយបរិច្ឆេទ 2023 ដែលកើនឡើងពី 250.10 លានដុល្លារអាមេរិកក្នុងឆ្នាំ 2022។ សមិទ្ធិផលហិរញ្ញវត្ថុទាំងនេះឆ្លុះបញ្ចាំងពីការខិតខំប្រឹងប្រែងរបស់ពួកយើងដើម្បីធ្វើឲ្យមានការកើនឡើង និងមានស្ថិរភាពរបស់ធនាគារ នៅក្នុងទីផ្សារប្រកួតប្រជែង ។

ប្រឈមមុខនឹងភាពមិនប្រាកដប្រជាផ្នែកសេដ្ឋកិច្ច កំណើនអត្រាការប្រាក់ និងភាពតានតឹងជាសកល រួមទាំងជម្លោះរុស្ស៊ី-អ៊ុយក្រែន និងស្ថានភាពប្រឈមរវាងចិន-អាមេរិក ធនាគារ ប៊ីអាយស៊ី នៅតែមិនផ្លាស់ប្តូរនៅក្នុងការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការផ្តល់ជូននូវសេវាកម្មធនាគារបែបឌីជីថលទំនើប សុវត្ថិភាព និងបច្ចេកវិទ្យាទំនើប។ ក្នុងនាមជាស្ថាប័នដែលមានការគ្រប់គ្រងបានយ៉ាងល្អ ពួកយើងមានការប្តេជ្ញាចិត្តក្នុងការសម្រេចបាននូវស្តង់ដារខ្ពស់។ គោលបំណងជាយុទ្ធសាស្ត្រសំខាន់ គឺដើម្បីបង្កើនកិច្ចខិតខំប្រឹងប្រែងផ្នែកទីផ្សាររបស់យើងដើម្បីពង្រឹងភាពល្បីនៃម៉ាកយីហោ ពង្រីកបណ្តាញរបស់យើង និងពង្រឹងទំនុកចិត្តរបស់អតិថិជន។ យើងក៏ផ្តោតលើការរចនាបង្កើតផលិតផល និងសេវាកម្មប្រកបដោយភាពច្នៃប្រឌិត ដោយផ្តោតជាពិសេសលើការបង្កើនការប្រមូលប្រាក់រៀលដើម្បីគាំទ្រដល់គោលនយោបាយរបស់ធនាគារជាតិនៃកម្ពុជាក្នុងការលើកតម្កើងប្រាក់រៀលដោយបន្ថយការពឹងផ្អែកទៅលើប្រាក់ដុល្លារអាមេរិក។ ធនាគារ ប៊ីអាយស៊ី ប្តេជ្ញាផ្តល់នូវសេវាកម្មហិរញ្ញវត្ថុដ៏ទូលំទូលាយតម្រូវតាមតម្រូវការរបស់សហគ្រាសធុនតូច និងមធ្យម អតិថិជន និងសាធារណជនទូទៅក្នុងប្រទេសកម្ពុជា ខណៈពេលដែលធានាបាននូវផលចំណេញសមរម្យដល់ម្ចាស់ភាគទុនិករបស់យើង តាមរយៈផលិតផលធនាគារដែលមានគុណភាពខ្ពស់ ដែលផ្តល់អត្ថប្រយោជន៍ទាំងផ្នែកធនាគារ ដល់ប្រជាជនកម្ពុជា និងដល់ភាគីពាក់ព័ន្ធទាំងអស់។

នៅក្នុងទិដ្ឋភាពប្រតិបត្តិការបច្ចុប្បន្នរបស់យើង ធនាគារ ប៊ីអាយស៊ី មានសាខាប្រតិបត្តិការសរុបចំនួន 5 ដែលមានទីតាំងជាយុទ្ធសាស្ត្រចំនួន 4 នៅក្នុងរាជធានីភ្នំពេញ និង 1 នៅខេត្តព្រះសីហនុដើម្បីបម្រើដល់អតិថិជន និងសហគមន៍។ ការពង្រីកបណ្តាញនេះបញ្ជាក់ពីការតាំងចិត្តដ៏មុតមាំរបស់យើងក្នុងការលើកកម្ពស់ភាពងាយស្រួល និងការផ្តល់ដំណោះស្រាយហិរញ្ញវត្ថុដែលសមស្របតាមតំបន់សំខាន់ៗ។

ជាមួយនឹងការប្តេជ្ញាចិត្តយ៉ាងខ្ជាប់ខ្ជួនចំពោះឧត្តមភាព ប្រតិបត្តិការរបស់យើងរក្សាបាននូវស្ថិរភាពដ៏រឹងមាំចំពេលមានភាពមិនច្បាស់លាស់ខាងសេដ្ឋកិច្ច។ យើងប្រកាន់ខ្ជាប់នូវការអនុវត្តការគ្រប់គ្រងហានិភ័យយ៉ាងតឹងរ៉ឹង ដោយធានានូវភាពធន់ និងការការពារផលប្រយោជន៍របស់ភាគីពាក់ព័ន្ធ។ ដោយចាប់យកនវានុវត្តន៍ផ្នែកឌីជីថលជាមូលដ្ឋានគ្រឹះនៃយុទ្ធសាស្ត្ររបស់យើង ជំនាញផ្នែកព័ត៌មានវិទ្យារបស់យើងបានជម្រុញយើងឱ្យឆ្ពោះទៅមុខ ធ្វើឱ្យប្រតិបត្តិការកាន់តែងាយស្រួល និងបទពិសោធន៍អតិថិជនកាន់តែប្រសើរឡើង។ កម្មវិធីធនាគារតាមទូរស័ព្ទ BIC Mobile ដែលទើបនឹងដាក់ឱ្យដំណើរការនាពេលថ្មីៗនេះ បង្ហាញយ៉ាងជាក់ច្បាស់ពីការយកចិត្តទុកដាក់មិនងាករេរបស់ធនាគារប៊ីអាយស៊ីចំពោះផាសុកភាព និងផ្តល់សិទ្ធិអាទិភាពដល់អតិថិជនក្នុងការទទួលយកសេវាកម្មហិរញ្ញវត្ថុដ៏ទូលំទូលាយតាមបែបឌីជីថល ដែលគំនិតផ្តួចផ្តើមទាំងនេះរួមចំណែកជម្រុញកំណើនប្រកបដោយនិរន្តរភាព និងការផ្តល់នូវគុណតម្លៃ

ពិសេសដល់អតិថិជនរបស់យើងផងដែរ។ តាមរយៈការចាប់ដៃគូជាលក្ខណៈយុទ្ធសាស្ត្រ ធនាគារប៊ីអាយស៊ីបានសម្រេចនូវព្រឹត្តិការណ៍សំខាន់ៗ រួមទាំងការដាក់ឱ្យដំណើរការដោយជោគជ័យនូវប័ណ្ណឥណទាន BIC Credit Mastercards។ កិច្ចសហការទាំងនេះបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់យើងក្នុងការលើកកម្ពស់ភាពកាន់តែងាយស្រួលផ្នែកហិរញ្ញវត្ថុ និងការផ្តល់អាទិភាពដល់អតិថិជនរបស់យើងជាមួយនឹងដំណោះស្រាយទូទាត់ប្រកបដោយភាពច្នៃប្រឌិត។ ជាងនេះទៅទៀត យើងមានមោទនភាពក្នុងការគាំទ្រគំនិតផ្តួចផ្តើម "ប្រកចេញចូលតែមួយ" របស់រដ្ឋាភិបាលតាមរយៈការសហការរបស់យើងជាមួយដៃគូជំនាញខាងការទូទាត់តាមឌីជីថល។

ភាពជាដៃគូនេះបង្ហាញពីការយកចិត្តទុកដាក់របស់យើងក្នុងការជម្រុញវឌ្ឍនភាពសេដ្ឋកិច្ចសង្គមតាមរយៈការសម្រួលដំណើរការ និងការកែលម្អប្រសិទ្ធភាពក្នុងសេវាសាធារណៈ។ ជារួម ការខិតខំទាំងនេះបង្ហាញពីវិធីសាស្ត្រសកម្មរបស់យើងក្នុងការជម្រុញកំណើន ការច្នៃប្រឌិត និងការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពនៅក្នុងសហគមន៍ដែលយើងបម្រើ។

នៅធនាគារ ប៊ីអាយស៊ី យើងចាត់ទុកទំនួលខុសត្រូវសង្គម (CSR) ជាមូលដ្ឋានគ្រឹះនៃអត្តសញ្ញាណរបស់យើងផងដែរ។ ភាពជោគជ័យផ្នែកហិរញ្ញវត្ថុមិនមែនជាគោលដៅតែមួយរបស់យើងប៉ុណ្ណោះទេ ប៉ុន្តែការធ្វើឱ្យមានលទ្ធផលជាវិជ្ជមានដល់សង្គម និងបរិស្ថានក៏ជាគោលការណ៍នៃធនាគារផងដែរ។ តាមរយៈគំនិតផ្តួចផ្តើមក្នុងវិស័យអប់រំ ការថែទាំសុខភាព និងនិរន្តរភាពបរិស្ថាន យើងប្តេជ្ញាជម្រុញការផ្លាស់ប្តូរប្រកបដោយអត្ថន័យ និងបង្កើតអនាគតដ៏ល្អប្រសើរសម្រាប់ទាំងអស់គ្នា។

យើងផ្តល់តម្លៃយ៉ាងជ្រាលជ្រៅចំពោះការជឿទុកចិត្ត និងការគាំទ្រពីភាគទុនិក ដោយសារទំនុកចិត្តរបស់ពួកគាត់ទើបអាចអនុញ្ញាតឱ្យយើងបន្តប្តេជ្ញាក្នុងកំណើនប្រកបដោយនិរន្តរភាព និងការបង្កើតគុណតម្លៃក្នុងរយៈពេលវែង។
ពួកយើងបន្តភាពច្នៃប្រឌិត និងដឹកនាំដោយឧទាហរណ៍ រួមមាន ទំនួលខុសត្រូវសង្គម (CSR) ទៅក្នុងអ្វីគ្រប់យ៉ាងដែលយើងធ្វើ។ រួមគ្នា យើងអាចកសាងបរិយាកាសដែលមាននិរន្តរភាព និងរួមបញ្ចូលកាន់តែច្រើន។

ក្នុងនាមជានាយកប្រតិបត្តិនៃធនាគារ ប៊ីអាយស៊ី នេះជាឯកសិទ្ធិរបស់ខ្ញុំក្នុងការលើកកម្ពស់វប្បធម៌មួយ ដែល "យើងរួមគ្នាតែមួយ!"។ នៅក្នុងទិដ្ឋភាពដ៏ស្វាហាប់នៃធនាគារ ការរួបរួមគឺជាកម្លាំងរបស់យើង។ យើងម្នាក់ៗរួមចំណែកក្នុងការដឹកនាំស្ថាប័នរបស់យើងឆ្ពោះទៅរកភាពជោគជ័យ ដែលជម្រុញដោយបេសកកម្មរួមគ្នាក្នុងការផ្តល់សេវាកម្មហិរញ្ញវត្ថុប្រកដោយតម្លាភាព និងទំនុកចិត្ត។

គោលដៅរបស់យើង គឺច្បាស់លាស់៖ ដើម្បីទទួលបានការជឿទុកចិត្តពីអតិថិជន និងភាគីពាក់ព័ន្ធរបស់យើង ក្នុងនាមជាដៃគូហិរញ្ញវត្ថុប្រកបដោយទំនុកចិត្ត។ គោលដៅនេះផ្តោតលើកិច្ចសហការ និងការខិតខំប្រឹងប្រែងរួមគ្នា។

សូមរក្សានូវវប្បធម៌សហការ និងគាំទ្រគ្នាទៅវិញទៅមក ការប្រកាន់ខ្ជាប់វិន័យមិនផ្លាស់ប្តូរ និងការសម្របខ្លួនយ៉ាងសកម្ម។ រួមគ្នាជាក្រុមតែមួយ យើងត្រៀមខ្លួនដើម្បីសម្រេចបានសមិទ្ធផលគួរឱ្យកត់សម្គាល់។ ការលះបង់ និងការខិតខំរបស់អ្នកត្រូវបានកោតសរសើរយ៉ាងជ្រាលជ្រៅ។

គណៈគ្រប់គ្រងរបស់យើងដោះស្រាយបញ្ហាប្រឈមដោយសុចរិតភាព និងការប្រមើលទុកជាមុន ដោយធានានូវអភិបាលកិច្ចរឹងមាំ និងការអនុវត្តប្រកបដោយនិរន្តរភាព។

យើងសូមថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រចំពោះគណៈគ្រប់គ្រងរបស់ធនាគារ ប៊ីអាយស៊ីគ្រប់ជាន់ថ្នាក់ និងបុគ្គលិកទាំងអស់សម្រាប់ការប្តេជ្ញាចិត្តដ៏មុតមាំរបស់ពួកគេចំពោះឧត្តមភាព។

យើងក៏សូមថ្លែងអំណរគុណចំពោះការជឿទុកចិត្ត និងការបន្តគាំទ្រពីសំណាក់អតិថិជនរបស់យើង ដែលជម្រុញឱ្យយើងផ្តល់នូវបទពិសោធន៍ដ៏ល្អ និងដំណោះស្រាយប្រកបដោយភាពច្នៃប្រឌិត។ រួមគ្នា យើងនឹងបន្តដឹកនាំធនាគារ ប៊ីអាយស៊ី ទៅកាន់វឌ្ឍនភាព។

សូមអរគុណ!

ដោយសេចក្តីគោរព!

លោក ហុង សុខឡេង
អគ្គនាយក

3 ទស្សនវិស័យសេដ្ឋកិច្ចកម្ពុជា និងទិដ្ឋភាពទូទៅនៃវិស័យធនាគារ

ស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និងស្ថិរភាព

នៅឆ្នាំ 2023 សេដ្ឋកិច្ចពិភពលោកបានងើបឡើងវិញក្នុងល្បឿនយឺត ដោយសារជម្លោះភូមិសាស្ត្រនយោបាយ អតិផរណាខ្ពស់ និងលក្ខខណ្ឌហិរញ្ញវត្ថុដ៏តឹងតែង។ សេដ្ឋកិច្ចប្រទេសកម្ពុជាបានកើនឡើងក្នុងអត្រា 5% ដូចគ្នានឹងឆ្នាំ 2022 ប៉ុន្តែនៅក្រោមអត្រាសក្តានុពលរបស់ខ្លួន។ ផលិតកម្ម ជាពិសេសផ្នែកវាយនភ័ណ្ឌបានធ្លាក់ចុះដោយសារតម្រូវការធ្លាក់ចុះពីសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប។ វិស័យកសិកម្មបានកើនឡើងតិចតួច ហើយសកម្មភាពអចលនទ្រព្យបានធ្លាក់ចុះ 0.9%។ ឱនភាពសារពើពន្ធមានចំនួន 2.6% នៃផលិតផលក្នុងស្រុកសរុប ដោយសារតែការប្រមូលពន្ធទាប និងការចំណាយខ្ពស់លើព្រឹត្តិការណ៍ស៊ីហ្គេម អាស៊ានប៉ារ៉ាហ្គេម និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។ អត្រាប្តូរប្រាក់រៀលនៅមានស្ថិរភាព ហើយអតិផរណាបានធ្លាក់ចុះពី 4.5% ទៅ 2.1% ភាគច្រើនដោយសារតម្លៃប្រេងធ្លាក់ចុះ។ ទុនបម្រុងបរទេសបានកើនឡើងដល់ 20 ពាន់លានដុល្លារអាមេរិក ដែលបង្ហាញពីតម្រូវការសម្រាប់ទុនបំរុងបន្ថែម និងប្រាក់រៀលកាន់តែរឹងមាំ ដើម្បីបង្កើនគោលនយោបាយរូបិយវត្ថុ។

វិស័យធនាគារ៖ ការអនុវត្ត និងស្ថិរភាព

ទោះបីជាមានការកើនឡើងនៃហានិភ័យឥណទានក៏ដោយ ក៏ប្រព័ន្ធធនាគារនៅតែមានភាពរឹងមាំ។ កំណើនទ្រព្យសកម្ម និងប្រាក់កម្ចីបានថយចុះមកត្រឹម 8.2% និង 4.2%% រៀងគ្នា។ ឥណទានធនាគារសរុបឈានដល់ 211 ពាន់ពាន់លានរៀល (51.6 ពាន់លានដុល្លារអាមេរិក) ដែលវិស័យឯកជនរួមចំណែកសំខាន់។ ឥណទានមិនដំណើរការបានកើនឡើងពី 2.9% ដល់ 5.1%។ សន្ទនីយភាពនៅតែភាពរឹងមាំ ដោយសារតែអនុបាតក្របខ័ណ្ឌសន្ទនីយភាព របស់ធនាគារមានអត្រាល្អលើសពី 100%។ ប្រាក់ចំណេញសុទ្ធបានធ្លាក់ចុះត្រឹម 45% ដោយសារតែការប្រាក់ខ្ពស់ និងសំវិធានធន ប៉ុន្តែអនុបាតភាពគ្រប់គ្រាន់នៃដើមទុនមានកម្រិតខ្ពស់នៅ 22.3%។ ទ្រព្យសកម្ម និងឥណទានរបស់មីក្រូហិរញ្ញវត្ថុបានធ្លាក់ចុះជិតពាក់កណ្តាលបន្ទាប់ពីការរួមបញ្ចូលគ្នា ជាមួយនឹងគុណភាពឥណទានកាន់តែមានភាពមិនអំណោយផល ប៉ុន្តែនៅតែអាចគ្រប់គ្រងបាន។ ធនាគារឯកទេសទទួលបានកំណើនឥណទានយឺតត្រឹម 1.6% និងអនុបាតឥណទានមិនដំណើរការ 12.1% ប៉ុន្តែ អនុបាតភាពគ្រប់គ្រាន់នៃដើមទុននៅតែរក្សាអត្រាល្អ 39%។

ប្រភព: **National Bank of Cambodia | Annual Financial Stability Review (FSR) 2023**

4 ព័ត៌មានអំពីធនាគារ

ថ្ងៃទី14 ខែវិច្ឆិកា ឆ្នាំ2017 ស្របតាមច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម និងទទួលបានអាជ្ញាប័ណ្ណយោងតាមបទប្បញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា (“NBC”) ហើយធនាគារបានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី18 ខែកក្កដា ឆ្នាំ18 ព្រមទាំងបានចាប់ផ្ដើមដំណើរការអាជីវកម្មរបស់ខ្លួននៅថ្ងៃទី18 ខែសីហា ឆ្នាំ2018 ផងដែរ។

ធនាគារបានចូលរួមយ៉ាងសកម្មនៅក្នុងគ្រប់ទិដ្ឋភាពនៃធុរកិច្ចធនាគារទាំងអស់ ហើយថែមទាំងបានផ្ដល់សេវាហិរញ្ញវត្ថុពាក់ព័ន្ធផ្សេងៗនៅក្នុងព្រះរាជាណាចក្រកម្ពុជាទៀតផង។

ធនាគារត្រូវបានបង្កើតជាលើកដំបូងដោយក្រុមហ៊ុន Asia Investment and Financial Services Sole Co., Ltd នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ក្រុមហ៊ុន Paradise Investment Co., Ltd. នៃព្រះរាជាណាចក្រកម្ពុជា និងក្រុមហ៊ុន Prime Street Advisory Co., Ltd នៃព្រះរាជាណាចក្រថៃ។ នៅថ្ងៃទី29 ខែកញ្ញា ឆ្នាំ2020 ធនាគារជាតិនៃកម្ពុជាបានអនុម័តឱ្យធ្វើការផ្ទេរនូវរាល់ភាគហ៊ុនទាំងអស់របស់ក្រុមហ៊ុន Paradise Investment Co., Ltd (Cambodia) និងក្រុមហ៊ុន Prime Street Advisory Co., Ltd (Thailand) ជូនទៅលោក យឹម លក្ខណ៍ ដោយជំរុញឱ្យមានការពង្រឹងនូវចក្ខុវិស័យ និងបេសកកម្មរបស់ក្រុមប្រឹក្សាភិបាលនៃធនាគារប៊ី.អាយ.ស៊ី បន្ថែមមួយកម្រិតទៀត។

នៅថ្ងៃទី26 ខែឧសភា ឆ្នាំ2023 ភាគហ៊ុន 60% នៃភាគហ៊ុនទាំងអស់នៅក្នុងធនាគារ ប៊ីអាយស៊ី ដែលគ្រប់គ្រងដោយក្រុមហ៊ុន Asia Investment and Financial Services Sole Co., Ltd. នៃប្រទេសឡាវ (AIFS) និង39% នៃភាគហ៊ុនទាំងអស់នៅក្នុងធនាគារ ប៊ីអាយស៊ី ដែលកាន់កាប់ដោយ លោក យឹម លក្ខណ៍ ត្រូវបានផ្ទេរទៅក្រុមហ៊ុន Apsara Holdings Pte. ដែលជាក្រុមហ៊ុនកាន់កាប់ភាគហ៊ុនរបស់ប្រទេសសិង្ហបុរីតំណាងដោយ លោក យឹម លក្ខណ៍ ដែលឥឡូវនេះកាន់កាប់ភាគហ៊ុន99% នៃភាគហ៊ុនទាំងអស់នៅក្នុងធនាគារ ប៊ីអាយស៊ី ហើយភាគហ៊ុន1% នៃភាគហ៊ុនរបស់ ធនាគារ ប៊ីអាយស៊ី ក៏ត្រូវបានកាន់កាប់ដោយលោក យឹម លក្ខណ៍ផងដែរ។

ការផ្ទេរភាគហ៊ុននេះគឺជាព្រឹត្តិការណ៍ដ៏សំខាន់មួយសម្រាប់ធនាគារដែលវាត្រូវបានធ្វើដើម្បីបង្រួបបង្រួម និងរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងភាគហ៊ុនរបស់ធនាគារឡើងវិញ ការឆ្លុះបញ្ចាំងពីការរីកចម្រើននៃទំហំធនាគារ ក៏ដូចជានៅក្នុងមហិច្ឆតា និងការពង្រីកខ្លួនជាលក្ខណៈអន្តរជាតិដោយផ្តល់ឱ្យ នូវជម្រើសជាច្រើនសម្រាប់កំណើនទីផ្សារនាពេលអនាគតរបស់ខ្លួន ការប៉ះពាល់ក្នុងតំបន់ និងអន្តរជាតិ ក៏ដូចជាផលប្រយោជន៍ជាលក្ខណៈយុទ្ធសាស្ត្រ។

រចនាសម្ព័ន្ធភាគទុនិក



4.1 បេសកកម្ម ចក្ខុវិស័យ គុណតម្លៃ

បេសកកម្ម

ភាពឆ្លាតវៃ និងភាពរហ័សរហួនជាងគេក្នុងការផ្តល់អត្ថប្រយោជន៍កាន់តែសម្បូរបែបថែមទៀតជូនដល់អតិថិជនរបស់យើង តាមរយៈការផ្តល់ដំណោះស្រាយមានភាពច្នៃប្រឌិត និងជាក់ស្តែង ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់អតិថិជនទាំងអស់។ យើងក៏បានប្តេជ្ញាចិត្តខ្ពស់ក្នុងការបង្កើតអត្ថប្រយោជន៍សម្រាប់អតិថិជន និងភាគទុនិកទាំងអស់របស់យើង ហើយនឹងខិតខំប្រឹងប្រែងកែលម្អសេវាធនាគាររបស់យើងជាប់ជាប្រចាំផងដែរ តាមរយៈការវិនិយោគជាបន្តបន្ទាប់ទៅលើផ្នែកធនធានមនុស្ស គំនិតច្នៃប្រឌិតថ្មីនិងបច្ចេកវិទ្យា។ យើងពង្រឹងទំនាក់ទំនងភាពជាដៃគូជាមួយនឹងអតិថិជនរបស់យើង តាមរយៈការគោរពគ្នាទៅវិញទៅមក បើកចំហ ស្មោះត្រង់ និងការយល់ដឹងអំពីតម្រូវការរបស់អតិថិជន។

ចក្ខុវិស័យ

មានគោលបំណងក្លាយជាធនាគារដៃគូដ៏ល្អបំផុត តាមរយៈការផ្តល់សេវាបុគ្គលល្អបំផុតទៅតាមតម្រូវការរបស់អតិថិជនម្នាក់ៗ និងការផ្តល់ផលិតផល និងដំណោះស្រាយប្រកបដោយភាពច្នៃប្រឌិតដោយប្រើបច្ចេកវិទ្យាទំនើប ដើម្បីបំពេញតាមតម្រូវការ និងការរំពឹងទុករបស់អតិថិជន។

គុណតម្លៃ

1. ទស្សនៈចំពោះបុគ្គលិក

- ធនធានមនុស្ស គឺជាទ្រព្យសកម្មដ៏ល្អបំផុតរបស់យើង ដូច្នេះយើងបានផ្តោតការយកចិត្តទុកដាក់យ៉ាងសំខាន់ទៅលើការអភិវឌ្ឍធនធានមនុស្សរបស់យើង។ ដំណើរការអភិវឌ្ឍន៍ធនធានមនុស្សដ៏សកម្មគឺជាកត្តាបង្កើន ឧត្តមភាពប្រកួតប្រជែងរបស់យើង។

2. ទស្សនៈចំពោះអតិថិជន

- ផ្តល់សេវាល្អបំផុត និងសេវាធនាគារមានសុវត្ថិភាពដល់អតិថិជន។
- បំពេញតាមតម្រូវការសេវាធនាគារនិងហិរញ្ញវត្ថុជូនអតិថិជន។

3. ទស្សនៈចំពោះភាគទុនិក

- បង្កើតគុណតម្លៃភាគទុនិកកម្រិតខ្ពស់ និងផលរបរនិរន្តរភាពលើទ្រព្យសកម្ម។

4. ទស្សនៈចំពោះសហគមន៍

- គាំទ្រដល់គោលនយោបាយនិងគោលបំណងរបស់ រាជរដ្ឋាភិបាល និងចូលរួមចំណែកអភិវឌ្ឍសហគមន៍ក៏ដូចជាប្រទេសជាតិទាំងមូលឱ្យមានការរីកចំរើន។

រចនាសម្ព័ន្ធ

5.1 រចនាសម្ព័ន្ធនៃធនាគារ




គណៈកម្មាធិការ
គ្រប់គ្រងហានិភ័យ
គណៈកម្មាធិការ
សវនកម្ម
គណៈកម្មាធិការ
គ្រប់គ្រងបច្ចេកវិទ្យា
គណៈកម្មាធិការផ្សេងៗ
បច្ចេកវិទ្យា
ច្បាប់និងប្រតិបត្តិតាម
គ្រប់គ្រងហានិភ័យ
សវនកម្មផ្ទៃក្នុង
ហិរញ្ញប្បទានបុគ្គល
គ្រប់គ្រងឥណទាន
ទំនាក់ទំនងសាធារណៈនិងទីផ្សារ

5.2 ក្រុមប្រឹក្សាភិបាល

លោក យឹម លក្ខណ៍
ប្រធានក្រុមប្រឹក្សាភិបាល

លោក យឹម លក្ខណ៍ មានតួនាទីនៅក្នុងក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនមួយចំនួនដូចជា ប្រធានក្រុមប្រឹក្សា ធនាគារ ប៊ីអាយស៊ី (តាំងពីឆ្នាំ2020 ដែលបម្រើការងារនៅក្នុងក្រុមប្រឹក្សាភិបាលនៅមុនពេលនោះ) និង ក្រុមហ៊ុន BIC Trust ដែលក្រុមហ៊ុនទាំងពីរនេះជាក្រុមហ៊ុនមហាជនទាំងអស់ ព្រមទាំងជាប្រធានក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុន One Central Tower និងក្រុមហ៊ុន U. Property Management ដែលជាក្រុមហ៊ុនឯកជន សកម្មនៅក្នុងវិស័យអចលនទ្រព្យ ព្រមទាំងក្រុមហ៊ុនមួយចំនួនទៀតក្នុងតំណែងជាប្រធានក្រុមប្រឹក្សាភិបាល និងសមាជិកក្រុមប្រឹក្សាភិបាល។

ដោយបានបម្រើការងារនៅក្នុងប្រទេស និងមាតុប្រទេសរបស់លោកយ៉ាងខ្ជាប់ខ្ជួននៅក្នុងអំឡុងពេលយុវវ័យរបស់ខ្លួន លោក យឹម លក្ខណ៍បាន ចាប់ផ្តើមបង្កើតចក្ខុវិស័យប្រកបដោយមហិច្ឆិតាសម្រាប់ប្រទេសកម្ពុជា ហើយចក្ខុវិស័យនេះត្រូវបានពង្រីកគួរឱ្យកត់សម្គាល់យ៉ាង ឆាប់រហ័ស នៅក្នុងដំណាក់កាលអាជីវកម្មនិងសេដ្ឋកិច្ចសកល។ នេះគឺជាចក្ខុវិស័យដែលនៅជាប់នឹងបេះដូងដែលលោកទទួលបានពីគ្រួសាររបស់លោកនិង បានបង្ហាញ ច្បាស់លាស់មិនត្រឹមនៅក្នុងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងសេវាធនាគារនៅកម្ពុជា ប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងនៅក្នុងគម្រោង បឹង ស្នោរដែលមានចក្ខុវិស័យយ៉ាង ធំធេង ដែលជាគម្រោងអភិវឌ្ឍន៍អចលនទ្រព្យពហុគោលបំណងដោយមានទេសភាពលើកកម្ពស់កម្រិតជីវភាព រស់នៅក្នុងសហគមន៍នេះឱ្យលេចធ្លោផងដែរ។

លោក ហុង សុខឡេង
អភិបាល / អគ្គនាយក

លោក ហុង សុខឡេង ត្រូវបានតែងតាំង ជាអគ្គនាយកនៃធនាគារ ប៊ីអាយស៊ី ហើយដឹកនាំយុទ្ធសាស្ត្ររីកចម្រើនរបស់ធនាគារ ប៊ីអាយស៊ី នៅក្នុងប្រទេសកម្ពុជា និងក្នុងតំបន់ ជាមួយនឹងទំនួលខុសត្រូវចំពោះអាទិភាពយុទ្ធសាស្ត្រស្នូល សាជីវកម្មធនាគារ ភាពជាដៃគូអន្តរជាតិ និងការធ្វើអាជីវកម្មបែបឌីជីថល។ តាមទស្សនវិស័យជាយុទ្ធសាស្ត្រ និងការយកចិត្តទុកដាក់ជាអាទិភាពចំពោះអតិថិជនរបស់ធនាគារ ប៊ីអាយស៊ី លោក ហុង សុខឡេង ដឹកនាំ និងរៀបចំគំនិតផ្តួចផ្តើមការផ្លាស់ប្តូរ ដែលជម្រុញឲ្យមានការរីកចម្រើនក្នុងវិស័យធនាគារសាជីវកម្ម បង្កើតភាពជឿជាក់ និងទំនុកចិត្តលើមូលដ្ឋាននៃភាពជាដៃគូក្នុងតំបន់ និងអន្តរជាតិដែលកំពុងរីកចម្រើនរបស់ធនាគារ ប៊ីអាយស៊ី និងការធ្វើឲ្យធនាគារឈានមុខគេនៃការធ្វើអាជីវកម្មបែបឌីជីថល និងការបង្កើតអង្គភាពដែលជម្រុញឲ្យមានដំណើរការប្រកបដោយប្រសិទ្ធភាព ដើម្បីភាពរីកចម្រើនប្រកបដោយនិរន្តរភាព និងស្ថិរភាពសម្រាប់ឆ្នាំខាងមុខ។

លោក ហុង សុខឡេង មានបទពិសោធន៍ជាង 20ឆ្នាំនៃយុទ្ធសាស្ត្រការអភិវឌ្ឍន៍អាជីវកម្ម និងសេវាកម្មហិរញ្ញវត្ថុ ដែលក្នុងនោះជាង 15ឆ្នាំ លោកបានបម្រើការក្នុងតួនាទី ប្រតិបត្តិជាន់ខ្ពស់ ក្នុងវិស័យធនាគារ ដោយលោកធ្លាប់បម្រើការងារជាអនុប្រធានជាន់ខ្ពស់ ប្រធានផ្នែកធុរកិច្ចធនាគារ និងជាប្រធានផ្នែកសាជីវកម្ម និង SME Banking។ ពេញមួយអាជីពរបស់គាត់ គាត់បានដើរតួនាទីយ៉ាងសំខាន់ក្នុងការពន្លឿនកំណើននៃប្រាក់បញ្ញើអាជីវកម្ម និងសហគ្រាសធុនតូច និងមធ្យម បង្កើនតម្លៃនៃផលប័ត្រប្រាក់កម្ចី និងបង្កើតទំនាក់ទំនងជាមួយក្រុមហ៊ុនឈានមុខជាច្រើន។

លោក ហុង សុខឡេង បានទទួលសញ្ញាប័ត្រថ្នាក់បណ្ឌិតផ្នែកភាពជាអ្នកដឹកនាំ និងគ្រប់គ្រង ពីសកលវិទ្យាល័យអន្តរជាតិអឺរ៉ុប (European International University) នៅទីក្រុងប៉ារីស និងបរិញ្ញាប័ត្រផ្នែករដ្ឋបាល និងគ្រប់គ្រង ពីសកលវិទ្យាល័យន័រតុន។

លោក យា សារឿន
អភិបាល / អគ្គនាយករង

លោក យា សារឿន ទទួលបានបរិញ្ញាបត្រផ្នែកគ្រប់គ្រងពាណិជ្ជកម្ម មានបទពិសោធន៍យ៉ាងទូលំទូលាយក្នុងការគ្រប់គ្រងអាជីវកម្មលើវិស័យផ្សេងៗក្នុងប្រទេសកម្ពុជា។

លោកបានបម្រើការជា អគ្គនាយករងនៃក្រុមហ៊ុន ប៊ី.អាយ.ស៊ី គ្រុប ឯ.ក (B.I.C Group Co., Ltd.) ដែលលោកបានត្រួតពិនិត្យការវិនិយោគជាច្រើន ជាពិសេសនៅក្នុងវិស័យហិរញ្ញវត្ថុ។ មុននឹងបំពេញតួនាទីនេះ លោកបានផ្តល់ការណែនាំជាយុទ្ធសាស្ត្រ ក្នុងនាមជាទីប្រឹក្សាប្រធានក្រុមហ៊ុន ប៊ី.អាយ.ស៊ី ឌីវេឡុបមេន ឯ.ក (B.I.C Development Co., Ltd.) ដែលផ្តោតលើការវិនិយោគលើអចលនទ្រព្យ។

ក្នុងនាមជាអភិបាលនៃធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក លោក យា សារឿន បន្តប្រើជំនាញរបស់គាត់សម្រាប់ការរីកចម្រើនជាយុទ្ធសាស្ត្រនៅក្នុងឧស្សាហកម្មធនាគារ។ អាជីពរបស់ សារឿន ឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តយ៉ាងខ្ជាប់ខ្ជួនចំពោះឧត្តមភាព និងភាពប៉ិនប្រសប់ក្នុងការជំរុញឱ្យទទួលបានជោគជ័យក្នុងទិដ្ឋភាពធុរកិច្ចដ៏ស្វាហាប់របស់កម្ពុជា។

លោក JOHN EDWARD MC COSH

អភិបាលឯករាជ្យ

លោក MC COSH JOHN EDWARD បានបម្រើការងារនៅសហរដ្ឋអាមេរិក អឺរ៉ុប អាហ្វ្រិក និងអាស៊ី ក្នុងតួនាទីគ្រប់គ្រង និងប្រតិបត្តិការផ្សេងៗ។ បច្ចុប្បន្នលោក JONH គឺជាអនុប្រធានផ្នែកអភិវឌ្ឍន៍របស់ក្រុមហ៊ុន BIC Group ដែលពីមុន គាត់គឺជានាយកប្រតិបត្តិរបស់ក្រុមហ៊ុន Sapparot Group និងពីមុនជាមួយនឹងក្រុមហ៊ុន Four Seasons Hotels and Resorts ដែលបានបើកអចលនទ្រព្យថ្មីៗ ដឹកនាំក្រុម និងរៀបចំនីតិវិធីប្រតិបត្តិការ និងស្តង់ដារសេវា និងផលិតផល។

លោក JONH បានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិតផ្នែកគ្រប់គ្រងធុរកិច្ចពី HEC Paris និងសាកលវិទ្យាល័យ Witwatersrand និងថ្នាក់ undergraduate degree ពីសាលា Ecole Hôtelière de Lausanne។

លោក ភេ វុទ្ធី

អភិបាលឯករាជ្យ

លោក ភេ វុទ្ធី ជាអ្នកជំនាញផ្នែកច្បាប់ដែលមានសញ្ញាប័ត្រអនុបណ្ឌិតពីរផ្នែកច្បាប់ពាណិជ្ជកម្មអន្តរជាតិ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ក្នុងទីក្រុងភ្នំពេញ ប្រទេសកម្ពុជា និងសាកលវិទ្យាល័យ Paris-Panthéon-Assas ប្រទេសបារាំង។ លោក វុទ្ធី មានបទពិសោធន៍យ៉ាងទូលំទូលាយផ្នែកច្បាប់ និងផ្នែកប្រឹក្សាវិនិយោគ។

តួនាទីថ្មីបំផុតរបស់គាត់ គឺជាទីប្រឹក្សាច្បាប់ជាន់ខ្ពស់ សម្រាប់ក្រុមហ៊ុនអភិវឌ្ឍន៍អចលនទ្រព្យ និងវិនិយោគដ៏លេចធ្លោមួយនៅកម្ពុជា។ មុននេះ លោកបានបម្រើការជាទីប្រឹក្សាផ្នែកច្បាប់ និងវិនិយោគដល់ក្រុមហ៊ុនផ្សេងៗ រួមទាំងជំនាញផ្នែកសេវាកម្មហិរញ្ញវត្ថុ និងព័ត៌មានវិទ្យាផងដែរ។

លោក វុទ្ធី បានបន្ថែមជំនាញរបស់ខ្លួនបន្ថែមទៀត ដោយបានចូលរួមជាមួយធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក ជាអភិបាលឯករាជ្យក្នុងខែមីនា ឆ្នាំ2023។ ប្រវត្តិវិជ្ជាជីវៈ និងគុណវុឌ្ឍិសិក្សាចម្រុះរបស់គាត់បានផ្តល់ឱ្យគាត់នូវការយល់ដឹងដ៏ទូលំទូលាយអំពីភាពស្មុគស្មាញផ្នែកច្បាប់ និងយុទ្ធសាស្រ្តវិនិយោគ ដែលធ្វើអោយគាត់ក្លាយជាធនធានដ៏មានតម្លៃ។

5.3 គណៈគ្រប់គ្រង

លោក ហុង សុខឡេង

អគ្គនាយក

លោក ហុង សុខឡេង ត្រូវបានតែងតាំង ជាអគ្គនាយក នៃធនាគារ ប៊ីអាយស៊ី ហើយដឹកនាំយុទ្ធសាស្ត្ររីកចម្រើនរបស់ធនាគារ ប៊ីអាយស៊ី នៅក្នុងប្រទេសកម្ពុជា និងក្នុងតំបន់ ជាមួយនឹងទំនួលខុសត្រូវចំពោះអាទិភាពយុទ្ធសាស្ត្រស្នូល សាជីវកម្មធនាគារ ភាពជាដៃគូអន្តរជាតិ និងការធ្វើអាជីវកម្មបែបឌីជីថល។ តាមទស្សនវិស័យជាយុទ្ធសាស្ត្រ និងការយកចិត្តទុកដាក់ជាអាទិភាពចំពោះអតិថិជនរបស់ធនាគារ ប៊ីអាយស៊ី លោក ហុង សុខឡេង ដឹកនាំ និងរៀបចំគំនិតផ្តួចផ្តើមការផ្លាស់ប្តូរ ដែលជម្រុញឲ្យមានការរីកចម្រើនក្នុងវិស័យធនាគារសាជីវកម្ម បង្កើតភាពជឿជាក់ និងទំនុកចិត្តលើមូលដ្ឋាននៃភាពជាដៃគូក្នុងតំបន់ និងអន្តរជាតិដែលកំពុងរីកចម្រើនរបស់ធនាគារ ប៊ីអាយស៊ី និងការធ្វើឲ្យធនាគារឈានមុខគេនៃការធ្វើអាជីវកម្មបែបឌីជីថល និងការបង្កើតអង្គភាពដែលជម្រុញឲ្យមានដំណើរការប្រកបដោយប្រសិទ្ធភាព ដើម្បីភាពរីកចម្រើនប្រកបដោយនិរន្តរភាព និងស្ថិរភាពសម្រាប់ឆ្នាំខាងមុខ។

លោក ហុង សុខឡេង មានបទពិសោធន៍ជាង 20ឆ្នាំនៃយុទ្ធសាស្ត្រ ការអភិវឌ្ឍន៍អាជីវកម្ម និងសេវាកម្មហិរញ្ញវត្ថុ ដែលក្នុងនោះជាង 15ឆ្នាំ លោកបានបម្រើការក្នុងតួនាទី ប្រតិបត្តិជាន់ខ្ពស់ ក្នុងវិស័យធនាគារ ដោយលោកធ្លាប់បម្រើការងារជាអនុប្រធានជាន់ខ្ពស់ ប្រធានផ្នែកធុរកិច្ចធនាគារ និងជាប្រធានផ្នែកសាជីវកម្ម និង SME Banking។ ពេញមួយអាជីពរបស់គាត់ គាត់បានដើរតួនាទីយ៉ាងសំខាន់ក្នុងការពន្លឿនកំណើននៃប្រាក់បញ្ញើអាជីវកម្ម និងសហគ្រាសធុនតូច និងមធ្យម បង្កើនតម្លៃនៃផលប័ត្រប្រាក់កម្ចី និងបង្កើតទំនាក់ទំនងជាមួយក្រុមហ៊ុនឈានមុខជាច្រើន។

លោក ហុង សុខឡេង បានទទួលសញ្ញាប័ត្រថ្នាក់បណ្ឌិតផ្នែកភាពជាអ្នកដឹកនាំ និងគ្រប់គ្រង ពីសកលវិទ្យាល័យអន្តរជាតិអឺរ៉ុប (European International University) នៅទីក្រុងប៉ារីស និងបរិញ្ញាប័ត្រផ្នែករដ្ឋបាល និងគ្រប់គ្រង ពីសកលវិទ្យាល័យន័រតុន។

លោកស្រី អៀន លក្ខិណា
នាយិកាប្រតិបត្តិការ

លោកស្រី អៀន លក្ខិណា បច្ចុប្បន្នបម្រើការជានាយិកាប្រតិបត្តិការ នៅធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ភីអិលស៊ី ទទួលបន្ទុកផ្នែកប្រតិបត្តិការកណ្តាល ប្រតិបត្តិការសាខា ប្រតិបត្តិកាឥណទាន ការគ្រប់គ្រងកណ្តាល មជ្ឈមណ្ឌលកាត និងសេវាឌីជីថល ចាប់តាំងពីខែមិថុនាឆ្នាំ2023។ មុនពេលបម្រើការនៅធនាគារ ប៊ីអាយស៊ី លោកស្រីបម្រើការនៅក្នុងផ្នែកផ្សេងៗ ក្នុងតួនាទីជាមួយធនាគារអន្តរជាតិ ធនាគារសាជីវកម្ម និងធនាគារក្នុងស្រុកធំមួយនៅកម្ពុជា ជាមួយនឹងការដឹកនាំ និងបទពិសោធន៍យ៉ាងទូលំទូលាយក្នុងវិស័យហិរញ្ញវត្ថុ និងធនាគារ រួមទាំងប្រតិបត្តិការឥណទាន ការគ្រប់គ្រងគម្រោង សេវាកម្មបុគ្គល និងសាជីវកម្ម។

លោកស្រី លក្ខិណា មានបទពិសោធន៍ការងារ ជាង 22ឆ្នាំ។ លោកស្រីបានចាប់ផ្តើមអាជីពដំបូងជាគណនេយ្យករនៅធនាគារក្នុងស្រុកមួយក្នុងឆ្នាំ2022 និងផ្នែកហិរញ្ញវត្ថុនៅក្រុមហ៊ុនវេជ្ជសាស្ត្រក្នុងឆ្នាំ 2024។ លោកស្រីបានបន្តបទពិសោធន៍ក្នុងវិស័យធនាគារផ្នែកសេវាកម្មបុគ្គល និងប្រតិបត្តិការឥណទានក្នុងឆ្នាំ2007 នៅធនាគារអន្តរជាតិមួយអស់រយៈពេលជាង 7ឆ្នាំ។ លើសពីនេះ លោកស្រីបានបន្តការងារជាមួយធនាគារក្នុងស្រុកដ៏ធំបំផុតមួយក្នុងប្រទេសកម្ពុជានៅចុងឆ្នាំ2014។ លោកស្រីបានកាន់មុខតំណែងជាន់ខ្ពស់ជាច្រើនដូចជា ប្រធានផ្នែកវិភាគសារជីវកម្ម ប្រធានយុទ្ធសាស្ត្រសាជីវកម្ម ប្រធានផ្នែកគ្រប់គ្រងគម្រោង និងជាប្រធានប្រតិបត្តិការកណ្តាល ។

លោក DONG QUANG THANG (VIN)
នាយកស្តីទីប្រតិបត្តិបច្ចេកវិទ្យា

លោក Dong Quang Thang (Vincent) មានបទពិសោធន៍ជាង 17ឆ្នាំក្នុងវិស័យព័ត៌មានវិទ្យា អាជីវកម្មឌីជីថល ការអភិវឌ្ឍន៍ផលិតផល និងការអភិវឌ្ឍន៍យុទ្ធសាស្ត្រសាជីវកម្ម ឯកទេសក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ ដែលមានជាង 10ឆ្នាំបម្រើការការងារក្នុងតួនាទីជាន់ខ្ពស់ និងប្រតិបត្តិក្នុងវិស័យនេះ ដោយធ្លាប់បម្រើការងារជា នាយករងផ្នែកព័ត៌មាននៃធនាគារ Maritime Commercial Vietnam និងស្ថាប័នមួយចំនួនដូចជា VPBank Vietnam, Orient Commercial Bank Vietnam, Techcombank Vietnam, Samsung Electronics, FPT Corporation ។

លោក Vincent បានទទួលសញ្ញាប័ត្រអនុបណ្ឌិតពីសាកលវិទ្យាល័យ Paris Patheon Sorbonne និងបរិញ្ញាបត្រផ្នែកព័ត៌មានវិទ្យាពីសកលវិទ្យាល័យជាតិវៀតណាម HCM ។

លោក VO DUY ANH DUNG (ANDY)

នាយកហិរញ្ញប្បទានបុគ្គល

ជាមួយនឹងអនុបណ្ឌិតផ្នែកអាជីវកម្ម និងពាណិជ្ជកម្មពីសាកលវិទ្យាល័យ Sydney លោក Vo Duy Anh Dung (Andy) មានបទពិសោធន៍ផ្នែកធនាគារជាង 15ឆ្នាំ។ គាត់មានជំនាញក្នុងវិស័យហិរញ្ញប្បទានបុគ្គលក្នុងប្រទេសវៀតណាម និងតៃវ៉ាន់ បង្កើនមូលដ្ឋានអតិថិជន និងដឹកនាំដំណើរវិវឌ្ឍន៍ឌីជីថលដែលសន្សំសំចៃ។ លោក Vo Duy Anh Dung មានឯកទេសក្នុងការវិភាគហិរញ្ញវត្ថុ ការធ្វើផែនការយុទ្ធសាស្រ្ត និងការគ្រប់គ្រងហានិភ័យ។ លោក Andy មានភាពសកម្មក្នុងការគ្រប់គ្រងប្រកបដោយវិជ្ជាជីវៈ និងកម្មវិធីចំណេះដឹងផ្នែកហិរញ្ញវត្ថុសហគមន៍ ដែលរួមចំណែកដល់ការច្នៃប្រឌិត និងការរីកចម្រើនក្នុងវិស័យធនាគារពិភពលោក។

លោក Vo Duy Anh Dung ធ្លាប់មានបទពិសោធន៍នៅធនាគារ VPBank និងធនាគារ OCB ដែលជាធនាគារផ្តល់ហិរញ្ញប្បទានបុគ្គលធំជាងគេចំនួនពីររបស់វៀតណាម ហើយបានបម្រើការជាប្រធានមជ្ឈមណ្ឌលធុរកិច្ច និងជាប្រធានមជ្ឈមណ្ឌលភាពជាដៃគូ ដែលលោកបានដឹកនាំគំនិតផ្តួចផ្តើមយុទ្ធសាស្រ្តដើម្បីបង្កើនប្រតិបត្តិការអាជីវកម្ម និងសេវាកម្មអតិថិជន ជំរុញសម្ព័ន្ធភាពសំខាន់ៗ និងជំរុញកំណើនអាជីវកម្មតាមរយៈភាពជាដៃគូប្រកបដោយភាពច្នៃប្រឌិត។ លោក Vo Duy Anh Dung បានចំណាយពេល 4ឆ្នាំជាមួយធនាគារ Sinopac Vietnam ដែលជាធនាគារតៃវ៉ាន់ក្នុងតួនាទីជាប្រធានផ្នែកហិរញ្ញប្បទានបុគ្គលដោយលោកបានពង្រីកវិសាលភាពផ្នែកហិរញ្ញប្បទានបុគ្គលប្រកបដោយភាពជោគជ័យ និងអនុវត្តយុទ្ធសាស្រ្តរក្សាអតិថិជនប្រកបដោយប្រសិទ្ធភាពនៅក្នុងប្រទេសវៀតណាម។

លោក សំ ហូង

នាយកធនធានមនុស្ស

លោក សំ ហូង បានចូលរួមជាមួយធនាគារ ប៊ីអាយស៊ី នៅខែសីហា ឆ្នាំ2023 ជានាយកផ្នែកធនធានមនុស្ស។ គាត់ដឹកនាំក្រុមដើម្បីគាំទ្រដល់អាជីវកម្មធនាគារតាមរយៈការទទួលបានទេពកោសល្យ ភាពប៉ិនប្រសប់ និងការអភិវឌ្ឍន៍អង្គការ ការគ្រប់គ្រងការអនុវត្ត សំណង និងអត្ថប្រយោជន៍ និងការចូលរួមក្នុងក្រុម។

លោក បានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងធុរកិច្ចផ្នែកគ្រប់គ្រង និងអនុបណ្ឌិតផ្នែកសិល្បៈភាសាអង់គ្លេសក្នុងឆ្នាំ 2008។ លោក សំ ហូង ដើរតួនាទីផ្សេងៗក្នុងការបង្រៀនភាសាអង់គ្លេសជាភាសាបរទេស (TEFL) និងការគ្រប់គ្រងធនធានមនុស្សក្នុងរយៈពេល 20ឆ្នាំកន្លងមកនេះ។

លោក បាន ម៉ារ៉ា
ប្រធាននាយកដ្ឋាន ហិរញ្ញវត្ថុ និងរតនាគារ

លោក បាន ម៉ារ៉ា គឺជាអ្នកជំនាញផ្នែកហិរញ្ញវត្ថុដ៏ឆ្នើមម្នាក់ដែលមានបទពិសោធន៍ជាង 13 ឆ្នាំនៅក្នុងវិស័យធនាគារ។ គាត់បានចូលបម្រើការងារជាមួយធនាគារ ប៊ីអាយស៊ី ក្នុងខែកញ្ញា ឆ្នាំ2018 ជាប្រធានផ្នែកហិរញ្ញវត្ថុ ហើយបានឈានមុខតំណែងជាអ្នកគ្រប់គ្រងជាន់ខ្ពស់ ហិរញ្ញវត្ថុ និងរតនាគារក្នុងខែមករា ឆ្នាំ2020។ នៅខែកក្កដា ឆ្នាំ2023 គាត់ត្រូវបានតែងតាំងជាប្រធាននាយកដ្ឋាន ហិរញ្ញវត្ថុ និងរតនាគារ។

លោក ម៉ារ៉ា មានបទពិសោធន៍ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុពន្ធដារ ការគ្រប់គ្រងហិរញ្ញវត្ថុ ការរៀបចំផែនការអាជីវកម្ម ហើយក៏មានបទពិសោធន៍គ្រប់គ្រងគម្រោងនានាផងដែរ រួមមានការផ្លាស់ប្តូរស្តង់ដារគណនេយ្យដោយអនុលោមតាម CIFRS និងការអនុវត្តប្រព័ន្ធធនាគារដែលរួមចំណែកយ៉ាងសំខាន់ដល់ស្ថិរភាព និងកំណើនហិរញ្ញវត្ថុរបស់ធនាគារ ប៊ីអាយស៊ី។

លោកបានបញ្ចប់បរិញ្ញាបត្រផ្នែកហិរញ្ញវត្ថុ និងធនាគារ ពីសាកលវិទ្យាល័យជាតិគ្រប់គ្រង នៅឆ្នាំ2010 ហើយបច្ចុប្បន្ន លោកកំពុងបន្តការសិក្សាកម្រិត ACCA នៅសាលា CamED Business School នៅរាជធានីភ្នំពេញ ប្រទេសកម្ពុជា។

លោក សួន សូផានីកា
ប្រធាននាយកដ្ឋានគ្រប់គ្រងហានិយភ័យ

លោក សួន សូផានីកា បានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងហិរញ្ញវត្ថុ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ហើយលោកមាន បទពិសោធន៍យ៉ាងទូលំទូលាយក្នុងវិស័យសេវាកម្មហិរញ្ញវត្ថុរយៈពេល 15ឆ្នាំ ដែលមានជំនាញគ្រប់គ្រងមុខងារដូចជា ហានិភ័យ ប្រតិបត្តិតាម និងហិរញ្ញវត្ថុ ដែលក្នុងនោះគាត់មានបទពិសោធន៍ 12ឆ្នាំ ក្នុងការគ្រប់គ្រងហានិភ័យ។

លោកមានជំនាញក្នុងការវិភាគ និងមានចំណេះដឹងទូលំទូលាយក្នុងការគ្រប់គ្រងហានិភ័យទាំងអស់ រួមមានហានិភ័យឥណទាន ហានិភ័យប្រតិបត្តិការ ហានិភ័យទីផ្សារ និងហានិភ័យសាច់ប្រាក់ងាយស្រួល។ គាត់បានចូលរួមចំណែក និងចែករំលែកចំណេះដឹង និងបទពិសោធន៍របស់គាត់ ដើម្បីគាំទ្រដល់វិទ្យាស្ថានធនាគារ និងហិរញ្ញវត្ថុ (Institution of Banking and Finance) ដើម្បីបង្កើតក្របខ័ណ្ឌសមត្ថភាពសម្រាប់ការគ្រប់គ្រងហានិភ័យ ដែលជាក្របខ័ណ្ឌពិពណ៌នាអំពីសំណុំជំនាញអប្បបរមាដែលត្រូវការ ដើម្បីបំពេញការងារជាអ្នកគ្រប់គ្រងហានិភ័យប្រកបដោយប្រសិទ្ធភាព។

គាត់បានចូលបម្រើការងារជាមួយធនាគារ ប៊ីអាយស៊ី ក្នុងមុខតំណែងជាប្រធាននាយកដ្ឋានគ្រប់គ្រងហានិភ័យ នៅថ្ងៃទី8 ខែសីហា ឆ្នាំ 2022។ មុនពេលបំពេញតួនាទីនេះ គាត់បានបម្រើការជាប្រធាននាយកដ្ឋានគ្រប់គ្រងហានិភ័យនៅធនាគារធំៗមួយចំនួនក្នុងប្រទេសកម្ពុជា និងក៏ធ្លាប់ជាប្រធាននាយកដ្ឋានគ្រប់គ្រងហានិភ័យរបស់សហគ្រាសរដ្ឋ (state-owned enterprise) ក្រោមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

លោក គឹម លី

ប្រធាននាយកដ្ឋានឥណទាន

លោក គឹម លី បច្ចុប្បន្នមានតួនាទីជាប្រធាននាយកដ្ឋានឥណទាន ចាប់ពីថ្ងៃទី15 ខែ ឧសភា ឆ្នាំ2023 នៅធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ភីអិលស៊ី និងដឹកនាំនាយកដ្ឋានឥណទានក្នុងការគ្រប់គ្រងហានិភ័យឥណទានទាំងមូល។

ដោយបានបម្រើការងារក្នុងវិស័យធនាគារអស់រយៈពេលជាង 16ឆ្នាំ ដែលមានតួនាទីជាអ្នកគ្រប់គ្រងជាង 8ឆ្នាំ លោក គឹម លី បាននិងកំពុងបង្កើតបទពិសោធន៍ និងជំនាញក្នុងតួនាទីផ្សេងៗក្នុងវិស័យធនាគារ ដូចជាការផ្តល់ប្រាក់កម្ចីសាជីវកម្ម ការគ្រប់គ្រងឥណទាន ហិរញ្ញប្បទានពាណិជ្ជកម្ម និងការគ្រប់គ្រងហិរញ្ញប្បទានគម្រោង។ មុននឹងចូលជាសមាជិក ធនាគារ ប៊ីអាយស៊ី លោកបានធ្វើការជាមួយនឹងធនាគារធំមួយក្នុងចំនោមធនាគារទាំង ៣ ក្នុងប្រទេសកម្ពុជា ជាប្រធានផ្នែកទំនាក់ទំនងសាជីវកម្ម ប្រធានស្តីទីផ្នែកហិរញ្ញវត្ថុពាណិជ្ជកម្ម និងជាប្រធានផ្នែកហិរញ្ញប្បទានគម្រោង។

លោក គឹម លី បានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិតផ្នែកសេដ្ឋកិច្ច និងគ្រប់គ្រងទូទៅ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងសញ្ញាបត្រផ្នែកច្បាប់ពាណិជ្ជកម្មកម្ពុជា ពីសាលា CamEd Business School។

លោក អ៊ឹម សុធា

ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង

លោក អ៊ឹម សុធា បានចូលបម្រើការងារនៅធនាគារ ប៊ីអាយស៊ី ក្នុងខែមីនា ឆ្នាំ2024 ជាប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង។ លោកទទួលបន្ទុកលើការបង្កើត និងត្រួតពិនិត្យផែនការសវនកម្មផ្ទៃក្នុង គោលនយោបាយ/នីតិវិធីសវនកម្ម និងវាយតំលៃប្រព័ន្ធការគ្រប់គ្រងផ្ទៃក្នុងរបស់ធនាគារ ដើម្បីធានាបានថា "ប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង" ស្ថិតនៅនឹងកន្លែង និងត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវដោយបុគ្គលិក និងអ្នកគ្រប់គ្រង។

មុនពេលចូលបម្រើការងារនៅធនាគារ ប៊ីអាយស៊ី លោក សុធា គឺជាប្រធានផ្នែកសវនកម្មផ្ទៃក្នុង និងជាប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុងនៅធនាគារពាណិជ្ជក្នុងស្រុក/អន្តរជាតិចំនួន 4អស់រយៈពេលជាង 16ឆ្នាំ។ គាត់មានបទពិសោធន៍ផ្នែកធនាគារយ៉ាងទូលំទូលាយ ជាពិសេស លើការធ្វើសវនកម្មផ្ទៃក្នុង ក៏ដូចជាការបង្កើតគោលនយោបាយ និងនីតិវិធីសវនកម្មផ្ទៃក្នុង ធ្វើការវាយតម្លៃហានិភ័យ ធ្វើការស៊ើបអង្កេតការក្លែងបន្លំ/ការប្រព្រឹត្តិកំហុសឆ្គងនានា ដើម្បីពង្រឹងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងផ្តល់នូវការធានាលើអភិបាលកិច្ចនៅក្នុងស្ថាប័នហិរញ្ញវត្ថុ។

លោក សុធា បញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកសវនកម្ម និងបរិញ្ញាបត្រគណនេយ្យពីគ្រឹះស្ថានក្នុងស្រុក។ លើសពីនេះគាត់ទទួលបានវិញ្ញាបនបត្រវិជ្ជាជីវៈជាច្រើនពីស្ថាប័ន/សមាគមវិជ្ជាជីវៈក្នុងស្រុក និងអន្តរជាតិ (កម្ពុជា ម៉ាឡេស៊ី និងថៃ)។

ការគ្រប់គ្រងធនធានមនុស្ស

ជាយន្តការដែលអង្គភាពប្រើប្រាស់សម្រាប់គ្រប់គ្រងការជ្រើសរើស អភិវឌ្ឍន៍ និងបង្កើនប្រសិទ្ធភាពបុគ្គលិក ដើម្បីបង្កើនគុណតម្លៃរបស់ពួកគេចំពោះធនាគារ ដែលត្រូវបានគេស្គាល់ថា "ការគ្រប់គ្រងធនធានមនុស្ស"។ នៅពេលដែលការគ្រប់គ្រងធនធានមនុស្សត្រូវបានប្រតិបត្តិបានល្អ និងប្រសិទ្ធភាព នោះនឹងនាំឱ្យ "ការជ្រើសរើសធនធានដ៏ត្រឹមត្រូវ"។ ការគ្រប់គ្រងធនធានមនុស្ស ដើរតួនាទីយ៉ាងសំខាន់ការថែរក្សា និងដឹកនាំចាត់ចែង លើមធ្យោបាយ និងដំណើរការផ្សេងៗ។

ក្រមសីលធម៌

ក្រមសីលធម៌ សំដៅលើផ្នត់គំនិត និងគោលការណ៍ជាមូលដ្ឋាននៃអាកប្បកិរិយាសមរម្យរបស់មនុស្ស។ ក្រមសីលធម៌ និងក្រមសីលធម៌ធុរកិច្ច ត្រូវបានចងក្រងជាឯកសារដើម្បីកំណត់វិធាន និងស្តង់ដារសម្រាប់អនុវត្តលើរបៀបដែលយើងទាំងអស់គ្នាធ្វើការ ដើម្បីអភិវឌ្ឍន៍ធនាគារ និងផ្តល់សេវាដល់អតិថិជនរបស់យើង ការពារគុណតម្លៃរបស់ធនាគារ ផលប្រយោជន៍របស់ភាគទុនិក និងផ្តល់ការយកចិត្តទុកដាក់បុគ្គលិករបស់យើង។

ដំណើរការជ្រើសរើសបេក្ខជនដ៏ត្រឹមត្រូវ

គោលដៅនៃការជ្រើសរើសបុគ្គលិក គឺដើម្បីកំណត់ និងជ្រើសរើសបេក្ខជនដែលស័ក្តិសមបំផុតជាមួយនឹងតួនាទី និងអាជីវកម្មទាក់ទងនឹងបទពិសោធន៍ វប្បធម៌ និងសមត្ថភាព។ ផ្នែកជ្រើសរើសបុគ្គលិករបស់យើងបានលើកកម្ពស់សមត្ថភាពនៃការសម្រេចចិត្តជ្រើសរើសបុគ្គលិកតាមរយៈនីតិវិធីដែលមានលក្ខណៈសមធម៌ ត្រឹមត្រូវ ដើម្បីទទួលបានបុគ្គលិកមានសមត្ថភាពស័ក្តិសមតាមតម្រូវការ។ ដំណើរការនេះ ធានាអោយបេក្ខជនទទួលបាននូវបទពិសោធន៏ល្អតាមរយៈការជ្រើសរើសនេះ ហើយធនាគារត្រូវបានទទួលស្គាល់ជាវិជ្ជមាន តាមរយៈប្រតិបត្តិការងារដែលមានការគ្រប់គ្រងល្អក្នុងការរជ្រើសរើសបុគ្គលិកប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ។

ការបណ្តុះបណ្តាល និងបង្កើនសមត្ថភាពសម្រាប់ការរីកចម្រើន

កម្មវិធីបណ្តុះបណ្តាល និងអភិវឌ្ឍន៍ជាបន្តបន្ទាប់របស់ធនាគារ ត្រូវបានបង្កើតឡើងដើម្បីផ្តល់ចំណេះដឹង និងជំនាញចាំបាច់ទាក់ទងនឹងការងារប្រចាំថ្ងៃដល់បុគ្គលិក ដែលជាកត្តាមួយនៃការប្តេជ្ញាចិត្តរបស់ធនាគារក្នុងការផ្តល់នូវវេទិកា និងកម្មវិធីដ៏ល្អបំផុតសម្រាប់ភាពជោគជ័យ និងការរីកចម្រើនជានិរន្ត។

នៅឆ្នាំ2023 ធនាគារបានរៀបចំវគ្គបណ្តុះបណ្តាលទាំងក្នុង និង ក្រៅ ដើម្បីពង្រឹងការអភិវឌ្ឍន៍ទេពកោសល្យ និងបង្កើនវប្បធម៌បណ្តុះបណ្តាលបន្តនៅក្នុងធនាគារផងដែរ។ ជាលទ្ធផល បុគ្គលិកម្នាក់ៗបានសិក្សាជាមួយប្រធានបទសំខាន់ៗជាមធ្យម 15ម៉ោងក្នុង1ឆ្នាំ ទាំងក្នុងថ្នាក់ និង តាមអេឡិចត្រូនិក/សិក្សាពីចំងាយ។

បន្ថែមពីលើការទទួលបានវគ្គបណ្តុះបណ្តាល បុគ្គលិកក៏មានឱកាសចូលរួមសិក្ខាសាលា កិច្ចប្រជុំ និងវគ្គបណ្តុះបណ្តាលជាច្រើនជាមួយនិយ័តករ ដៃគូសហការី ដើម្បីទទួលព័ត៌មានអំពីច្បាប់ និងបទប្បញ្ញត្តិថ្មីៗ។

ការផ្តល់រង្វាន់ និងការទទួលស្គាល់ស្នាដៃបុគ្គលិក

ស្របតាមយុទ្ធសាស្ត្រធនាគារបានរៀបចំអត្ថប្រយោជន៍សម្រាប់ផ្តល់ដល់បុគ្គលិក ដែលរួមមានប្រាក់បៀវត្សរ៍ ឬប្រាក់ឈ្នួល ហើយរួមបញ្ចូលប្រាក់ឧបត្ថម្ភអត្ថប្រយោជន៍ ប្រាក់រង្វាន់ ការលើកទឹកចិត្តជាសាច់ប្រាក់ និងមិនមែនសាច់ប្រាក់ សមរម្យនិងស្របតាមទីផ្សារប្រកួតប្រជែងសម្រាប់បុគ្គលិក។

យើងក៏មានកម្មវិធីសម្រាប់ លើកទឹកចិត្ត និងការទទួលស្គាល់ស្នាដៃនៅកន្លែងការងារ ដែលជួយលើកកម្ពស់ការវិវត្តន៍ អភិវឌ្ឍន៍ និងជោគជ័យនៅក្នុងធនាគារ។ នៅពេលដែលសមិទ្ធផលស្នាដៃរបស់បុគ្គលិកត្រូវបានទទួលស្គាល់ ពួកគេទំនងជាត្រូវបានលើកទឹកចិត្តឱ្យបន្តការងារល្អរបស់ពួកគេ និងបំពេញតាមគោលដៅ ឬលើសពីគោលដៅដើម្បីឱ្យធនាគារអាចឈានទៅមុខបាន និងរីកចម្រើនជានិរន្ត។

ការរីកចម្រើន និងសមិទ្ធផល

6.1 ព័ត៌មានហិរញ្ញវត្ថុសង្ខេប

	ឆ្នាំហិរញ្ញវត្ថុ 2023	ឆ្នាំហិរញ្ញវត្ថុ 2022
លទ្ធផលប្រតិបត្តិការ (០០០ ដុល្លារអាមេរិក)		
ចំណូលប្រតិបត្តិការ	**15,460**	15,526
ចំណេញ / (ខាត) មុនបង់ពន្ធ	**1,240**	484
ចំណេញ / (ខាត) សុទ្ធសម្រាប់ឆ្នាំ	**1,113**	95
ទិន្នន័យតារាងតុល្យការគន្លឹះ (០០០ ដុល្លារអាមេរិក)		
ទ្រព្យសកម្មសរុប	**521,601**	330,244
ឥណទាន និងបុរេប្រទានដល់អតិថិជន	**169,279**	117,190
ទ្រព្យអសកម្មសរុប	**444,135**	253,890
ប្រាក់បញ្ញើរបស់ធនាគារ និងអតិថិជន	**435,115**	250,099
មូលធនភាគទុនិក	**75,000**	75,000
ទ្រព្យម្ចាស់របស់ភាគទុនិក	**77,466**	76,353
អនុបាតហិរញ្ញវត្ថុ (%)		
ផលលើទ្រព្យសកម្ម (ROA)	**0.21%**	0.03%
ផលលើមូលធន (ROE)	**1.44%**	0.12%
អនុបាតសាច់ប្រាក់ងាយស្រួល	**256%**	259%
អនុបាតឥណទានធៀបនឹងប្រាក់បញ្ញើ	**67%**	54%
អនុបាតឥណទានមិនដំណើរការធៀបនឹងឥណទានសរុប	**1.02%**	6.58%
ការគ្រប់គ្រងទុន		
មូលនិធិផ្ទាល់សុទ្ធ (០០០ ដុល្លារអាមេរិក)	**75,766**	75,199
អនុបាតសោធនភាព (%)	**32%**	34%

6.2 សកម្មភាពអាជីវកម្ម

លោក ហុង សុខឡេង ត្រូវបានតែងតាំងជាអគ្គនាយកថ្មីនៃធនាគារ ប៊ីអាយស៊ី

នៅថ្ងៃទី15 ខែមីនា ឆ្នាំ2023 ដោយមានភាពជឿជាក់ និងទំនុកចិត្តពីក្រុមប្រឹក្សាភិបាលនៃធនាគារ ប៊ីអាយស៊ី ដែលជាធនាគារពាណិជ្ជឈានមុខគេមួយបានប្រកាសតែងតាំង លោក ហុង សុខឡេង ជាអគ្គនាយកថ្មីនៃធនាគារ។

ដោយផ្តោតលើអាទិភាពយុទ្ធសាស្ត្រស្នូលរបស់ធនាគារ ក៏ដូចជាធនាគារសាជីវកម្ម ភាពជាដៃគូអន្តរជាតិ និងការធ្វើអាជីវកម្មធនាគារតាមបែបឌីជីថល លោក សុខឡេង ដឹកនាំយុទ្ធសាស្ត្រអភិវឌ្ឍន៍ជឿនលឿនរបស់ធនាគារ ប៊ីអាយស៊ី នៅក្នុងប្រទេសកម្ពុជា ដោយផ្តល់សេវាកម្មអតិថិជនឈានមុខ និងជំរុញប្រតិបត្តិការហិរញ្ញវត្ថុដែលឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តរបស់ធនាគារចំពោះអតិថិជនដែលកំពុងតែមានការរីកចម្រើនដ៏គួរឲ្យកត់សម្គាល់។ ការជ្រើសរើសរបស់លោក សុខឡេង ដើម្បីដឹកនាំយុទ្ធសាស្ត្រកំណើន និងពង្រីករបស់ធនាគារ ប៊ីអាយស៊ី គឺស្របតាមអាទិភាពរបស់ខ្លួន ដើម្បីបម្រើអតិថិជនជាមួយនឹងស្តង់ដាប្រកបដោយគុណភាព និងផ្តល់ឱ្យម្ចាស់ភាគហ៊ុនអតិថិជន និងបុគ្គលិក និងដៃគូរបស់ធនាគារ ប៊ីអាយស៊ី នូវទំនុកចិត្តលើឱកាសនាពេលអនាគត។

ប្រារព្ធពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ

ធនាគារ ប៊ីអាយស៊ី បានប្រារព្ធពិធីបុណ្យចូលឆ្នាំខ្មែរជាមួយនឹងពិធីជប់លៀងដ៏សប្បាយរីករាយប្រកបដោយភាតរភាព ដោយមានការចូលរួមពីគណៈគ្រប់គ្រង និងបុគ្គលិករបស់ធនាគារ ប៊ីអាយស៊ី ទាំងអស់។ កម្មវិធីដ៏រីករាយនេះក៏មានការចូលរួមពីអ្នកគ្រប់គ្រងពីក្រុមហ៊ុនបុត្រសម្ព័ន្ធជាច្រើនរបស់ BIC Group រួមមាន BIC Trust, BIC Insurance និង BIC Market។ ការប្រារព្ធពិធីនេះបានជំរុញឱ្យមានសាមគ្គីភាព និងភាពស្និទ្ធស្នាលក្នុងចំណោមក្រុម ដែលឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តរបស់យើងក្នុងការរក្សានូវវប្បធម៌សាជីវកម្មដ៏រឹងមាំ និងកិច្ចសហការ។ ការជួបជុំនេះបានផ្តល់ឱកាសដ៏ល្អសម្រាប់សមាជិកក្រុមនៅទូទាំងសាខា និងសាខាផ្សេងៗគ្នាដើម្បីភ្ជាប់ទំនាក់ទំនង ចែករំលែកបទពិសោធន៍ និងបង្កើតទំនាក់ទំនងការងារកាន់តែរឹងមាំ រួមចំណែកដល់ការរួមសហការគ្នា និងភាពជោគជ័យរបស់ BIC Group។

ពិធីចុះហត្ថលេខាលើអនុសារណៈយោគយល់គ្នារវាងធនាគារ B.I.C (Cambodia) Bank Plc. និង ក្រុមហ៊ុន KESS INNOVATION Plc.

ថ្ងៃទី7 ខែសីហា ឆ្នាំ2023 ធនាគារ B.I.C (Cambodia) Bank Plc. និង KESS INNOVATION Plc. បានចុះហត្ថលេខាលើអនុសារណៈយោគយល់គ្នាក្នុងការពង្រីកវិសាលភាពបច្ចេកវិទ្យាបែបឌីជីថល ដើម្បីផ្តល់ជូននូវបទពិសោធន៍ធនាគារ និងហិរញ្ញវត្ថុដ៏ទំនើប សុវត្ថិភាព និងប្រកដោយភាពច្នៃប្រឌិត។ កិច្ចសហប្រតិបត្តិការនេះ ជាលទ្ធផលនៃទស្សនវិស័យ និងការប្តេជ្ញាក្នុងការផ្តល់ជូននូវ ភាពកាន់តែងាយស្រួល និងសុវត្ថិភាពនៃសេវាធនាគារបែបឌីជីថល ព្រមទាំងភាពច្នៃប្រឌិត និងជំនាញនៃដំណោះស្រាយបច្ចេកវិទ្យា។

សិក្ខាសាលារៀបចំដោយធនាគារ ប៊ីអាយស៊ី

នៅថ្ងៃទី 26 និង 27 ខែសីហា ឆ្នាំ 2023 ធនាគារ ប៊ីអាយស៊ី បានរៀបចំសិក្ខាសាលា និង ការពង្រឹងទំនាក់ទំនងក្រុមការងារ សម្រាប់គណៈគ្រប់គ្រងនៃធនាគារ នៅក្រុងព្រះសីហនុ។ BIC Bank Transforming to be GREAT គឺជា ប្រធានបទយុទ្ធសាស្ត្រ គណៈគ្រប់គ្រង និងក្រុមការងារ ទទួលបានការពិភាក្សា ដ៏មានអត្ថន័យ ផែនការអនុវត្ត ការសហការជាក្រុម ប្រកបដោយភាតរភាព។ ពេញមួយព្រឹត្តិការណ៍នេះ យើងបានចូលរួមក្នុងការពិភាក្សាប្រកបដោយអត្ថន័យ បង្កើតផែនការសកម្មភាពដ៏ទូលំទូលាយ និងជំរុញកិច្ចសហការជាក្រុម។ បន្ថែមពីលើវគ្គប្រកបដោយផលិតភាព សហការីទាំងអស់ចូលរួមសកម្មភាពរីករាយជាច្រើនដែលពង្រឹងទំនាក់ទំនងក្រុមការងារ និងបង្កើនបទពិសោធន៍រួមគ្នា។

ធនាគារ BIC ដាក់សម្ពោធជាផ្លូវការ បណ្ណឥណទាន BIC Credit Mastercard សម្រាប់អតិថិជន

ធនាគារ ប៊ីអាយស៊ី ដាក់ដំណើរការ BIC CREDIT MASTERCARD ពង្រឹងតួនាទីរបស់ធនាគារជាអ្នកដឹកនាំនៅកម្ពុជាក្នុងវិស័យធនាគារឌីជីថល និងជម្រុញការទូទាត់ដោយមិនប្រើសាច់ប្រាក់

នៅខែតុលា ឆ្នាំ 2023 ធនាគារ ប៊ីអាយស៊ី ដែលជាធនាគារកំពុងមានភាពរីកចម្រើនយ៉ាងឆាប់រហ័ស លើវិស័យធនាគារឌីជីថលនៅក្នុងប្រទេសកម្ពុជា បានប្រកាសដាក់សម្ពោធជាផ្លូវការនូវ បណ្ណឥណទាន BIC Credit Mastrcard ដែលជាផលិតផលដ៏ថ្មីស្រឡាងមួយ និងផ្តល់ជូននូវជម្រើសនៃការទូទាត់ប្រាក់ដែលទំនើប សុវត្ថិភាព ងាយស្រួល ចំណាយមុនទើបបង់ប្រាក់តាមក្រោយ។ ព្រឹត្តិការណ៍ដាក់សម្ពោធជាផ្លូវការនេះ ត្រូវបានប្រារព្ធធ្វើឡើងនៅសណ្ឋាគារ Fairfield by Marriott Phnom Penh ដោយមានវត្តមានចូលរួមពីគណៈគ្រប់គ្រងរបស់ធនាគារ ប៊ីអាយស៊ី ក្រុមហ៊ុនMastercard ភ្ញៀវកិត្តិយស និងអតិថិជនផងដែរ។ បណ្ណឥណទាន BIC Credit Mastercard ផ្តល់ជូនជាជម្រើសបីប្រភេទ៖ Classic, Gold និង Platinum ដែលបណ្ណនីមួយៗមានលក្ខណៈពិសេស និងអត្ថប្រយោជន៍ផ្សេងៗគ្នា បន្ថែមនូវអាទិភាព ភាពងាយស្រួល ចំណាយមុនបង់សងតាមក្រោយប្រកបដោយសុវត្ថិភាព ដែលសាកសមនឹងតម្រូវការ និងចំណូលចិត្តនៃអតិថិជន។ បណ្ណឥណទាន BIC Credit Mastercard អនុញ្ញាតឱ្យអតិថិជនអាចរីករាយជាមួយនឹងបទពិសោធន៍ទូទាត់ប្រាក់បានយ៉ាងឆាប់រហ័ស ងាយស្រួល សុវត្ថិភាព ព្រមទាំងទទួលបានអត្ថប្រយោជន៍ត្រឡប់មកវិញជាច្រើនសន្ធឹកសន្ធាប់ មិនថាជាការទូទាត់តាមអនឡាញ ឬនៅតាមបណ្តាហាងជាដៃគូ គ្រប់ទីកន្លែងទូទាំងពិភពលោក។ ការដាក់សម្ពោធជាផ្លូវការនូវបណ្ណឥណទាន BIC Credit Mastercard នេះ គឺជាព្រឹត្តិការណ៍ដ៏អស្ចារ្យមួយសម្រាប់ធនាគារ ប៊ីអាយស៊ី ដែលឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តរបស់ធនាគារ ក្នុងការផ្តល់នូវផលិតផល និងសេវាកម្មប្រកបដោយភាពច្នៃប្រឌិត និងឆ្លើយតបតាមតម្រូវការទីផ្សារបែបឌីជីថល។

កំណើនគួរឱ្យកត់សម្គាល់ក្នុងរយៈពេល៥ ឆ្នាំចុងក្រោយនេះ ក៏ដោយសារតែការអនុវត្តយុទ្ធសាស្ត្រឌីជីថលរូបនីយកម្មរបស់ខ្លួន ក៏ដូចជាការទទួលបាននូវជំនឿទុកចិត្ត និងការគាំទ្រពីភាគទុនិក គណៈគ្រប់គ្រង ភាគីពាក់ព័ន្ធ និងអតិថិជនផងដែរ។ លើសពីនេះទៅទៀត ធនាគារ ប៊ីអាយស៊ី ក៏បានដាក់ដំណើរការរួចជាស្រេចទៅហើយ នូវបណ្ណឥណពន្ធ BIC Debit Mastercard បណ្ណនិមិត្ត BIC Virtual Mastercard ព្រមទាំងកម្មវិធី BIC Mobile app ដែលអតិថិជនអាចធ្វើប្រតិបត្តិការហិរញ្ញវត្ថុដូចជា ការទូទាត់តាម KHQR ការផ្ទេរប្រាក់ទៅកាន់ធនាគារផ្សេងៗក្នុងស្រុកតាមរយៈបាគងដោយឥតគិតថ្លៃសេវា ការទូទាត់ថ្លៃសេវាសាធារណៈយ៉ាងច្រើន ក៏ដូចជាការទិញទំនិញ online ជាដើម។ អ្វីដែលកាន់តែពិសេសនោះគឺ អតិថិជនអាចបើកគណនី BIC Digital Account តាមរយៈកម្មវិធី BIC Mobile app បានគ្រប់ពេលវេលា និងគ្រប់ទីកន្លែងផងដែរ។

ដើម្បីអបអរសាទរការដាក់សម្ពោធជាផ្លូវការនេះ ធនាគារ ប៊ីអាយស៊ី នឹងផ្តល់ជូននូវកម្មវិធីប្រូម៉ូសិនដ៏អស្ចារ្យ សម្រាប់អ្នកប្រើប្រាស់បណ្ណឥណទាន BIC Credit Mastercard។ អតិថិជននឹងទទួលបានសាច់ប្រាក់ត្រឡប់មកវិញ 20% លើប្រតិបត្តិការទូទាត់ទូទាំងពិភពលោក។ លើសពីនេះទៅទៀត អតិថិជនក៏នឹងមានឱកាសឈ្នះរង្វាន់ដ៏អស្ចារ្យជាច្រើនដូចជា៖

- រថយន្ត Ford Ranger ថ្មីស្រឡាង
- កញ្ចប់ដំណើរកម្សាន្តទៅកាន់ទ្វីបអឺរ៉ុប ប្រទេសឌូបៃ និងប្រទេសសិង្ហបុរី
- ទូរស័ព្ទ iPhone 15 Pro Max ថ្មីស្រឡាង
- កង់ Giant
- មិនគិតថ្លៃសេវាប្រចាំឆ្នាំលើបណ្ណឥណទាន BIC Credit Mastercard Platinum ពេញមួយជីវិត

6.3 សកម្មភាពផ្នែកទីផ្សារ និងទំនាក់ទំនងសាធារណៈ

កម្មវិធីធនាគារតាមទូរស័ព្ទ ប៊ីអាយស៊ី MOBILE



ក្នុងនាមជាធនាគារពាណិជ្ជ ធនាគារ ប៊ីអាយស៊ី ផ្តល់អាទិភាពក្នុងនវានុវត្តន៍បែបឌីជីថល។ យើងបានធ្វើទំនើបកម្មបច្ចេកវិទ្យារបស់យើងយ៉ាងខ្លាំងជាពិសេសនៅក្នុងសេវាធនាគារតាមទូរស័ព្ទជាមួយនឹងកម្មវិធីធនាគារតាមទូរស័ព្ទ BIC Mobile ជំនាន់ 3.0។ ជំនាន់ថ្មីនេះត្រូវបានបង្កើតឡើងដោយមានការខិតខំប្រឹងប្រែងយ៉ាងទូលំទូលាយ និងផ្តោតលើបទពិសោធន៍អ្នកប្រើប្រាស់ (UX/UI) ត្រូវបានដាក់ឱ្យដំណើរការដោយជោគជ័យ។

ដើម្បីធានាបាននូវបទពិសោធន៍អ្នកប្រើប្រាស់ដ៏រលូន យើងបានធ្វើតេស្តសាកល្បងក្នុងចំណោមបុគ្គលិក មុនពេលដាក់ដំណើរការជាផ្លូវការ។ ក្នុងដំណាក់កាលតេស្តសាកល្បងនេះ និងការបើកដំណើរសាកល្បង យើងបានវិភាគយ៉ាងល្អិតល្អន់អំពីការអនុវត្ត និងប្រមូលនូវមតិកែលម្អដ៏មានតម្លៃសម្រាប់ការកែលម្អបន្ថែមទៀត។ ដោយផ្អែកលើវឌ្ឍនភាពនេះ យើងមានទំនុកចិត្តលើសមត្ថភាពរបស់យើងក្នុងការបន្តដំណើរការ Go Live ជាផ្លូវការនៅថ្ងៃទី 21 ខែធ្នូ ឆ្នាំ 2023។ ក្រុមការងារផ្នែកព័ត៌មានវិទ្យាបានខិតខំប្រឹងប្រែងយ៉ាងមុតមាំ ដើម្បីអនុវត្តជំហានចាំបាច់សម្រាប់ការចាប់ផ្តើមដោយជោគជ័យ។

លក្ខណៈពិសេសៗជាច្រើនដូចជានៅក្នុងជំនាន់ 3.1.0 នៃ កម្មវិធីធនាគារតាមទូរស័ព្ទ BIC Mobile យើងបានណែនាំ និងធ្វើឲ្យប្រសើរឡើងនូវមុខងារថ្មីៗជាច្រើន រួមទាំង៖

- ការបើក "គណនីសន្សំបន្ថែម"
- មុខងារ "ផ្ទេរទៅគណនីផ្ទាល់ខ្លួន" កាន់តែប្រសើរឡើង
- ដំណើរការប្រសើរឡើងមុខងារ "Scan KHQR"
- បច្ចុប្បន្នភាព "e-KYC"
- ការកែកំហុសផ្សេងៗ និងការកែលម្អដំណើរការទាំងមូល

ការបើកគណនីឌីជីថល ប៊ីអាយស៊ី

មុខងារបើកគណនីឌីជីថលតាមរយៈកម្មវិធីតាមទូរស័ព្ទ BIC Mobile ផ្តល់នូវដំណោះស្រាយយ៉ាងរលូនសម្រាប់អតិថិជនក្នុងការបើកគណនីធនាគារគ្រប់ពេលវេលា និងគ្រប់ទីកន្លែង ដោយគ្រាន់តែមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ស្មាតហ្វូន (Smartphone) និងអ៊ីនធឺណិតដែលមានសុពលភាព។ ការប្រើប្រាស់បច្ចេកវិទ្យា e-KYC កម្រិតខ្ពស់ រួមទាំង AI និងមុខងារសម្គាល់លើផ្ទៃមុខ អតិថិជនអាចបើកគណនីឌីជីថលយ៉ាងងាយស្រួលតាមរយៈកម្មវិធីតាមទូរស័ព្ទ BIC Mobile។ មុខងារនេះអនុញ្ញាតឱ្យអតិថិជនអាចប្រើប្រាស់សេវាធនាគារឌីជីថលជាមួយនឹងទឹកប្រាក់ដែលអាចទូទាត់ប្រចាំថ្ងៃអតិបរមាចំនួន 5,000 ដុល្លារ (2,000,000 រៀល) និងដែនកំណត់ប្រចាំខែចំនួន 50,000 ដុល្លារ (200,000,000 រៀល)។ តាមរយៈការធ្វើតាមជំហានងាយៗ ដូចជាការបញ្ជូនឯកសារ e-KYC និងសម្គាល់ផ្ទៃមុខ អតិថិជនអាចទទួលបានគណនីជារូបិយប័ណ្ណចំនួនពីរ៖ ប្រាក់រៀល និងដុល្លារ។

ការទូទាត់ឆ្លងដែន៖ ថៃ QR

ក្នុងឆ្នាំ 2023 យើងបានដាក់ដំណើរដោយជោគជ័យនូវសេវាកម្មការទូទាត់ឆ្លងដែន ជាមួយនឹងការណែនាំនៃមុខងារ "Thai QR"។ តាមរយៈកិច្ចសហប្រតិបត្តិការជាមួយដៃគូយុទ្ធសាស្ត្រ និយតករ និងក្រុមការងារដ៏មោះមុតនិងខិតខំប្រឹងប្រែងរបស់យើង ធនាគារ ប៊ីអាយស៊ី បានសម្រួលដល់អតិថិជនដែលធ្វើដំណើរទៅកាន់ប្រទេសថៃ ដោយអាចឱ្យពួកគាត់ធ្វើការទូទាត់ប្រាក់ដោយផ្ទាល់ទៅកាន់ដៃគូជាង ៥ លានពាណិជ្ជករ ដោយគ្រាន់តែស្កេន ថៃ QR កូដ ពីគណនីប្រាក់រៀលនៅលើកម្មវិធី ធនាគារតាមទូរស័ព្ទ BIC Mobile។ មុខងារថ្មីនេះអនុញ្ញាឱ្យអតិថិជនធ្វើការទូទាត់តាមពេលវេលាជាក់ស្តែងសម្រាប់ទំនិញ និងសេវាកម្មតាមរយៈ QR របស់ប្រទេសថៃ ជាមួយនឹងទំហំទឹកប្រាក់អតិបរមារហូតដល់ 10 លានរៀល ក្នុងមួយប្រតិបត្តិការ និងទំហំទឹកប្រាក់អតិបរមារហូតដល់ 10 លានរៀល ក្នុងមួយថ្ងៃ។

ធនាគារ ប៊ីអាយស៊ី ចូលរួមទិវារត់ប្រណាំងអន្តរជាតិពាក់កណ្តាលម៉ារ៉ាតុង លើកទី 28 នៅអង្គរវត្ត

យើងមានមោទនភាពដែលធនាគារ ប៊ីអាយស៊ី បានចូលរួមក្នុងទិវារត់ប្រណាំងពាក់កណ្តាលម៉ារ៉ាតុងអន្តរជាតិលើកទី 28 អង្គរវត្ត កាលពីធ្នូ ឆ្នាំ 2023 នៅខេត្តសៀមរាប។ ថ្នាក់ដឹកនាំ និងបុគ្គលិករបស់ធនាគារបានចូលរួមយ៉ាងសកម្មក្នុងព្រឹត្តិការណ៍នេះ ដើម្បីជាការចូលរួមចំណែកសង្គម ក្នុងការគាំទ្រការសង្គ្រោះជនរងគ្រោះដោយសារគ្រាប់មីននៅកម្ពុជា និងជួយដល់កុមារក្រីក្រនៅមន្ទីរពេទ្យកុមារអង្គរ និងមន្ទីរពេទ្យគន្ធបុប្ផាជាដើម។

ធនាគារ ប៊ីអាយស៊ី ប្តេជ្ញាក្នុងការកសាងទំនាក់ទំនងរឹងមាំគមន៍ និងលើកកម្ពស់និរន្តរភាព។ កម្មវិធីផ្សព្វផ្សាយសហគមន៍របស់យើងផ្តោតលើការអប់រំ ការផ្តល់ជំនួយដល់សហគមន៍ដែលខ្វះខាត និងគាំទ្រអ្នកដែលមានទេពកោសល្យក្នុងមូលដ្ឋាន។ យើងលើកទឹកចិត្តដល់ការចូលរួមរបស់បុគ្គលិកក្នុងការស្ម័គ្រចិត្ត និងធានាបានថាប្រតិបត្តិការរបស់យើងនឹងមិនប៉ះពាល់ដល់បរិស្ថាន។

ក្នុងរយៈពេល 4 ឆ្នាំកន្លងមកនេះ យើងបានបង្កើនការយកចិត្តទុកដាក់របស់យើងទៅលើទំនួលខុសត្រូវសង្គម (CSR) ដោយរួមបញ្ចូលនូវការអនុវត្តប្រកបដោយនិរន្តរភាព ដើម្បីបំពេញតាមបទប្បញ្ញត្តិកាន់តែតឹងរ៉ឹង បំពេញតម្រូវការអតិថិជនយ៉ាងវៃឆ្លាត និងភាពរីកចម្រើនដ៏ឿនលឿនក្នុងវិស័យធនាគារបែបឌីជីថល។

6.4 សមិទ្ធិផលសំខាន់ៗ

ការដាក់ដំណើរការបើកសាខាធនាគារ ប៊ីអាយស៊ី សាខាពោធិ៍ចិនតុង

ធនាគារ ប៊ីអាយស៊ី បានបើកសម្ពោធសាខាប្រតិបត្តិការទីប្រាំ (សាខាពោធិ៍ចិនតុង) ដែលមានទីតាំងស្ថិតនៅតាមបណ្តោយមហាវិថីសហព័ន្ធរុស្សី។

ការបង្កើតសាខាពោធិ៍ចិនតុងជាការបោះជំហានឆ្ពោះទៅមុខយ៉ាងសំខាន់ក្នុងកិច្ចខិតខំប្រឹងប្រែងពង្រីកវិសាលភាពបណ្តាញសាខាធនាគារ ប៊ីអាយស៊ី ដែលបង្ហាញពីការប្តេជ្ញាចិត្តរបស់ថ្នាក់ដឹកនាំធនាគារក្នុងការលើកកម្ពស់ភាពងាយស្រួល និងបម្រើតម្រូវការរបស់អតិថិជនប្រកបដោយប្រសិទ្ធភាព។

ស្ថិតនៅទីតាំងប្រកបដោយផាកសុកភាព និងភាពងាយស្រួលទទួលយកសេវាកម្ម សាខាពោធិ៍ចិនតុង អាចផ្តល់នូវសេវាធនាគារយ៉ាងទូលំទូលាយដល់បុគ្គល អាជីវកម្ម និងសហគមន៍ក្នុងតំបន់ជុំវិញ។ គោលបំណងរបស់យើង គឺផ្តល់ជូននូវដំណោះស្រាយហិរញ្ញវត្ថុដែលសមស្រប និងសេវាកម្មអតិថិជនពិសេស ដើម្បីផ្តល់សិទ្ធិអាទិភាពដល់អតិថិជនរបស់យើង និងរួមចំណែកដល់កំណើនសេដ្ឋកិច្ចក្នុងស្រុក។

ការដាក់ដំណើរការសាខាពោធិ៍ចិនតុង បង្ហាញពីការយកចិត្តទុកដាក់របស់ធនាគារ ធនាគារក្នុងការច្នៃប្រឌិត និងឧត្តមភាពក្នុងសេវាកម្មធនាគារ។ យើងមានសេចក្តីរំភើបរីករាយក្នុងការស្វាគមន៍អតិថិជនមកកាន់សាខាថ្មីបំផុតរបស់យើង និងដើម្បីបន្តផ្តល់នូវតម្លៃដល់សហគមន៍ដែលយើងបម្រើ។

វិញ្ញាបនបត្រអនុលោមភាពសារពើពន្ធប្រភេទ "មាស"

ធនាគារ ប៊ីអាយស៊ី មានមោទនភាព និងរីករាយក្នុងការទទួលបាននូវវិញ្ញាបនបត្រអនុលោមភាពសារពើពន្ធពីអគ្គនាយកដ្ឋានពន្ធដារ ដែលមានកម្រិតប្រភេទ "មាស"។

កម្រិតអនុលោមភាពសារពើពន្ធប្រភេទមាសនេះ គឺជាសមិទ្ធិផលដ៏សំខាន់មួយសម្រាប់ធនាគារ ប៊ីអាយស៊ី ដែលឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តរបស់យើងក្នុងការរក្សាបាននូវស្តង់ដារខ្ពស់បំផុតនៃសុចរិតភាពហិរញ្ញវត្ថុ និងការប្រកាន់ខ្ជាប់បទប្បញ្ញត្តិ។

អគ្គនាយកដ្ឋានពន្ធដារបានធ្វើការពិនិត្យ និងវាយតម្លៃយ៉ាងហ្មត់ចត់លើកាតព្វកិច្ចពន្ធរបស់ធនាគារ ប៊ីអាយស៊ី ដោយពិនិត្យលើឯកសារយោងនិងសារៈតារនៃការអនុវត្តកាតព្វកិច្ចសារពើពន្ធរបស់ធនាគារ ។ កម្រិតអនុលោមភាពសារពើពន្ធប្រភេទមាសនេះគឺជាសក្ខីភាពមួយចំពោះតម្លាភាព ភាពត្រឹមត្រូវ និងភាពទៀងទាត់នៃការបំពេញកាតព្វកិច្ចពន្ធដាររបស់យើងចំពោះរាជរដ្ឋាភិបាលកម្ពុជា។ ការទទួលស្គាល់នេះមិនត្រឹមតែឆ្លុះបញ្ចាំងពីការយកចិត្តទុកដាក់របស់យើងចំពោះការអនុវត្តពន្ធគំរូប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងពង្រឹងទំនុកចិត្ត និងភាពជឿជាក់ដែលអតិថិជន និងសាធារណជនរបស់យើងមានចំពោះធនាគារ ប៊ីអាយស៊ី ផងដែរ។

ការទទួលបានវិញ្ញាបនបត្រនេះបញ្ជាក់ពីការប្តេជ្ញាចិត្តបន្តរបស់យើងចំពោះឧត្តមភាពនៃប្រតិបត្តិការ និងការទទួលខុសត្រូវសារពើពន្ធ។ វាបង្ហាញពីតួនាទីរបស់យើងជាពលរដ្ឋសាជីវកម្មដែលអាចទុកចិត្តបាន និងមានទំនួលខុសត្រូវ រួមចំណែកជាវិជ្ជមានដល់សេដ្ឋកិច្ចជាតិ។ យើងមានកិត្តិយសចំពោះការទទួលស្គាល់នេះ ហើយនៅតែបន្តខិតខំយ៉ាងខ្ជាប់ខ្ជួនដើម្បីលើកកម្ពស់ស្តង់ដាទាំងនេះនាពេលអនាគត។

ពានរង្វាន់ភាពជាអ្នកដឹកនាំពី MASTERCARD

ធនាគារ ប៊ីអាយស៊ី មានសេចក្តីរីករាយដែលទទួលបានពានចំនួន 2 ពីម៉ាស្ទ័រកាត ក្នុងឆ្នាំ 2023 ដោយទទួលស្គាល់សមិទ្ធិផលដ៏គួរឲ្យកត់សម្គាល់ក្នុងឆ្នាំនេះ។

1. ពានរង្វាន់ជាស្ថាប័នដែលមានកំណើនខ្ពស់សម្រាប់បណ្ណឥណទាន: ពានរង្វាន់នេះទទួលស្គាល់នូវការអនុវត្តដ៏ពិសេសរបស់ធនាគារ ប៊ីអាយស៊ី ក្នុងទំហំឥណទាន ដែលឆ្លុះបញ្ចាំងពីការយកចិត្តទុកដាក់របស់យើងក្នុងការផ្តល់សេវាឥណទានដែលអាចប្រើប្រាស់បាន និងប្រកួតប្រជែងដល់អតិថិជនរបស់យើង។ នេះជាសក្ខីភាពបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់យើងក្នុងការសម្របសម្រួលការដាក់បញ្ចូលផ្នែកហិរញ្ញវត្ថុ និងការផ្តល់សិទ្ធិដល់អតិថិជន និងអាជីវកម្មជាមួយនឹងដំណោះស្រាយឥណទានដ៏ងាយស្រួលដែលស្របតាមតម្រូវការរបស់ពួកគេ។
2. ពានរង្វាន់ជាស្ថាប័នដែលមានការទូទាត់អន្តរជាតិច្រើនជាងគេ: ពានរង្វាន់នេះសំដៅដល់ភាពនាំមុខក្នុងការទូទាត់អន្តរជាតិ បង្ហាញពីឧត្តមភាពរបស់ធនាគារ ប៊ីអាយស៊ី ក្នុងការសម្របសម្រួលប្រតិបត្តិការអន្តរជាតិ។ សមិទ្ធិផលនេះបង្ហាញពីជំនាញរបស់យើងក្នុងសេវាកម្មហិរញ្ញវត្ថុអន្តរជាតិ និងសមត្ថភាពរបស់យើងក្នុងការរុករកប្រកបដោយប្រសិទ្ធភាពនូវភាពស្មុគស្មាញនៃពាណិជ្ជកម្មសកល។ នេះសបញ្ជាក់អំពីតួនាទីរបស់យើងជាដៃគូដែលអាចទុកចិត្តបានសម្រាប់អតិថិជនដែលចូលរួមក្នុងប្រតិបត្តិការឆ្លងដែន ដោយផ្តល់ជូននូវដំណោះស្រាយការទូទាត់ប្រកបដោយភាពរលូន និងគួរឱ្យទុកចិត្ត។

ការអបអរសាទរទាំងនេះពី Mastercard បម្រើជាសក្ខីភាពដល់ការប្តេជ្ញាចិត្តរបស់ធនាគារ ប៊ីអាយស៊ី ចំពោះឧត្តមភាព ភាពច្នៃប្រឌិត និងការពេញចិត្តពីសំណាកអតិថិជន។ ពាននេះពង្រឹងជំហររបស់យើងកាន់តែរឹងមាំក្នុងភាពជាធនាគារឈានមុខមួយក្នុងឧស្សាហកម្មធនាគារ និងជំរុញយើងឱ្យបន្តផ្តល់សេវាកម្មហិរញ្ញវត្ថុពិសេស និងជំរុញឱ្យមានលទ្ធផលជាវិជ្ជមាននៅក្នុងសហគមន៍។

7 អភិបាលកិច្ចសាជីវកម្ម

ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលរបស់ធនាគារ ប៊ីអាយស៊ី ត្រូវបានតែងតាំងដោយភាគហ៊ុនិក ។ ក្រុមប្រឹក្សាភិបាលត្រូវពិនិត្យ រចនាសម្ព័ន្ធ ទំហំ និងសមាសភាពក្រុមប្រឹក្សាភិបាល និងអនុគណៈកម្មការរបស់ខ្លួនឡើងវិញនិងជាប្រចាំ ហើយធ្វើការផ្តល់អនុសាសន៍ និងរាយការណ៍ជូនភាគហ៊ុនិកសម្រាប់ការផ្លាស់ប្តូរណាមួយដែលចាត់ទុកថាចាំបាច់ ហើយការផ្លាស់ប្តូរនេះត្រូវតែស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមានរបស់រាជរដ្ឋាភិបាលកម្ពុជា។ ក្រុមប្រឹក្សាភិបាលមានទំនួលខុសត្រូវក្នុងការត្រួតពិនិត្យ ការគ្រប់គ្រងទូទៅនិងកិច្ចការងាររបស់ធនាគារ សម្រាប់ការអនុវត្តអោយត្រឹមត្រូវស្របតាមក្រមប្រតិបត្តិសម្រាប់វិស័យធនាគារ និងហិរញ្ញវត្ថុ។ ទំនួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលយ៉ាងតិចបំផុតមានដូចខាងក្រោម ៖

- ការអនុម័តគោលនយោបាយជាយុទ្ធសាស្ត្រ និងផែនការអាជីវកម្ម
- ការអនុម័តគម្រោងថវិកាប្រចាំឆ្នាំ របាយការណ៍ហិរញ្ញវត្ថុ និងផែនការវិនិយោគប្រចាំឆ្នាំ
- ពិនិត្យ និងអនុម័តសំណើររបស់ប្រធាននាយកប្រតិបត្តិលើរចនាសម្ព័ន្ធធនាគារ បទបញ្ជាផ្ទៃក្នុង គោលនយោបាយបុគ្គលិក កិច្ចសន្យាជាមួយអ្នកផ្គត់ផ្គង់ផ្សេងៗ
- ស្នើរវិសោធនកម្មលក្ខន្តិកៈក្រុមហ៊ុន
- ការអនុម័តថវិកាប្រតិបត្តិការប្រចាំឆ្នាំរបស់ធនាគារ និងធានាថាប្រតិបត្តិការត្រូវបានធ្វើឡើងដោយប្រុងប្រយ័ត្នស្របតាមច្បាប់និងបទប្បញ្ញត្តិ និងគោលនយោបាយរបស់ធនាគារ
- ត្រួតពិនិត្យការគ្រប់គ្រង និងកិច្ចការរបស់ធនាគារ ដើម្បីធានាបាននូវការគ្រប់គ្រងប្រកបដោយត្រឹមត្រូវ ពេញលេញ និងប្រុងប្រយ័ត្នការអនុលោមតាមកាតព្វកិច្ចច្បាប់និងបទប្បញ្ញត្តិ ប្រសិទ្ធភាពនៃគោលនយោបាយ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ការត្រួតពិនិត្យនិងវាយតម្លៃឱ្យបានគ្រប់គ្រាន់ និងគ្រប់ជ្រុងជ្រោយនៃហានិភ័យ ការត្រួតពិនិត្យការអនុវត្តជាប្រចាំ និងធានាបាននូវវិធានការកែតម្រូវ
- ការអនុម័តលើការពង្រីកសកម្មភាពរបស់ធនាគារទៅក្នុងអាជីវកម្មថ្មីនៅក្នុងតំបន់ភូមិសាស្ត្រនៃប្រទេសកម្ពុជា
- ការអនុម័តលើការសម្រេចចិត្តណាមួយដើម្បីបញ្ឈប់ប្រតិបត្តិការអាជីវកម្មរបស់ធនាគារនូវផ្នែកណាមួយ ឬទាំងអស់ជាសារវន្ត
- ការអនុម័តលើសំណើរការបែងចែកដើមទុន និងធនធានផ្សេងៗនៅក្នុងធនាគារ
- ការអនុម័តលើការកែប្រែសំខាន់ៗ លើគោលនយោបាយគណនេយ្យ ឬការអនុវត្ត
- រក្សាប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង និងការគ្រប់គ្រងហានិភ័យយ៉ាងត្រឹមត្រូវ និងប្រុងប្រយ័ត្ន។ ប្រធានក្រុមប្រឹក្សាភិបាលត្រូវបានតែងតាំងដោយភាគហ៊ុនិក ហើយក្នុងករណីអវត្តមានរបស់ប្រធានក្រុមប្រឹក្សាភិបាល អនុប្រធានក្រុមប្រឹក្សាភិបាលនឹងក្លាយជាប្រធានស្តីទីដោយស្វ័យប្រវត្តិ ហើយត្រូវបំពេញភារកិច្ចដូចគ្នានឹងប្រធានក្រុមប្រឹក្សាភិបាល។ សមាជិកក្រុមប្រឹក្សាភិបាល ត្រូវមានសមាជិកភាពយ៉ាងតិចចំនួន៥រូប ដែលក្នុងនោះសមាជិកភាពចំនួន២រូប ត្រូវជាអភិបាលឯករាជ្យ។ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលត្រូវតែធ្វើឡើងរៀងរាល់ត្រីមាស ប៉ុន្តែប្រធានក្រុមប្រឹក្សាភិបាលអាចកោះហៅឱ្យមានកិច្ចប្រជុំពិសេស តាមការស្នើសុំដោយសមាជិកក្រុមប្រឹក្សាភិបាលណាមួយ យ៉ាងហោចណាស់មានសមាជិកភាពចំនួន 50% ភាគរយ(ហាសិប)នៃសមាជិកក្រុមប្រឹក្សាភិបាលត្រូវតែមានវត្តមានសម្រាប់មួយកូរ៉ុម

គណៈកម្មាធិការសវនកម្ម

គណៈកម្មាធិការសវនកម្មត្រូវបានបង្កើតឡើង ជាតំណាងអោយក្រុមប្រឹក្សាភិបាល ដើម្បីត្រួតពិនិត្យលើការគ្រប់គ្រងហិរញ្ញវត្ថុរបស់ធនាគារ ដើម្បីកំណត់ និងវាយតម្លៃ ព្រមទាំងតាមដានហានិភ័យនានាលើការគ្រប់គ្រងហិរញ្ញវត្ថុ និងពិនិត្យលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារ។ សមាជិកនៃគណៈកម្មាធិការសវនកម្ម យ៉ាងហោចណាស់ត្រូវមានចំនួន ៣រូប ដែលជាសមាជិកភាពមកពីក្រុមប្រឹក្សាភិបាលរបស់ធនាគារ និងត្រូវបានចាត់តាំងដោយក្រុមប្រឹក្សាភិបាលសម្រាប់អាណត្តិ ៣ឆ្នាំ ហើយសមាជិកទាំងអស់នឹងត្រូវធ្វើការវាយតំលៃគុណវឌ្ឍន៍ ដើម្បីបន្តអាណត្តិជាថ្មីស្របតាមលក្ខខណ្ឌនៃសមាជិកភាពជាក្រុមប្រឹក្សាភិបាល។ បេក្ខភាពប្រធានគណៈកម្មាធិការសវនកម្ម គួរតែជាអភិបាលឯករាជ្យ។ មានតែសមាជិកគណៈកម្មាធិការ សវនកម្មប៉ុណ្ណោះដែលមានសិទ្ធិចូលរួមកិច្ចប្រជុំ ប៉ុន្តែអ្នកគ្រប់គ្រងជាន់ខ្ពស់ផ្សេងទៀតអាចមានសិទ្ធិចូលរួមកិច្ចប្រជុំនៅក្នុងមួយផ្នែកណាមួយ ឬកិច្ចប្រជុំទាំងមូល តាមការអញ្ជើញរបស់ប្រធានគណៈកម្មាធិការសវនកម្ម មានដូចជា ប្រធាននាយកប្រតិបត្តិ ប្រធាននាយកដ្ឋានហានិភ័យ នាយកសវនកម្មផ្ទៃក្នុង នាយកប្រតិបត្តិតាម នាយកហិរញ្ញវត្ថុ និងក្រុមហ៊ុនសវនកម្មឯករាជ្យដែលទទួលស្គាល់ពីធនាគារជាតិនៃកម្ពុជា។

គណៈកម្មាធិការហានិភ័យ និងអនុលោមភាព

គណៈកម្មាធិការហានិភ័យ និងអនុលោមភាពត្រូវបានបង្កើតឡើងដើម្បីផ្តល់ប្រឹក្សាដល់ក្រុមប្រឹក្សាភិបាលអំពីគ្រប់គ្រងហានិភ័យនាពេលបច្ចុប្បន្ន និងអនាគតរបស់ធនាគារ ត្រួតពិនិត្យការអនុវត្តក្របខ័ណ្ឌគ្រប់គ្រងហានិភ័យ និងរាយការណ៍អំពីស្ថានភាពនៃវប្បធម៌ហានិភ័យនៅក្នុងធនាគារ ។ ជាពិសេស ទំនួលខុសត្រូវរបស់គណៈកម្មាធិការហានិភ័យ និងអនុលោមភាព រួមបញ្ចូលទាំងការទទួល និងដោះស្រាយបណ្តឹងពីសំណាក់បុគ្គលិក និងធ្វើការស្វែងរកការក្លែងបន្លំនានានៅក្នុងធនាគារ ។ គណៈកម្មាធិការហានិភ័យ និងអនុលោមភាព នឹងពិនិត្យឡើងវិញនូវប្រសិទ្ធភាពនៃប្រព័ន្ធការងារនាពេលបច្ចុប្បន្ន អោយអនុលោមតាមច្បាប់ នីតិវិធីនានា ដើម្បីស្វែងរកការក្លែងបន្លំ សំដៅការទប់ស្កាត់ការស៊ីសំណូកនានា ដើម្បីពង្រឹងភាពពេញលេញ និងប្រសិទ្ធភាពនៃការប្រឆាំងនឹងការលាងសម្អាតប្រាក់ ។ ម៉្យាងវិញទៀត គណៈកម្មាធិការហានិភ័យ និងអនុលោមភាពក៏ត្រូវបានធានាថាអាចបំពេញការងារលើការស៊ើបអង្កេត និងដោះស្រាយ វិវាទ ព្រមទាំងរាយការណ៍អំពីលទ្ធផលដោយឯករាជ្យ មិនលំអៀង និងធ្វើការតាមដានលើការដោះស្រាយបញ្ហាដ៏សមស្របណាមួយរបស់គណៈគ្រប់គ្រងរបស់ធនាគារ ។

សមាជិកត្រូវមាននាយកយ៉ាងហោចណាស់ ៣រូប ដែលត្រូវបានចាត់តាំងដោយក្រុមប្រឹក្សាភិបាលសម្រាប់អាណត្តិ 3ឆ្នាំ ដែលត្រូវបន្តអាណត្តិជាថ្មីស្របតាមលក្ខខណ្ឌនៃការតែងតាំងជាក្រុមប្រឹក្សាភិបាល ។ សមាជិកម្នាក់ក្នុងចំណោមសមាជិកដែលត្រូវបានតែងតាំងដោយក្រុមប្រឹក្សាភិបាល និងអភិបាលឯករាជ្យដែលត្រូវកាន់តួនាទីជាគណៈកម្មាធិការហានិភ័យ និងអនុលោមតាម ។ សមាជិកនៃគណៈកម្មាធិការរួមត្រូវតែមានបទពិសោធន៍គ្រប់គ្រាន់ និងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការបំពេញភារកិច្ចរបស់ខ្លួន និងជាបុគ្គលដែលមានចរិតលក្ខណៈល្អ សេចក្ដីថ្លៃថ្នូរ និងមានសុចរិតភាព គួរជាទីគោរព។

គណៈកម្មាធិការផ្សេងទៀតរួមមាន:

- **គណៈកម្មាធិការប្រតិបត្តិ (EXCO)** មានទំនួលខុសត្រូវក្នុងការគ្រប់គ្រង និងត្រួតពិនិត្យគ្រប់ទិដ្ឋភាព និងមុខងារនានា ស្របតាមទម្រង់តួនាទី និងលក្ខខណ្ឌដែលបានចែងនិមួយៗ ។ ជាពិសេសគណៈកម្មាធិការប្រតិបត្តិ មានទំនួលខុសត្រូវរួមមាន ការបង្កើតយុទ្ធសាស្ត្រអាជីវកម្ម ត្រួតពិនិត្យ និងចាត់វិធានការសមស្របលើរបាយការណ៍ហិរញ្ញវត្ថុ ការគ្រប់គ្រងទ្រព្យសកម្ម និងបំណុលរបស់ធនាគារ ការបែងចែកដើមទុន និងការគ្រប់គ្រងហានិភ័យ ឱ្យស្របទៅតាមចក្ខុវិស័យរបស់ក្រុមប្រឹក្សាភិបាល។
- **គណកម្មាធិការទ្រព្យសកម្ម និងបំណុល (ALCO)** ទទួលខុសត្រូវក្នុងការផ្តល់នូវប្រព័ន្ធព័ត៌មាន គ្រប់គ្រងសំខាន់ៗ និងការត្រួតពិនិត្យសម្រាប់ការវាយតម្លៃហានិភ័យលើហិរញ្ញវត្ថុ ទាំងក្នុង និងក្រៅតារាងតុល្យការសម្រាប់ធនាគារ ។ គោលដៅរបស់គណកម្មាធិការទ្រព្យសកម្ម និងបំណុល គឺដើម្បីធានាចំពោះការគ្រប់គ្រងទ្រព្យសកម្មរបស់ធនាគារអោយមានភាពត្រឹមត្រូវ និងមានប្រសិទ្ធិភាព ដែលរួមមាន ចំណូលការប្រាក់ និងការចំណាយការប្រាក់ ។ ភារកិច្ចរបស់គណកម្មាធិការទ្រព្យសកម្ម និងបំណុល រួមបញ្ចូលទាំងការ ផ្នែកនៃការគ្រប់គ្រងហានិភ័យរតនាគារ ហានិភ័យអត្រាការប្រាក់ និងសកម្មភាពការពារហានិភ័យ ហានិភ័យឥណទានរតនាគារ និងការផ្តល់មូលនិធិ។
- **គណៈកម្មាធិការប្រតិបត្តិ (EXCO)** មានទំនួលខុសត្រូវក្នុងការគ្រប់គ្រង និងត្រួតពិនិត្យគ្រប់ទិដ្ឋភាព និងមុខងារនានា ស្របតាមទម្រង់តួនាទី និងលក្ខខណ្ឌដែលបានចែងនិមួយៗ ។ ជាពិសេសគណៈកម្មាធិការប្រតិបត្តិ មានទំនួលខុសត្រូវរួមមាន ការបង្កើតយុទ្ធសាស្ត្រអាជីវកម្ម ត្រួតពិនិត្យ និងចាត់វិធានការសមស្របលើរបាយការណ៍ហិរញ្ញវត្ថុ ការគ្រប់គ្រងទ្រព្យសកម្ម និងបំណុលរបស់ធនាគារ ការបែងចែកដើមទុន និងការគ្រប់គ្រងហានិភ័យ ឱ្យស្របទៅតាមចក្ខុវិស័យរបស់ក្រុមប្រឹក្សាភិបាល។
- **គណៈកម្មាធិការឥណទាន (CC)** ទទួលខុសត្រូវក្នុងការត្រួតពិនិត្យ ការផ្តល់ប្រាក់កម្ចី និងយុទ្ធសាស្ត្រឥណទានរបស់ធនាគារ រួមទាំងការពិនិត្យឡើងវិញនូវគោលនយោបាយឥណទាន និងការកំណត់ផលប័ត្រឥណទានរបស់ធនាគារ ។
- **គណៈកម្មាធិការលទ្ធកម្ម** ទទួលខុសត្រូវក្នុងការធានានូវតម្លាភាព និងភាពត្រឹមត្រូវក្នុងការទិញ ទំនិញ និង សេវាកម្មនានាសំរាប់ធនាគារ។ គោលបំណងចំបងក្នុងការសំរេចចិត្តរបស់គណៈកម្មាធិការនេះមិនផ្អែកលើតម្លៃទាបបំផុតនោះទេ ប៉ុន្តែការសំរេចចិត្តទិញទំនិញរបស់គណៈកម្មការគឺផ្អែកលើតម្លៃទីផ្សារ សមស្របនិងគុណភាពរបស់ទំនិញ អាយុកាលប្រើប្រាស់បានយូរ ដែលចំនេញដល់ការប្រើប្រាស់ ការដឹកជញ្ជូនទាន់ពេលវេលា មិនប៉ះពាល់ដល់បរិស្ថាន និងសង្គម និងមានការធានាត្រឹមត្រូវ និងស្របតាមច្បាប់ ។

គណៈគ្រប់គ្រងជាន់ខ្ពស់

នាយកដ្ឋានអាជីវកម្ម និងប្រតិបត្តិការ គឺជាខ្សែការពារអាជីវកម្មទីមួយ ដើម្បីធានាឱ្យប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង ដំណើរការដោយរលូន។

គណៈគ្រប់គ្រងឯករាជ្យផ្នែកហានិភ័យ និងអនុលោមភាព

ក្នុងនាមជានាយកដ្ឋានឯករាជ្យ ពួកគេមានតួរនាទីក្នុងការត្រួតពិនិត្យ និងតាមដានមើលប្រតិបត្តិអាជីវកម្មរបស់ធនាគារអោយអនុលោមតាមច្បាប់ និងរាយការណ៍ពីហានិភ័យនានានៅក្នុងធនាគារជាប្រចាំជូនគណៈគ្រប់គ្រងជាន់ខ្ពស់របស់ធនាគារ ។

នាយកដ្ឋានសវនកម្មផ្ទៃក្នុង

សវនករផ្ទៃក្នុង នឹងអនុវត្តន៍ការងារសវនកម្មជាប្រចាំដោយឯករាជ្យទៅតាមផែនការដែលបានកំណត់ទុក លើប្រសិទ្ធភាពនិងភាពរឹងមាំនៃដំណើរការ និងក្របខ័ណ្ឌគ្រប់គ្រងហានិភ័យពាក់ព័ន្ធរួមបញ្ចូលគ្នា ដើម្បីធ្វើអោយប្រសើរឡើង និងធានាប្រសិទ្ធភាពនៃការទទួលខុសត្រូវ និងការគ្រប់គ្រង ឬ ការអនុវត្តការងាររបស់ផ្នែកគាំទ្រអាជីវកម្មរបស់ធនាគារ។ សវនករផ្ទៃក្នុង ក៏ធ្វើការត្រួតពិនិត្យផងដែរជាប្រចាំលើប្រតិបត្តិការ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារ ព្រមទាំង ផ្តល់ការរៀបចំប្រព័ន្ធត្រួតពិនិត្យតម្លាភាពលើប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងការអនុលោមតាមបទប្បញ្ញត្តិពាក់ព័ន្ធរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។

លទ្ធផលនៃការធ្វើសវនកម្ម នាំមកនូវនិងរួមបញ្ចូលនូវអនុសាសន៍ផ្អែកលើហានិភ័យ និងទស្សនៈអនាគត និងផ្តល់អនុសាន៍ជូនគណៈគ្រប់គ្រងស្តីពីវិធានការកែតម្រូវចាំបាច់ និងការអនុវត្ត។ របាយការណ៍សវនកម្មផ្ទៃក្នុងត្រូវផ្ញើជូនក្រុមប្រឹក្សាភិបាល តាមរយៈគណៈកម្មាធិការសវនកម្ម។

ការរៀបចំប្រព័ន្ធត្រួតពិនិត្យតម្លាភាព

ធនាគារ ប៊ីអាយស៊ី មានការបែងចែកមុខងារភារកិច្ចដើម្បីធានាអោយមានការសម្រេចចិត្តដោយឯករាជ្យ និងការត្រួតពិនិត្យលើភាពត្រឹមត្រូវ និងគុណភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។ ផ្នែកគាំទ្រអាជីវកម្មរបស់ធនាគារ ត្រូវមាន និងរក្សានូវទំនួលខុសត្រូវផ្សេងៗគ្នា ហើយមិនអាចមានឥទ្ធិពលលើគ្នាទៅវិញទៅមក ដើម្បីជៀសវាងការប្រមូលផ្តុំអំណាច កាត់បន្ថយកំហុស និងការពារមិនអោយមានអាកប្បកិរិយាមិនសមរម្យ និងការប្រព្រឹត្តិមិនត្រឹមត្រូវ។

របាយការណ៍ ហិរញ្ញវត្ថុ

សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែធ្នូ ឆ្នាំ2023
និងរបាយការណ៍របស់សវនករឯករាជ្យ





ព័ត៌មានអំពីធនាគារ

ធនាគារ៖	ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក
ចុះបញ្ជីពាណិជ្ជកម្មលេខ៖	00029200
ទីស្នាក់ការការចុះបញ្ជី៖	អគារលេខ 462 ជាន់ផ្ទាល់ដី និងជាន់ទី1 មហាវិថីព្រះមុនីវង្ស (ផ្លូវលេខ 93) ភូមិ 13 សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ភាគទុនិក៖	Apsara Holdings Pte. Ltd. (ចាប់ពីថ្ងៃទី28 ខែកក្កដា ឆ្នាំ2023) Asia Investment and Financial Services Sole Co.,Ltd. (រហូតដល់ថ្ងៃទី28 ខែកក្កដា ឆ្នាំ2023) លោក យឹម លក្ខណ៍

ក្រុមប្រឹក្សាភិបាល៖	លោក យឹម លក្ខណ៍	ប្រធានក្រុមប្រឹក្សាភិបាល
	លោក John Edward Mc Cosh	អភិបាលឯករាជ្យ
	លោក យា សារឿន	អភិបាល (តែងតាំងនៅថ្ងៃទី13 ខែមីនា ឆ្នាំ2023)
	លោក តេ វុទ្ធី	អភិបាលឯករាជ្យ (តែងតាំងនៅថ្ងៃទី13 ខែមីនា ឆ្នាំ2023)
	អ្នកស្រី Adel Leilanie Gaba Legarta	អភិបាល (លាលែងនៅថ្ងៃទី31 ខែមករា ឆ្នាំ2024)
	លោក Zulkiflee Kuan Shun Bin Abdullah	អភិបាល (លាលែងនៅថ្ងៃទី13 ខែមីនា ឆ្នាំ2023)
	លោក Rutsaran Moonsan	អភិបាលឯករាជ្យ (លាលែងនៅថ្ងៃទី13 ខែមីនា ឆ្នាំ2023)
អ្នកគ្រប់គ្រង៖	លោក ហុង សុខឡេង	អគ្គនាយក
	លោក យា សារឿន	អគ្គនាយករង
	លោក អ៊ាត ចិត្រាសូរិវង្ស	នាយកប្រតិបត្តិបច្ចេកវិទ្យា
	លោក Zulkiflee Kuan Shun Bin Abdullah	នាយកប្រតិបត្តិរតនាគារ
	អ្នកស្រី អៀន លក្ខិណា	នាយិកាប្រតិបត្តិការ
	លោក សំ ហុង	ប្រធាននាយកដ្ឋានធនធានមនុស្ស
	លោក បាន ម៉ារ៉ា	ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងរតនាគារ
	លោក សួន សុផានីកា	ប្រធាននាយកដ្ឋានគ្រប់គ្រងហានិភ័យ
	លោក គឹម លី	ប្រធាននាយកដ្ឋានឥណទាន

ធនាគារិកចម្បងៗ៖	ធនាគារជាតិនៃកម្ពុជា ធនាគារ អេស៊ីលីដា ភីអិលស៊ី ធនាគារ កាណាឌីយ៉ា ក.អ ធនាគារ វិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី ធនាគារ ខេប៊ីប្រាសាក់ ម.ក ធនាគារ Ajman ធនាគារ BIC Bank Lao Ltd ធនាគារ Kasikorn Bank Public Company Limited ធនាគារ Krung Thai Bank ធនាគារ Development Bank of Philippines ធនាគារ វីង (ខេមបូឌា) ម.ក
សវនករ៖	អេហ្វអាយអាយ & អឹសូស៊ីអេត

8.1 របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល សូមធ្វើការបង្ហាញនូវរបាយការណ៍របស់ខ្លួន ដោយភ្ជាប់ជាមួយនូវរបាយការណ៍ហិរញ្ញវត្ថុរបស់ ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក ហៅកាត់ថា ("ធនាគារ") ដែលបានធ្វើសវនកម្មរួចសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023។

សកម្មភាពចម្បង

សកម្មភាពចម្បងរបស់ធនាគារ គឺការផ្តល់នូវសេវាកម្មផ្នែកធនាគារ និងសេវាកម្មហិរញ្ញវត្ថុពាក់ព័ន្ធផ្សេងៗនៅក្នុង ព្រះរាជាណាចក្រកម្ពុជា។ ពុំមានការប្រែប្រួលជាសារវន្តទៅលើសកម្មភាពចម្បងនៅក្នុងការិយបរិច្ឆេទនោះទេ។

លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់ធនាគារ មានដូចខាងក្រោម៖

	2023		2022	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 2.4)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 2.4)
ប្រាក់ចំណេញមុនដកពន្ធ	**1,240,242**	**5,097,395**	483,629	1,976,592
ចំណាយពន្ធលើប្រាក់ចំណេញ	**(127,564)**	**(524,288)**	(388,871)	(1,589,316)
ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ	**1,112,678**	**4,573,107**	94,758	387,276

ភាគលាភ

ពុំមានភាគលាភណាត្រូវបានប្រកាស ឬត្រូវបានបង់ ហើយក្រុមប្រឹក្សាភិបាលក៏ពុំបានផ្តល់ជាអនុសាសន៍ឱ្យមានការបែងចែកភាគលាភសម្រាប់ការិយបរិច្ឆេទនេះទេ។

ដើមទុន

នៅថ្ងៃទី15 ខែមីនា ឆ្នាំ2023 ភាគទុនិកបានចុះហត្ថលេខាលើសេចក្តីសម្រេចរបស់ភាគទុនិកក្នុងការផ្ទេរភាគហ៊ុន ចំនួន60%កាន់កាប់ដោយក្រុមហ៊ុន Asia Investment and Financial Services Sole Co., Ltd. និង ចំនួន39% កាន់កាប់ដោយលោក យឹម លក្ខណ៍ ទៅឱ្យក្រុមហ៊ុន Apsara Holdings Pte. Ltd.។ សូមមើលកំណត់សម្គាល់ 18 សម្រាប់ភាគហ៊ុន និងរចនាសម្ព័ន្ធលម្អិតរបស់ធនាគារ។

ទុនបម្រុង និងសំវិធានធន

ពុំមានការប្រែប្រួលជាសារវន្តទៅលើទុនបម្រុង និងសំវិធានធននៅក្នុងការិយបរិច្ឆេទនេះទេ ក្រៅពីការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ។

ឥណទានអាក្រក់ និងឥណទានជាប់សង្ស័យ

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យដើម្បីបញ្ជាក់ថា វិធានការទាក់ទងនឹងការលុបចោលនូវឥណទានអាក្រក់ និងការធ្វើសំវិធានធន លើឥណទានជាប់សង្ស័យត្រូវបានធ្វើឡើង ហើយមានការជឿជាក់ថាមិនមានឥណទានអាក្រក់ និងសំវិធានធន ត្រូវបានធ្វើឡើងសម្រាប់ឥណទានជាប់សង្ស័យ។

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានពិនិត្យឃើញមានស្ថានភាពណាមួយ ដែលអាចនឹងបណ្តាលឱ្យចំនួននៃការលុបបំបាត់ចោលឥណទានអាក្រក់ ឬចំនួននៃការធ្វើសំវិធានធនលើឥណទានជាប់សង្ស័យនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះមានចំនួនខ្វះខាតជាសារវន្តនោះឡើយ។

ទ្រព្យសកម្មចរន្ត

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យដើម្បីបញ្ជាក់ថាបណ្តាទ្រព្យសកម្មចរន្តទាំងអស់ ដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យរបស់ធនាគារ ហើយដែលទំនងជាមិនអាចលក់បាននៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតា ត្រូវបានកាត់បន្ថយឱ្យនៅស្មើនឹងតម្លៃដែលរំពឹងទុកថានឹងអាចប្រមូលបានជាក់ស្តែង។

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលនឹងធ្វើឱ្យប៉ះពាល់ដល់ការកំណត់តម្លៃទ្រព្យសកម្មចរន្ត នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារថាមានភាពមិនត្រឹមត្រូវនោះទេ។

វិធីសាស្ត្រកំណត់តម្លៃ

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើងដែលនឹងធ្វើឱ្យ ប៉ះពាល់ដល់វិធីសាស្ត្រកំណត់តម្លៃ ដែលបានអនុវត្តកន្លងមកក្នុងការវាយតម្លៃទ្រព្យសកម្ម និងបំណុលនៅក្នុង របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារថាមានភាពមិនត្រឹមត្រូវ ឬមិនសមស្របនោះទេ។

បំណុលយថាភាព

នាការិយបរិច្ឆេទនៃរបាយការណ៍នេះពុំមាន៖

(ក) ការប្រែប្រួលទ្រព្យសកម្មណាមួយរបស់ធនាគារ ដែលកើតមានឡើងដោយសារការដាក់បញ្ចាំសម្រាប់ការធានាចំពោះបំណុលរបស់បុគ្គលណាមួយចាប់តាំងពីដំណាច់ឆ្នាំឡើយ ឬ

(ខ) បំណុលយថាហេតុណាមួយដែលកើតមានឡើងចំពោះធនាគារចាប់តាំងពីចុងការិយបរិច្ឆេទមកក្រៅអំពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ធនាគារ។

ក្រុមប្រឹក្សាភិបាលមានមតិថា ពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងៗទៀតរបស់ធនាគារ ដែលត្រូវបំពេញ ឬអាចនឹងត្រូវបំពេញក្នុងរយៈពេល 12ខែបន្ទាប់ពីចុងការិយបរិច្ឆេទនេះដែលនឹងធ្វើឱ្យមានផលប៉ះពាល់ ឬអាចនឹងប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ធនាគារក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនដូចដែលបានកំណត់និងនៅពេលដែលដល់ថ្ងៃកំណត់។

ការផ្លាស់ប្តូរនៃហេតុការណ៍

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាល ពុំបានដឹងពីហេតុការណ៍ណាមួយដែលមិនបានរែកញែកនៅក្នុងរបាយការណ៍នេះ ឬក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ដែលនឹងបណ្តាលឱ្យមានតួលេខនៃចំនួនណាមួយដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុមានភាពមិនត្រឹមត្រូវនោះទេ។

ប្រតិបត្តិការមិនប្រក្រតី

ក្រុមប្រឹក្សាភិបាលមានមតិថា លទ្ធផលនៃប្រតិបត្តិការរបស់ធនាគារ ក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះមិនមានផលប៉ះពាល់ជាសារវន្តដោយសកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីនោះទេ។

ក្រុមប្រឹក្សាភិបាលក៏មានមតិផងដែរថា នៅក្នុងចន្លោះពេលចាប់ពីថ្ងៃចុងការិយបរិច្ឆេទ ដល់ថ្ងៃចេញរបាយការណ៍នេះពុំមានចំណាត់ថ្នាក់សកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីកើតមានឡើង ដែលអាចនាំឱ្យប៉ះពាល់ដល់លទ្ធផលនៃប្រតិបត្តិការរបស់ធនាគារក្នុងការិយបរិច្ឆេទ ដែលរបាយការណ៍នេះបានរៀបចំឡើងនោះទេ។

ព្រឹត្តិការណ៍ក្រោយកាលបរិច្ឆេទរាយការណ៍

ពុំមានព្រឹត្តិការណ៍សារវន្តកើតឡើងក្រោយកាលបរិច្ឆេទរាយការណ៍ ដែលតម្រូវឱ្យមានការលាតត្រដាង ឬនិយ័តភាពក្រៅពីព្រឹត្តិការណ៍ដែលបានលាតត្រដាងរួចហើយ នៅក្នុងកំណត់សម្គាល់ដែលភ្ជាប់ជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាលដែលបម្រើការនៅក្នុងការិយបរិច្ឆេទ និងនាថ្ងៃចេញរបាយការណ៍នេះមានរាយនាមដូចខាងក្រោម៖

1. លោក យឹម លក្ខណ៍	ប្រធានក្រុមប្រឹក្សាភិបាល	
2. លោក John Edward Mc Cosh	អភិបាលឯករាជ្យ	
3. លោក យា សារឿន	អភិបាល	(តែងតាំងនៅថ្ងៃទី13 ខែមីនា ឆ្នាំ2023)
4. លោក តេ វុទ្ធី	អភិបាលឯករាជ្យ	(តែងតាំងនៅថ្ងៃទី13 ខែមីនា ឆ្នាំ2023)
5. អ្នកស្រី Adel Leilanle Gaba Legarta	អភិបាល	(លាលែងនៅថ្ងៃទី31 ខែមករា ឆ្នាំ2024)
6. លោក Zulkiflee Kuan Shun Bin Abdullah	អភិបាល	(លាលែងនៅថ្ងៃទី13 ខែមីនា ឆ្នាំ2023)
7. លោក Rutsaran Moonsan	អភិបាលឯករាជ្យ	(លាលែងនៅថ្ងៃទី13 ខែមីនា ឆ្នាំ2023)

ចំណែកហ៊ុនរបស់ក្រុមប្រឹក្សាភិបាល

សូមមើលកំណត់សម្គាល់ទី18 សម្រាប់ចំណែកហ៊ុនរបស់ក្រុមប្រឹក្សាភិបាល។

អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

មិនថានៅចុងការិយបរិច្ឆេទ ឬនៅក្នុងអំឡុងការិយបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុនេះ គឺមិនមានកិច្ចព្រមព្រៀងណាមួយដែលធនាគារជាភាគីម្ខាង ដែលកម្មវត្ថុនៃកិច្ចព្រមព្រៀងនោះអាចផ្តល់លទ្ធភាពដល់ក្រុមប្រឹក្សាភិបាលណាម្នាក់ឱ្យទទួលបាននូវអត្ថប្រយោជន៍ តាមមធ្យោបាយផ្សេងៗដូចជាការទិញភាគហ៊ុន ឬប័ណ្ណបំណុលរបស់ធនាគារ ឬសាជីវកម្មដទៃ។

ចាប់តាំងពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុនៃឆ្នាំកន្លងទៅក្រុមប្រឹក្សាភិបាលពុំបានទទួល ឬមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយ (ក្រៅពីអត្ថប្រយោជន៍ដែលបានរាប់បញ្ចូលក្នុងចំនួនសរុបនៃឯកត្តជនដែលបានទទួល ឬកំណត់នឹងអាចទទួលបានដោយក្រុមប្រឹក្សាភិបាល) តាមរយៈការចុះកិច្ចសន្យាធ្វើឡើងដោយធនាគារជាមួយក្រុមប្រឹក្សាភិបាល ឬដោយធនាគារផ្សេងដែលមានក្រុមប្រឹក្សាភិបាលជាសមាជិក ឬក៏ជាមួយធនាគារផ្សេង ដែលមានក្រុមប្រឹក្សាភិបាលជាសមាជិកនោះមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុច្រើនជាងអ្វីត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលមានភារៈធ្វើការអះអាងបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុបានរៀបចំឡើងយ៉ាងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារនាថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 និងព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (“CIFRS”)។ នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះក្រុមប្រឹក្សាភិបាលត្រូវ៖

(ក) អនុម័តនូវគោលនយោបាយគណនេយ្យសមស្រប ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុផល និងប្រុងប្រយ័ត្ន ព្រមទាំងអនុវត្តតាមគោលការណ៍ទាំងនេះប្រកបដោយសង្គតិភាព។

(ខ) អនុលោមទៅតាម CIFRS ឬប្រសិនបើមានការប្រាសចាកពីនេះដើម្បីបង្ហាញពីភាពពិត និងត្រឹមត្រូវ គឺត្រូវតែបង្ហាញ និងពន្យល់ឱ្យបានច្បាស់លាស់ និងកំណត់ចំនួននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

(គ) ត្រួតពិនិត្យប្រព័ន្ធដំណើរការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ និងការរក្សាទុកនូវបញ្ជីគណនេយ្យឱ្យបានគ្រប់គ្រាន់ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឱ្យមានប្រសិទ្ធភាព។

(ឃ) វាយតម្លៃនូវលទ្ធភាពរបស់ធនាគារចំពោះការបន្តនិរន្តរភាពអាជីវកម្ម ទទួលខុសត្រូវលើការលាតត្រដាងព័ត៌មាន ប្រសិនបើពាក់ព័ន្ធនូវបញ្ហាទាំងឡាយដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃស្តង់ដារគណនេយ្យ លើកលែងតែក្រុមប្រឹក្សាភិបាលមានបំណងចង់ជម្រះបញ្ជីធនាគារ ឬបញ្ឈប់ប្រតិបត្តិការ ឬគ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ។

(ង) ត្រួតពិនិត្យ និងដឹកនាំធនាគារឱ្យមានប្រសិទ្ធភាពលើរាល់សេចក្តីសម្រេចសំខាន់ៗទាំងឡាយ ដែលប៉ះពាល់ដល់សកម្មភាពប្រតិបត្តិការ និងដំណើរការរបស់ធនាគារ ហើយត្រូវប្រាកដថាកិច្ចការនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលធានាអះអាង ថាបានអនុវត្តនូវរាល់តម្រូវការដូចដែលបានរាយការណ៍ខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ។

ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាល សូមធ្វើការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុដែលភ្ជាប់មកជាមួយដូចដែលបានបង្ហាញនៅទំព័រទី 43 ដល់ 104 ថាបានបង្ហាញនូវភាពត្រឹមត្រូវក្នុងកម្រិតជាសារវន្តនៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់របស់ធនាគារសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា។

ចុះហត្ថលេខាដោយអនុលោមទៅតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលៈ

លោក ហុង សុខឡេង
អគ្គនាយក

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី28 ខែមីនា ឆ្នាំ2024

8.2 របាយការណ៍របស់សវនករឯករាជ្យ

ជូនចំពោះភាគទុនិក ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក

មតិសវនកម្ម

យើងខ្ញុំ បានធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក ហៅកាត់ថា (“ធនាគារ”) ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនាថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 ព្រមទាំងរបាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ របាយការណ៍ស្តីពីបម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ និងកំណត់សម្គាល់ដែលរួមមានគោលនយោបាយគណនេយ្យសារវន្ត ព្រមទាំងព័ត៌មានពន្យល់ផ្សេងៗទៀតដែលបានបង្ហាញនៅទំព័រទី 43 ដល់ 104។

ជាមតិរបស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុបានបង្ហាញនូវភាពត្រឹមត្រូវក្នុងកម្រិតជាសារវន្តនៃស្ថានភាពហិរញ្ញវត្ថុរបស់ ធនាគារ នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់របស់ធនាគារសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (“CIFRS”)។

មូលដ្ឋាននៃការបញ្ចេញមតិសវនកម្ម

យើងខ្ញុំ បានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា។ ការទទួលខុសត្រូវរបស់យើងខ្ញុំដែលស្របតាមស្តង់ដារទាំងនោះត្រូវបានរៀបរាប់បន្ថែមទៀតនៅក្នុងកថាខណ្ឌស្តីពីការទទួលខុសត្រូវរបស់សវនករសម្រាប់ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុដែលមាននៅក្នុងរបាយការណ៍របស់យើងខ្ញុំ។ យើងខ្ញុំមានឯករាជ្យភាពពីធនាគារ ស្របតាមតម្រូវការក្រមសីលធម៌ដែលពាក់ព័ន្ធនឹងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុនៅក្នុង ព្រះរាជាណាចក្រកម្ពុជា ហើយយើងខ្ញុំបានបំពេញតាមក្របខ័ណ្ឌទំនួលខុសត្រូវក្រមសីលធម៌ផ្សេងៗស្របតាមតម្រូវការទាំងនោះ។ យើងខ្ញុំជឿជាក់ថាភស្តុតាងសវនកម្មដែលយើងខ្ញុំប្រមូលបានមានលក្ខណៈគ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ។

បញ្ហាផ្សេងៗ

របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 ត្រូវបានធ្វើសវនកម្មដោយសវនករផ្សេងទៀតដែលបានបញ្ចេញមតិសវនកម្មនៅថ្ងៃទី27 ខែមេសា ឆ្នាំ2023 ថារបាយការណ៍នោះជាសារវន្តមានភាពត្រឹមត្រូវ។

ព័ត៌មានផ្សេងៗ

អ្នកគ្រប់គ្រងមានការទទួលខុសត្រូវលើព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗ ដែលបានទទួលត្រឹមថ្ងៃចេញរបាយការណ៍របស់សវនករ មានរបាយការណ៍របស់ក្រុមប្រឹក្សាភិបាលនៅទំព័រ 1 ដល់ទី 5 ចំណែកឯរបាយការណ៍ប្រចាំឆ្នាំរបស់ធនាគាររំពឹងថានឹងផ្តល់ឱ្យយើងខ្ញុំក្រោយកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះ។

មតិរបស់យើងខ្ញុំទៅលើរបាយការណ៍ហិរញ្ញវត្ថុ មិនបានគ្របដណ្តប់ព័ត៌មានផ្សេងៗឡើយ ហើយយើងខ្ញុំក៏មិនបានបញ្ចេញការសន្និដ្ឋានជាក់លាក់បន្ថែមលើនេះដែរ។

ពាក់ព័ន្ធនឹងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុ ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺត្រូវអានព័ត៌មានផ្សេងៗ ហើយពិចារណាថាតើព័ត៌មានផ្សេងៗនោះ មានភាពមិនស្របគ្នាជាសារវន្តជាមួយរបាយការណ៍ហិរញ្ញវត្ថុ ឬការយល់ដឹងរបស់យើងខ្ញុំនៅក្នុងការធ្វើសវនកម្ម ឬមានបង្ហាញនូវកំហុសឆ្គងជាសារវន្តឬទេ។ ប្រសិនបើផ្អែកតាមការងារដែលយើងខ្ញុំបានធ្វើមុនកាលបរិច្ឆេទនៃរបាយការណ៍សវនកម្ម អាចឱ្យយើងខ្ញុំសន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្តកើតឡើងលើព័ត៌មានផ្សេងៗ យើងខ្ញុំត្រូវរាយការណ៍ទៅតាមស្ថានភាពជាក់ស្តែង។ យើងខ្ញុំពុំមានអ្វីដែលត្រូវរាយការណ៍ពាក់ព័ន្ធនឹងព័ត៌មានផ្សេងៗនេះទេ។

ការទទួលខុសត្រូវលើរបាយការណ៍ហិរញ្ញវត្ថុរបស់អ្នកគ្រប់គ្រង និងអ្នកទទួលខុសត្រូវលើអភិបាលកិច្ច

អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការរៀបចំ និងការបង្ហាញនូវភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុដោយអនុលោម តាម CIFRS ហើយនិងទទួលខុសត្រូវលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលអ្នកគ្រប់គ្រងកំណត់ថាមានភាពចាំបាច់សម្រាប់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុឱ្យជៀសផុតពីការបង្ហាញខុសជាសារវន្តដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការវាយតម្លៃនូវលទ្ធភាពរបស់ធនាគារក្នុងការបន្តនិរន្តរភាពអាជីវកម្ម ទទួលខុសត្រូវលើការលាតត្រដាងព័ត៌មាន ប្រសិនបើពាក់ព័ន្ធនូវបញ្ហាទាំងឡាយដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យ លើកលែងតែអ្នកគ្រប់គ្រងមានបំណងចង់ជម្រះបញ្ជីផ្អាកដំណើរការធនាគារ ឬគ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ។

អ្នកទទួលខុសត្រូវលើអភិបាលកិច្ចមានភារៈទទួលខុសត្រូវក្នុងការត្រួតពិនិត្យដំណើរការហិរញ្ញវត្ថុរបស់ធនាគារ។

ការទទួលខុសត្រូវរបស់សវនករសម្រាប់ការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ

គោលដៅរបស់យើងខ្ញុំគឺផ្តល់នូវអំណះអំណាងសមហេតុផលថា របាយការណ៍ហិរញ្ញវត្ថុទាំងមូលមិនមានការបង្ហាញខុសជាសារវន្តដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងផ្តល់នូវរបាយការណ៍របស់សវនករដែលរួមបញ្ចូលទាំងមតិសវនកម្មរបស់យើងខ្ញុំ។ អំណះអំណាងសមហេតុផលគឺជាអំណះអំណាងមានកម្រិតខ្ពស់មួយ ប៉ុន្តែវាមិនអាចធានាថាគ្រប់ពេលនៃការធ្វើសវនកម្ម ដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជាអាចរកឃើញនូវការបង្ហាញខុសជាសារវន្តដែលបានកើតឡើងនោះទេ។ ការបង្ហាញខុសជាសារវន្តអាចកើតឡើងដោយសារការក្លែងបន្លំ ឬកំហុសឆ្គង ហើយត្រូវបានចាត់ទុកថាជាសារវន្តនៅពេលដែលការក្លែងបន្លំ ឬកំហុសឆ្គងតែមួយ ឬក៏រួមបញ្ចូលគ្នាមានផលប៉ះពាល់ដល់ការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ដោយយោងលើរបាយការណ៍ហិរញ្ញវត្ថុនេះ។

ជាផ្នែកមួយនៃការធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា យើងខ្ញុំអនុវត្តនូវការវិនិច្ឆ័យដែលប្រកបទៅដោយវិជ្ជាជីវៈ និងរក្សានូវមជ្ឈដ្ឋានគុនិយមក្នុងអំឡុងពេលសវនកម្ម។ យើងខ្ញុំក៏បាន៖

- ធ្វើការកំណត់ និងវាយតម្លៃនូវហានិភ័យនៃការបង្ហាញខុសជាសារវន្ត លើរបាយការណ៍ហិរញ្ញវត្ថុដោយសារតែការ ក្លែងបន្លំ កំហុសឆ្គង និងទទួលខុសត្រូវលើការរៀបចំ និងការអនុវត្តនូវនីតិវិធីសវនកម្មដើម្បីឆ្លើយតបទៅនឹងហានិភ័យទាំងនោះ និងប្រមូលនូវភស្តុតាងដែលមានលក្ខណៈគ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ។ ហានិភ័យដែលមិនអាចរកឃើញនូវការបង្ហាញខុសជាសារវន្តដែលកើតឡើងដោយសារតែការក្លែងបន្លំមានលក្ខណៈខ្ពស់ជាងការបង្ហាញខុសកើតឡើងពីកំហុសឆ្គងដោយសារតែការក្លែងបន្លំអាច រួមបញ្ចូលទាំងការឃុបឃិតគ្នា ការលួចបន្លំ ការលុបចោលដោយចេតនា ការបកស្រាយមិនពិត ឬមិនអនុវត្តតាមនីតិវិធីគ្រប់គ្រងផ្ទៃក្នុង។
- ទទួលបាននូវការយល់ដឹងអំពីការគ្រប់គ្រងផ្ទៃក្នុងដែលពាក់ព័ន្ធនឹងការធ្វើសវនកម្ម ក្នុងគោលបំណងដើម្បីរៀបចំនូវនីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនក្នុងគោលបំណងដើម្បីបញ្ចេញមតិលើប្រសិទ្ធភាពនៃការគ្រប់គ្រងផ្ទៃក្នុងរបស់ធនាគារឡើយ។
- ការវាយតម្លៃលើភាពសមស្របនៃគោលនយោបាយគណនេយ្យ ដែលធនាគារបានប្រើប្រាស់ និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យសំខាន់ៗ ព្រមទាំងការលាតត្រដាងព័ត៌មានពាក់ព័ន្ធដែលបានធ្វើឡើងដោយអ្នកគ្រប់គ្រង។
- ធ្វើការសន្និដ្ឋានលើភាពសមស្របនៃការប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យរបស់អ្នកគ្រប់គ្រង ហើយដោយផ្អែកទៅលើភស្តុតាងសវនកម្ម ដែលទទួលបានធ្វើការសន្និដ្ឋានថាតើភាពមិនច្បាស់លាស់ជាសារវន្តពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលអាចធ្វើឱ្យមានមន្ទិលជាសារវន្តលើលទ្ធភាពរបស់ធនាគារដើម្បីបន្តនិរន្តរភាពអាជីវកម្ម។ ប្រសិនបើយើងខ្ញុំធ្វើការសន្និដ្ឋានថាមានអត្ថិភាពនៃភាពមិនប្រាកដប្រជាជាសារវន្ត យើងខ្ញុំចាំបាច់ត្រូវបញ្ចូលនៅក្នុងរបាយការណ៍របស់យើងខ្ញុំ ដើម្បីទាញចំណាប់អារម្មណ៍លើការលាតត្រដាងព័ត៌មានពាក់ព័ន្ធនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើការលាតត្រដាងព័ត៌មានមានលក្ខណៈមិនគ្រប់គ្រាន់យើងខ្ញុំចាំបាច់ត្រូវផ្តល់មតិសវនកម្មដែលមានបញ្ហា។ ការសន្និដ្ឋានរបស់យើងខ្ញុំគឺផ្អែកតាមភស្តុតាងសវនកម្មដែលប្រមូលបានត្រឹមកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មរបស់យើងខ្ញុំ។ យ៉ាងណាក៏ដោយព្រឹត្តិការណ៍ ឬលក្ខខណ្ឌនាពេលអនាគតអាចធ្វើឱ្យធនាគារបញ្ឈប់នូវ និរន្តរភាពនៃអាជីវកម្ម។
- វាយតម្លៃលើការបង្ហាញរចនាសម្ព័ន្ធ និងខ្លឹមសារទូទៅនៃរបាយការណ៍ហិរញ្ញវត្ថុទាំងមូល ដែលរួមបញ្ចូលទាំងការលាតត្រដាងព័ត៌មាន និងវាយតម្លៃថាតើរបាយការណ៍ហិរញ្ញវត្ថុបានបង្ហាញពីប្រតិបត្តិការ និងព្រឹត្តិការណ៍ពាក់ព័ន្ធក្នុងអត្ថន័យដែលអាចសម្រេចបាននូវការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដ៏ត្រឹមត្រូវ។

យើងខ្ញុំបានផ្តល់ព័ត៌មានជូនអ្នកទទួលខុសត្រូវលើអភិបាលកិច្ច ចំពោះកត្តាពាក់ព័ន្ធពីសវនកម្មរួមមានជាអាទិ៍ វិសាលភាព និងពេលវេលាដែលបានគ្រោងទុកសម្រាប់ការធ្វើសវនកម្ម និងការរកឃើញបញ្ហាសវនកម្មជាសារវន្តរួមបញ្ចូលទាំងចំណុចខ្វះខាតនៃការគ្រប់គ្រងផ្ទៃក្នុងដែលបានរកឃើញក្នុងអំឡុងពេលធ្វើសវនកម្ម។

តំណាងក្រុមហ៊ុន អេហ្វអាយអាយ & អឹសូស៊ីអេត

សេង ចាន់ថន
ដៃគូសវនករ

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី28 ខែមីនា ឆ្នាំ2024

8.3 របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2023

	កំណត់សម្គាល់	2023		2022	
		ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 2.4)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 2.4)
ទ្រព្យសកម្ម					
សាច់ប្រាក់ និងសមតុល្យធនាគារ	5	259,585,139	1,060,405,293	124,143,924	511,100,535
ប្រាក់បញ្ញើនៅធនាគារផ្សេងៗ	6	19,731,058	80,601,372	-	-
ប្រាក់តម្កល់តាមបទប្បញ្ញត្តិ	7	36,871,218	150,618,926	23,871,072	98,277,203
ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន -សុទ្ធ	8	169,278,808	691,503,931	117,189,654	482,469,806
ការវិនិយោគផ្សេងៗ - សុទ្ធ	9	-	-	35,303,012	145,342,500
ទ្រព្យសកម្មផ្សេងៗ	10	24,918,593	101,792,452	22,918,319	94,354,719
គណនីត្រូវទទួលពីសម្ព័ន្ធញាតិ	27.1	429,674	1,755,218	-	-
ទ្រព្យសកម្មអរូបី	11	653,758	2,670,601	1,175,831	4,840,896
ទ្រព្យ និងបរិក្ខារ	12	2,165,952	8,847,914	2,415,600	9,945,025
សិទ្ធប្រើប្រាស់ទ្រព្យសកម្ម	13.1	7,378,794	30,142,373	3,128,587	12,880,393
ពន្ធពន្យារជាទ្រព្យសកម្ម - សុទ្ធ	17.2	588,067	2,402,254	97,526	401,516
ទ្រព្យសកម្មសរុប		**521,601,061**	**2,130,740,334**	**330,243,525**	**1,359,612,593**
បំណុល និងមូលធន					
បំណុល					
ប្រាក់បញ្ញើរបស់ធនាគារ	14	181,528,291	741,543,069	27,169,543	111,857,009
ប្រាក់បញ្ញើរបស់អតិថិជន	15	253,586,874	1,035,902,380	222,929,231	917,799,644
បំណុលភតិសន្យា	13.2	7,947,533	32,465,672	3,365,575	13,856,072
បំណុលផ្សេងៗ	16	590,582	2,412,527	386,973	1,593,168
បំណុលពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ	17.3	481,656	1,967,565	38,756	159,559
បំណុលសរុប		**444,134,936**	**1,814,291,213**	**253,890,078**	**1,045,265,452**
មូលធន					
ដើមទុន	18	75,000,000	300,000,000	75,000,000	300,000,000
ទុនបម្រុងតាមបទប្បញ្ញត្តិ	19	1,510,200	6,136,881	1,807,374	7,358,266
ប្រាក់ចំណេញរក្សាទុក/(ប្រាក់ខាតបង្គរ)		955,925	3,949,688	(453,927)	(1,844,804)
លម្អៀងពីការប្តូររូបិយប័ណ្ណ		-	6,362,552	-	8,833,679
មូលធនសរុប		77,466,125	316,449,121	76,353,447	314,347,141
បំណុល និងមូលធនសរុប		**521,601,061**	**2,130,740,334**	**330,243,525**	**1,359,612,593**

កំណត់សម្គាល់ដែលបានភ្ជាប់នេះ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ។

8.4 របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ

សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023

	កំណត់សម្គាល់	2023		2022	
		ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 2.4)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 2.4)
ចំណូលពីការប្រាក់	20	13,209,220	54,289,894	15,113,539	61,769,034
ចំណាយលើការប្រាក់	21	(6,293,037)	(25,864,382)	(7,590,330)	(31,021,679)
ចំណូលពីការប្រាក់សុទ្ធ		**6,916,183**	**28,425,512**	**7,523,209**	**30,747,355**
កម្រៃសេវា និងកម្រៃជើងសា	22	925,996	3,805,844	411,980	1,683,762
ចំណូលផ្សេងៗ		1,325,189	5,446,527	-	-
ប្រាក់ចំណូលពីប្រតិបត្តិការសរុប		**9,167,368**	**37,677,883**	**7,935,189**	**32,431,117**
ចំណាយលើបុគ្គលិក	23	(3,274,008)	(13,456,173)	(2,529,511)	(10,338,111)
រំលស់	24	(2,370,519)	(9,742,833)	(2,162,169)	(8,836,785)
ចំណាយប្រតិបត្តិការផ្សេងៗ	25	(2,764,635)	(11,362,650)	(1,999,711)	(8,172,819)
ការខាតបង់លើឱនភាពនៃតម្លៃនៃឧបករណ៍ហិរញ្ញវត្ថុ	8	482,036	1,981,168	(760,169)	(3,106,810)
ប្រាក់ចំណេញមុនដកពន្ធ		**1,240,242**	**5,097,395**	**483,629**	**1,976,592**
ចំណាយពន្ធលើប្រាក់ចំណេញ	17.4	(127,564)	(524,288)	(388,871)	(1,589,316)
ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ		**1,112,678**	**4,573,107**	**94,758**	**387,276**
លទ្ធផលលម្អិតផ្សេងៗ					
លម្អៀងពីការប្តូររូបិយប័ណ្ណ		-	(2,471,127)	-	3,281,965
លទ្ធផលលម្អិតសរុបសម្រាប់ការិយបរិច្ឆេទ		**1,112,678**	**2,101,980**	**94,758**	**3,669,241**

កំណត់សម្គាល់ដែលភ្ជាប់ជូននេះ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ។

8.5 របាយការណ៍ស្តីពីបម្រែបម្រួលមូលធន

សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023

	ដើមទុន		ទុនបម្រុងតាមបទប្បញ្ញត្តិ		ប្រាក់ខាតបង្គរ		លម្អៀងពីការប្តូររូបិយប័ណ្ណ		សរុប	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
		(កំណត់សម្គាល់ 2.4)		(កំណត់សម្គាល់ 2.4)		(កំណត់សម្គាល់ 2.4)	-	(កំណត់សម្គាល់ 2.4)		(កំណត់សម្គាល់ 2.4)
							-			
នាថ្ងៃទី1 ខែមករា ឆ្នាំ2022	75,000,000	300,000,000	1,552,087	6,314,908	(293,398)	(1,188,722)	-	5,551,714	76,258,689	310,677,900
លទ្ធផលលម្អិតសម្រាប់ការិយបរិច្ឆេទ										
ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ	-	-	-	-	94,758	387,276	-	-	94,758	387,276
ការផ្ទេរ	-	-	255,287	1,043,358	(255,287)	(1,043,358)	-	-	-	-
លទ្ធផលលម្អិតផ្សេងៗ										
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	-	-	-	-	-	-	3,281,965	-	3,281,965
សរុបលទ្ធផលលម្អិតសម្រាប់ការិយបរិច្ឆេទ	**-**	**-**	**1,807,374**	**7,358,266**	**(453,927)**	**(1,844,804)**	**-**	**8,833,679**	**76,353,447**	**314,347,141**
នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2022	**75,000,000**	**300,000,000**	**1,807,374**	**7,358,266**	**(453,927)**	**(1,844,804)**	**-**	**8,833,679**	**76,353,447**	**314,347,141**
2023							-			
នាថ្ងៃទី1 ខែមករា ឆ្នាំ2023	75,000,000	300,000,000	1,807,374	7,358,266	(453,927)	(1,844,804)	-	8,833,679	76,353,447	314,347,141
លទ្ធផលលម្អិតសម្រាប់ការិយបរិច្ឆេទ										
ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ	-	-	-	-	1,112,678	4,573,107	-	-	1,112,678	4,573,107
ការផ្ទេរ	-	-	(297,174)	(1,221,385)	297,174	1,221,385	-	-	-	-
លទ្ធផលលម្អិតផ្សេងៗ										
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	-	-	-	-	-	-	(2,471,127)	-	(2,471,127)
សរុបលទ្ធផលលម្អិតសម្រាប់ការិយបរិច្ឆេទ	-	-	(297,174)	(1,221,385)	1,409,852	5,794,492	-	(2,471,127)	1,112,678	2,101,980
នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2023	**75,000,000**	**300,000,000**	**1,510,200**	**6,136,881**	**955,925**	**3,949,688**	**-**	**6,362,552**	**77,466,125**	**316,449,121**

កំណត់សម្គាល់ដែលភ្ជាប់ជូននេះ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ។

8.6 របាយការណ៍លំហូរសាច់ប្រាក់

សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023

	2023		2022	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 2.4)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 2.4)
លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ				
ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ	1,112,678	4,573,107	94,758	387,276
និយ័តភាពលើ៖				
ចំណាយពន្ធលើប្រាក់ចំណេញ	127,564	524,288	388,871	1,589,316
ចំណាយលើការប្រាក់	6,293,037	25,864,382	7,590,330	31,021,679
ការខាតបង់លើឱនភាពនៃតម្លៃនៃឧបករណ៍ហិរញ្ញវត្ថុ	(482,036)	(1,981,168)	760,169	3,106,810
រំលស់	2,370,519	9,742,833	2,162,169	8,836,785
ចំណេញពីការលក់ទ្រព្យ និងបរិក្ខារ	98	403	-	-
ចំណូលការប្រាក់	(13,209,220)	(54,289,894)	(15,113,539)	(61,769,034)
	(3,787,360)	**(15,566,049)**	**(4,117,242)**	**(16,827,168)**
បម្រែបម្រួល៖				
ប្រាក់បញ្ញើនៅធនាគារផ្សេងៗ	(20,003,270)	(82,213,440)	5,536,120	22,626,122
ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន	(52,130,426)	(214,256,051)	25,756,979	105,268,772
ប្រាក់តម្កល់តាមបទប្បញ្ញត្តិ	(13,000,146)	(53,430,600)	2,000,064	8,174,262
ទ្រព្យសកម្មផ្សេងៗ	(2,429,948)	(9,987,086)	8,697,269	35,545,738
ប្រាក់បញ្ញើរបស់ធនាគារ	154,428,392	634,700,691	11,211,590	45,821,769
ប្រាក់បញ្ញើរបស់អតិថិជន	31,655,334	130,103,423	(39,016,789)	(159,461,617)
បំណុលផ្សេងៗ	203,609	836,833	(83,437)	(341,007)
សាច់ប្រាក់ទទួលបានពីប្រតិបត្តិការ	**94,936,185**	**390,187,721**	**9,984,554**	**40,806,871**
ការប្រាក់ទទួលបាន	13,665,850	56,166,644	16,181,372	66,133,267
ការប្រាក់ដែលបានបង់	(7,175,090)	(29,489,620)	(7,483,507)	(30,585,093)
ពន្ធលើប្រាក់ចំណេញដែលបានបង់	(175,205)	(720,093)	(700,257)	(2,861,950)
សាច់ប្រាក់សុទ្ធទទួលបានពីសកម្មភាពប្រតិបត្តិការ	**101,251,740**	**416,144,652**	**17,982,162**	**73,493,095**

	2023		2022	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 2.4)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 2.4)
លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ				
ការទិញទ្រព្យ និងបរិក្ខារ និងទ្រព្យសកម្មអរូបី	(1,011,967)	(4,159,184)	(283,894)	(1,160,275)
ការលក់ទ្រព្យ និងបរិក្ខារ	(98)	(403)	-	-
ការវិនិយោគផ្សេងៗ	35,502,167	145,913,906	(12,319,610)	(50,350,246)
សាច់ប្រាក់សុទ្ធទទួលបានពី/(ប្រើប្រាស់ក្នុង)សកម្មភាពវិនិយោគ	**34,490,102**	**141,754,319**	**(12,603,504)**	**(51,510,521)**
លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន				
ការទូទាត់បំណុលភតិសន្យា	(536,060)	(2,203,206)	(378,522)	(1,547,019)
សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពហិរញ្ញប្បទាន	**(536,060)**	**(2,203,206)**	**(378,522)**	**(1,547,019)**
ការកើនឡើងសុទ្ធនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល	**135,205,782**	**555,695,765**	**5,000,136**	**20,435,555**
សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាថ្ងៃទី1 ខែមករា	124,493,561	512,539,991	119,493,425	486,816,213
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	(7,363,940)	-	5,288,223
សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាថ្ងៃទី31 ខែធ្នូ (កំណត់សម្គាល់ 5)	**259,699,343**	**1,060,871,816**	**124,493,561**	**512,539,991**

កំណត់សម្គាល់ដែលភ្ជាប់ជូននេះ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ។

8.7 កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ

សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023

1. ព័ត៌មានអំពីធនាគារ

ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក ហៅកាត់ថា (“ធនាគារ”) ត្រូវបានបង្កើតឡើង និងបានចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី14 ខែវិច្ឆិកា ឆ្នាំ2017 ក្រោមបញ្ជីពាណិជ្ជកម្មលេខ 00029200 ចេញដោយក្រសួងពាណិជ្ជកម្ម ហើយបានចាប់ផ្តើមសកម្មភាពប្រតិបត្តិការបន្ទាប់ពីធនាគារទទួលបានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជានៅថ្ងៃទី18 ខែកក្កដា ឆ្នាំ2018។

សកម្មភាពចម្បងរបស់ធនាគារ គឺការផ្តល់នូវសេវាកម្មផ្នែកធនាគារ និងសេវាកម្មហិរញ្ញវត្ថុពាក់ព័ន្ធផ្សេងៗ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ទីស្នាក់ការចុះបញ្ជីរបស់ធនាគារមានទីតាំងស្ថិតនៅអគារលេខ 462 ជាន់ផ្ទាល់ដី និងជាន់ទី1 មហាវិថីព្រះមុនីវង្ស (ផ្លូវលេខ 93) ភូមិ 13 សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 ធនាគារមានបុគ្គលិកសរុបចំនួន 162 នាក់ (2022៖ 129នាក់)។

2. មូលដ្ឋាននៃការរៀបចំ

2.1 របាយការណ៍អនុលោមភាព

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំឡើងដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុ អន្តរជាតិនៃកម្ពុជា (“CIFRSs”)។ CIFRSs គឺដូចគ្នានឹងស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ (“IFRSs”) ដែលបានចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ (“IASB”) ពីព្រោះ IFRSs ត្រូវបានអនុម័តដោយក្រុមប្រឹក្សាគណនេយ្យជាតិ ឥឡូវនេះប្តូរទៅជានិយ័តករគណនេយ្យ និងសវនកម្មដោយគ្មានការកែតម្រូវទៅលើ CIFRSs ឡើយ។

ព័ត៌មានលម្អិតអំពីគោលនយោបាយគណនេយ្យសារវន្តរបស់ធនាគារ ត្រូវបានលាតត្រដាងក្នុងកំណត់សម្គាល់ 29។

របាយការណ៍ហិរញ្ញវត្ថុត្រូវបានអនុម័តសម្រេចដោយក្រុមប្រឹក្សាភិបាលធនាគារ និងផ្តល់សិទ្ធិផ្សាយ នៅថ្ងៃទី28 ខែមីនា ឆ្នាំ2024។

2.2 ការិយបរិច្ឆេទសារពើពន្ធ និងការិយបរិច្ឆេទរាយការណ៍

ឆ្នាំសារពើពន្ធរបស់ធនាគារចាប់ផ្តើមនៅថ្ងៃទី1 ខែ មករា និង បញ្ចប់នៅថ្ងៃទី31 ខែធ្នូ។

2.3 មូលដ្ឋាននៃការវាស់វែង

របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ត្រូវបានរៀបចំឡើងទៅតាមមូលដ្ឋានតម្លៃដើម។

2.4 រូបិយប័ណ្ណគោល និងរូបិយប័ណ្ណសម្រាប់ធ្វើការបង្ហាញ

រូបិយប័ណ្ណជាតិនៃព្រះរាជាណាចក្រកម្ពុជា គឺប្រាក់រៀល។ ធនាគារធ្វើប្រតិបត្តិការ និងកត់ត្រារាល់បញ្ជីគណនេយ្យរបស់ខ្លួនផ្អែកលើមូលដ្ឋានរូបិយប័ណ្ណពីរប្រភេទ ជាប្រាក់ដុល្លារអាមេរិក និងប្រាក់រៀល។ អ្នកគ្រប់គ្រងបានកំណត់ប្រាក់ដុល្លារអាមេរិកជារូបិយប័ណ្ណគោលព្រោះវាបានឆ្លុះបញ្ចាំងពីភាពចាំបាច់នៃសេដ្ឋកិច្ច ប្រភពព្រឹត្តិការណ៍ និងកាលៈទេសៈរបស់ធនាគារ។

របាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិក។ ការប្តូររូបិយប័ណ្ណពីប្រាក់ដុល្លារអាមេរិកទៅជាប្រាក់រៀល ត្រូវបានធ្វើឡើងដើម្បីអនុវត្តទៅតាមគោលការណ៍ច្បាប់ គណនេយ្យ និងសវនកម្ម។

ទ្រព្យសកម្ម និងបំណុលត្រូវបានប្តូរទៅជាប្រាក់រៀល ដោយប្រើអត្រាប្តូរប្រាក់នាកាលបរិច្ឆេទរាយការណ៍ហើយគណនីមូលធន ត្រូវបានប្តូរដោយប្រើអត្រាប្តូរប្រាក់ប្រវត្តិសាស្ត្រ។ ដោយឡែករបាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ និងរបាយការណ៍លំហូរសាច់ប្រាក់ គឺត្រូវបានប្តូរទៅជាប្រាក់រៀល ដោយប្រើអត្រាប្តូរប្រាក់មធ្យមប្រចាំឆ្នាំ។ លម្អៀងលើអត្រាប្តូរប្រាក់ ត្រូវបានទទួលស្គាល់ជា "លម្អៀងពីការប្តូររូបិយប័ណ្ណ" ក្នុងលទ្ធផលលម្អិតផ្សេងៗ។ លម្អៀងពីការប្តូររូបិយប័ណ្ណបង្គរ ត្រូវបានកត់ត្រាជាផ្នែកមួយនៅក្នុងរបាយការណ៍មូលធន។ គ្រប់តួលេខជាប្រាក់រៀល ត្រូវបានបង្គត់ជាខ្ទង់ពាន់ឡើងចុះទៅនឹងតួលេខដែលនៅជិតបំផុត "ពាន់រៀល" លើកលែងតែមានការបញ្ជាក់ផ្សេងទៀត។

ធនាគារប្រើប្រាស់អត្រាប្តូរប្រាក់ដូចខាងក្រោម៖

សម្រាប់ការិយបរិច្ឆេទ	អត្រាចុងគ្រា	អត្រាមធ្យម
ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023	1ដុល្លារ = 4,085 រៀល	4,110 រៀល
ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022	1ដុល្លារ = 4,117 រៀល	4,087 រៀល

តួលេខជាប្រាក់រៀលនេះ គឺធ្វើឡើងក្នុងគោលបំណងអនុលោមភាពតែប៉ុណ្ណោះ វាមិនត្រូវបានយកមកបកស្រាយថាតួលេខប្រាក់ដុល្លារអាមេរិកត្រូវបានប្តូរទៅជាប្រាក់រៀល ឬនឹងត្រូវប្តូរជាប្រាក់រៀលនាពេលអនាគតតាមអត្រាប្តូរប្រាក់នេះ ឬអត្រាប្តូរប្រាក់ផ្សេងទៀតនោះឡើយ។

2.5 ការប៉ាន់ស្មាន និងការវិនិច្ឆ័យ

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ តម្រូវឱ្យអ្នកគ្រប់គ្រងធ្វើការវិនិច្ឆ័យ ការប៉ាន់ស្មាន និងការសន្មតដែលមានផលប៉ះពាល់ដល់ការអនុវត្តនូវគោលនយោបាយគណនេយ្យ និងចំនួននៃទ្រព្យសកម្ម បំណុល ចំណូល និងចំណាយដែលបានរាយការណ៍។ លទ្ធផលជាក់ស្តែងអាចខុសពីការប៉ាន់ស្មានទាំងនេះ។

ការប៉ាន់ស្មាន និងការសន្មតដែលពាក់ព័ន្ធត្រូវបានត្រួតពិនិត្យជាប្រចាំ។ ការកែប្រែលើការប៉ាន់ស្មានគណនេយ្យត្រូវបានទទួលស្គាល់ និងកត់ត្រានៅក្នុងការិយបរិច្ឆេទ ដែលការប៉ាន់ស្មាននោះត្រូវបានកែប្រែនិងការិយបរិច្ឆេទអនាគតដែលមានផលប៉ះពាល់ដោយការកែប្រែនោះ។

3. ការប៉ាន់ស្មានគណនេយ្យ និងការវិនិច្ឆ័យផ្សេងៗ

ការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យត្រូវបានវាយតម្លៃជាបន្តបន្ទាប់ហើយផ្អែកលើបទពិសោធន៍ធ្លាប់មាន និងកត្តាដទៃទៀត រួមទាំងការរំពឹងទុកនៃហេតុការណ៍ដែលធ្លាប់បរាជ័យ ដែលត្រូវបានគេជឿជាក់ថាសមហេតុផលទៅតាមកាលៈទេសៈ។ ការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យថាមានហានិភ័យខ្ពស់ ដែលអាចតម្រូវឱ្យធ្វើនិយ័តកម្មលើតម្លៃយោងនៃទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុសម្រាប់កាលបរិច្ឆេទបន្ទាប់មានដូចខាងក្រោម៖

3.1 ពន្ធលើប្រាក់ចំណេញ និងពន្ធផ្សេងទៀត

ចំណាយពន្ធត្រូវបានគណនាផ្អែកលើការបកស្រាយចំពោះការអនុវត្តច្បាប់សារពើពន្ធបច្ចុប្បន្ន។ ទោះយ៉ាងណាក៏ដោយបទប្បញ្ញត្តិទាំងនេះអាចមានការប្រែប្រួលជារឿយៗ និងការបកស្រាយផ្សេងៗគ្នា បន្ទាប់ពីមានការត្រួតពិនិត្យពីអាជ្ញាធរពន្ធដារ។ ទាំងនេះ អាចបណ្តាលឱ្យមានការកើនឡើងចំណាយពន្ធ និងការទាមទារទូទាត់ប្រតិសកម្ម ។ វាពិតជាពិបាកកំណត់ពេលវេលាជាក់លាក់ណាមួយ និងភាពធ្ងន់ធ្ងរនៃការកើតឡើងទាំងនេះ ឬផលប៉ះពាល់ដ៏មានសក្តានុពលរបស់វា។

3.2 ទ្រព្យ និងបរិក្ខារ និងទ្រព្យសកម្មអរូបី

គណនេយ្យសម្រាប់ទ្រព្យ និងបរិក្ខារ និងទ្រព្យសកម្មអរូបី រួមបញ្ចូលទាំងការប៉ាន់ស្មានសម្រាប់កំណត់អាយុកាលនៃការប្រើប្រាស់នៃទ្រព្យ និងបរិក្ខារ និងទ្រព្យសកម្មអរូបី។ ការកំណត់អាយុកាលនៃការប្រើប្រាស់នៃទ្រព្យ និងបរិក្ខារ និងទ្រព្យសកម្មអរូបី គឺផ្អែកលើការវិនិច្ឆ័យរបស់អ្នកគ្រប់គ្រង។

3.3 ឱនភាពនៃឧបករណ៍ហិរញ្ញវត្ថុ

ដូចដែលបានបង្ហាញនៅក្នុងកំណត់សម្គាល់ទី28 (ក) ហានិភ័យឥណទានរបស់អតិថិជនត្រូវបានវាយតម្លៃជាប្រចាំ ដោយផ្តោតទៅលើលទ្ធភាពបច្ចុប្បន្នរបស់អតិថិជនក្នុងការទូទាត់ កំណត់ត្រាទូទាត់កន្លងមក និងការពិចារណាលើព័ត៌មានជាក់លាក់របស់អតិថិជន ក៏ដូចជាព័ត៌មានពាក់ព័ន្ធ

នឹងប្រទេស និងស្ថានភាពសេដ្ឋកិច្ចដែលអតិថិជនធ្វើប្រតិបត្តិការ។ ការខាតបង់ឥណទានក៏ឆ្លុះបញ្ចាំងពីទិន្នន័យប្រមើលមើលអនាគតផងដែរ។ ប្រសិនបើស្ថានភាពហិរញ្ញវត្ថុរបស់អតិថិជនកាន់តែយ៉ាប់យ៉ឺន ឬប្រសើរឡើង ឬការរំពឹងទុកអំពីលទ្ធផលសេដ្ឋកិច្ចនាពេលអនាគតខុសគ្នានឹងការប៉ាន់ប្រមាណរបស់ធនាគារ អាចនឹងតម្រូវឱ្យមានការធ្វើសំវិធានធនបន្ថែម ឬដកចេញនាពេលអនាគត។

3.4 ភតិសន្យា

អ្នកគ្រប់គ្រងធ្វើការវិនិច្ឆ័យថាតើធនាគារមានភាពប្រាកដក្នុងការបន្តនូវភតិសន្យា និងរយៈពេលភតិសន្យា។

3.5 ការវាស់វែងនៃតម្លៃសមស្រប

គោលនយោបាយគណនេយ្យ និងការកំណត់បង្ហាញមួយចំនួនរបស់ធនាគារតម្រូវឱ្យមានការវាស់វែងនូវតម្លៃសមស្របទាំងទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ។

តម្លៃសមស្រប ត្រូវបានចាត់ថ្នាក់ក្នុងកម្រិតខុសៗគ្នាតាមឋានានុក្រមតម្លៃសមស្រប ដោយយោងលើទិន្នន័យដែលប្រើប្រាស់នៅក្នុងវិធីសាស្រ្តវាយតម្លៃដូចខាងក្រោម៖

- **កម្រិតទី 1:** តម្លៃដកស្រង់ (មិនទាន់មាននិយ័តភាព) នៅក្នុងទីផ្សារសកម្មសម្រាប់ទ្រព្យសកម្ម ឬ បំណុលស្រដៀងគ្នា។
- **កម្រិតទី 2:** ទិន្នន័យដែលមិនមែនជាតម្លៃដកស្រង់ដែលមាននៅក្នុងកម្រិតទី1 ដែលអាចធ្វើការអង្កេតបានសម្រាប់ទ្រព្យសកម្ម ឬបំណុលទោះបីដោយផ្ទាល់ (ឧទាហរណ៍ដូចជាតម្លៃ) ឬមិនផ្ទាល់ (ឧទាហរណ៍កើតចេញពីតម្លៃ)។
- **កម្រិតទី 3:** ទិន្នន័យសម្រាប់ទ្រព្យសកម្ម ឬបំណុល ដែលមិនអាស្រ័យលើទិន្នន័យអង្កេតទីផ្សារ (ធាតុចូលមិនអាចអង្កេតបាន)។

ប្រសិនបើទិន្នន័យប្រើប្រាស់សម្រាប់ប៉ាន់ស្មានតម្លៃសមស្របនៃទ្រព្យសកម្ម ឬបំណុលមួយចាត់ទៅក្នុងថ្នាក់ខុសគ្នានៃកម្រិតតម្លៃសមស្រប នោះការប៉ាន់ស្មានតម្លៃសមស្របទាំងអស់នឹងនៅក្នុងកម្រិតតែមួយ នៃតម្លៃសមស្របដូចទិន្នន័យថ្នាក់ទាបដែលមានសារៈសំខាន់ក្នុងការប៉ាន់ស្មានទាំងអស់ ។

ធនាគារ ទទួលស្គាល់ការផ្ទេរផ្សេងៗរវាងកម្រិតនៃតម្លៃសមស្រប នាចុងការិយបរិច្ឆេទនៃរបាយការណ៍ដែលមានការផ្លាស់ប្តូរ។

ព័ត៌មានលើការប៉ាន់ស្មានតម្លៃសមស្រប គឺបង្ហាញនៅកំណត់សម្គាល់ 28 (ឃ) – ឧបករណ៍ហិរញ្ញវត្ថុ។

4. ការអនុវត្តស្តង់ដារថ្មី និងស្តង់ដារគណនេយ្យដែលបានកែប្រែ

4.1 ស្តង់ដារថ្មី និងស្តង់ដារគណនេយ្យដែលបានកែប្រែហើយមានប្រសិទ្ធភាពក្នុងការិយបរិច្ឆេទ

ធនាគារបានអនុវត្តទៅលើស្តង់ដារគណនេយ្យ និងការបកស្រាយស្តង់ដារទាំងអស់ គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2023។ ស្តង់ដារគណនេយ្យថ្មី និងស្តង់ដារគណនេយ្យដែលបានកែប្រែ និងបានធ្វើការបកស្រាយស្តង់ដារដែលត្រូវបានវាយតម្លៃថាអាចអនុវត្តបានសម្រាប់របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារមានដូចខាងក្រោម៖

- CIFRS 17 កិច្ចសន្យាធានារ៉ាប់រង
- វិសោធនកម្មលើ CIFRS 17 កិច្ចសន្យាធានារ៉ាប់រង (វិសោធនកម្មលើ IFRS C17 និង CIFRS 4)
- ការបង្ហាញគោលនយោបាយគណនេយ្យ (វិសោធនកម្មលើ CIAS 1 និង CIFRS Practice Statement 2)
- និយមន័យនៃការប៉ាន់ស្មានគណនេយ្យ (វិសោធនកម្មលើ CIAS 8 គោលនយោបាយគណនេយ្យ ការផ្លាស់ប្តូរលើការប៉ាន់ស្មានគណនេយ្យ និងកំហុស)
- ពន្ធពន្យារជាទ្រព្យសកម្ម និងបំណុលដែលកើតចេញពីប្រតិបត្តិការតែមួយ (វិសោធនកម្មលើ CIAS 12)
- កំណែទម្រង់លើពន្ធអន្តរជាតិ - Pillar Two Model Rules (វិសោធនកម្មលើ CIAS 12)

អ្នកគ្រប់គ្រងធ្វើការវាយតម្លៃថាការអនុវត្តស្តង់ដារគណនេយ្យខាងក្រោម មិនមានផលប៉ះពាល់ជាសារវន្តលើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារនោះទេ។

- កំណែទម្រង់អត្រាការប្រាក់គោល - ដំណាក់កាលទី 2 (វិសោធនកម្មលើ CIFRS9 ឧបករណ៍ហិរញ្ញវត្ថុ CAS 39 ឧបករណ៍ហិរញ្ញវត្ថុ CIFRS 7 ឧបករណ៍ហិរញ្ញវត្ថុ CIFRS 4 កិច្ចសន្យាធានារ៉ាប់រង និង CIFRS 16) ត្រូវបានវាយតម្លៃថាមិនមានផលប៉ះពាល់លើធនាគារនោះទេ។
- ផ្នែកបន្ថែមលើការលើកលែងជាបណ្តោះអាសន្នលើការអនុវត្តស្តង់ដារ CIFRS9 (វិសោធនកម្មលើ CIFRS 4)

4.2 ស្តង់ដារថ្មី និងការធ្វើវិសោធនកម្មដែលមិនទាន់ត្រូវបានអនុវត្ត

នាថ្ងៃដែលបានអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុនេះ ស្តង់ដារថ្មី និងការធ្វើវិសោធនកម្មមួយចំនួនដែលបានផ្សព្វផ្សាយ ប៉ុន្តែមិនទាន់មានប្រសិទ្ធភាព ហើយត្រូវបានគេរំពឹងទុកថា នឹងមានផលប៉ះពាល់ជាសារវន្តលើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារមានដូចខាងក្រោម៖

- បំណុលភតិសន្យា ក្នុងការលក់ និងជួលមកវិញ (វិសោធនកម្មលើ CIFRS16 ភតិសន្យា)
- ចំណាត់ថ្នាក់លើបំណុលរយៈពេលខ្លី ឬរយៈពេលវែង និងបំណុលរយៈពេលវែងជាមួយកិច្ចព្រមព្រៀង (វិសោធនកម្មលើ IAS1 ការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ)
- ការរៀបចំអ្នកផ្គត់ផ្គង់ហិរញ្ញវត្ថុ (វិសោធនកម្មលើ CIAS 7 របាយការណ៍លំហូរសាច់ប្រាក់ និង CIFRS 7 ឧបករណ៍ហិរញ្ញវត្ថុ ៖ ការបង្ហាញ)
- កង្វះខាតក្នុងការប្តូររូបិយប័ណ្ណ (វិសោធនកម្មលើ CIAS 21 ផលប៉ះពាល់ក្នុងការប្តូររូបិយប័ណ្ណបរទេស) ។

5. សាច់ប្រាក់ និងសាច់ប្រាក់សមមូល / សាច់ប្រាក់ និងសមតុល្យធនាគារ

	2023		2022	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 2.4)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 2.4)
សាច់ប្រាក់ក្នុងដៃ	12,846,657	52,478,594	7,134,928	29,374,499
សមតុល្យនៅធនាគារផ្សេងៗ	246,852,686	1,008,393,222	114,039,130	469,499,098
ប្រាក់តម្កល់ជាមួយធនាគារដែលមានកាលវសាន្តដំបូងតិចជាង 3 ខែ	-	-	3,319,503	13,666,394
សាច់ប្រាក់ និងសាច់ប្រាក់សមមូលបានបង្ហាញលើរបាយការណ៍លំហូរសាច់ប្រាក់	259,699,343	1,060,871,816	124,493,561	512,539,991
ដក៖ សំវិធានធននៃការខាតបង់លើឱនភាពតម្លៃ	(114,204)	(466,523)	(349,637)	(1,439,456)
	259,585,139	**1,060,405,293**	**124,143,924**	**511,100,535**

សមតុល្យនៅធនាគារផ្សេងៗ និងប្រាក់តម្កល់ជាមួយធនាគារដែលមានកាលវសាន្តដំបូងតិចជាង 3 ខែទទួលបានការប្រាក់ចាប់ពី 1.5% ដល់ 6% ក្នុងមួយឆ្នាំក្នុងអំឡុងឆ្នាំ 2023 (2022 ៖ 1% ដល់ 6%) ។ ចំណូលការប្រាក់ដែលរកបានក្នុងអំឡុងការិយបរិច្ឆេទមានចំនួន 1,473,916 ដុល្លារអាមេរិក (2022 ៖ 1,709,018 ដុល្លារអាមេរិក) ។

បម្រែបម្រួលនៃសំវិធានធនលើការខាតបង់លើឱនភាពនៃតម្លៃមានដូចខាងក្រោម៖

	2023		2022	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 2.4)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 2.4)
នាថ្ងៃទី1 ខែមករា	349,637	1,439,456	589,046	2,399,773
តំហយសំវិធានធនក្នុងការិយបរិច្ឆេទ	(235,433)	(967,630)	(239,409)	(978,465)
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	(5,303)	-	18,148
នាថ្ងៃទី31 ខែធ្នូ	**114,204**	**466,523**	**349,637**	**1,439,456**

6. ប្រាក់បញ្ញើនៅធនាគារផ្សេងៗ

	2023		2022	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 2.4)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 2.4)
ប្រាក់បញ្ញើមានកាលកំណត់	20,034,520	81,841,014	-	-
ដក៖ សំវិធានធននៃការខាតបង់លើឱនភាពនៃតម្លៃ	(303,462)	(1,239,642)	-	-
	19,731,058	**80,601,372**	**-**	**-**

នេះគឺជាប្រាក់បញ្ញើនៅធនាគារផ្សេងៗដែលមានកាលវសាន្តលើសពី 3 ខែ និងតិចជាង 1 ឆ្នាំដែលទទួលបានការប្រាក់ 7% ក្នុងឆ្នាំ2023 (2022 ៖ 1% ទៅ 4%) ក្នុងមួយឆ្នាំ។ ចំណូលការប្រាក់ដែលទទួលបានក្នុងការិយបរិច្ឆេទមានចំនួន 725,047 ដុល្លារអាមេរិកក្នុងឆ្នាំ2023 (2022 ៖ 40,980 ដុល្លារអាមេរិក)។

បម្រែបម្រួលនៃសំវិធានធនលើការខាតបង់លើឱនភាពនៃតម្លៃមានដូចខាងក្រោម៖

	2023		2022	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 2.4)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 2.4)
នាថ្ងៃទី1 ខែមករា	-	-	-	-
សំវិធានធនក្នុងការិយបរិច្ឆេទ	303,462	1,247,229	-	-
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	(7,587)	-	-
នាថ្ងៃទី31 ខែធ្នូ	**303,462**	**1,239,642**	**-**	**-**

7. ប្រាក់តម្កល់តាមបទប្បញ្ញត្តិ

		2023		2022	
		ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 2.4)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 2.4)
ប្រាក់តម្កល់ធានាលើដើមទុន	(ក)	7,500,000	30,637,500	7,500,000	30,877,500
ប្រាក់បម្រុងកាតព្វកិច្ចលើប្រាក់បញ្ញើរបស់អតិថិជន	(ខ)	29,371,218	119,981,426	16,371,072	67,399,703
		36,871,218	**150,618,926**	**23,871,072**	**98,277,203**

(ក) យោងតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជា លេខ ធ7-01-136 ចុះថ្ងៃទី15 ខែតុលា ឆ្នាំ2001 ធនាគារតម្រូវឱ្យរក្សាប្រាក់តម្កល់តាមច្បាប់ចំនួន 10% នៃដើមទុនរបស់ខ្លួន។ ប្រាក់តម្កល់នេះ គឺមិនអាចប្រើប្រាស់ក្នុងប្រតិបត្តិការប្រចាំថ្ងៃរបស់ខ្លួនបានឡើយ ប៉ុន្តែធនាគារអាចដកវិញបាននៅពេលដែលធនាគារសម្រេចចិត្តឈប់ធ្វើអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយស្ម័គ្រចិត្ត។ ប្រាក់តម្កល់នេះទទួលបានការប្រាក់ 0.08% - 1.19% ក្នុងឆ្នាំ2023 (2022 ៖ 0.08% - 1.19%) ក្នុងមួយឆ្នាំ មានចំនួន 94,543 ដុល្លារអាមេរិក ក្នុងឆ្នាំ2023 (2022 ៖ 27,551 ដុល្លារ អាមេរិក)។

(ខ) ប្រាក់បម្រុងកាតព្វកិច្ច គឺជាទុនបម្រុងអប្បបរមាដែលត្រូវបានគណនាតាមអត្រា 8% ចំពោះរូបិយប័ណ្ណជាប្រាក់រៀល និង 12.50 % ចំពោះរូបិយបណ្ណផ្សេងៗ នៃចំនួនទឹកប្រាក់សរុប នៃប្រាក់បញ្ញើពីអតិថិជន ប្រាក់បញ្ញើរបស់ធនាគារអនិវាសនជន និងប្រាក់បញ្ញើគ្រឹះស្ថានហិរញ្ញវត្ថុ និងប្រាក់កម្ចីលើអនិវាសនជន។ យោងតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជា លេខ ធ7-018-282 ប្រ.ក. ស្តីពីការរក្សាទុនបម្រុងកាតព្វកិច្ចចុះថ្ងៃទី29 ខែសីហា ឆ្នាំ2018 សម្រាប់ប្រាក់បញ្ញើ និងការខ្ចីរបស់ធនាគារពាណិជ្ជ ប្រាក់បម្រុងកាតព្វកិច្ចជាប្រាក់រៀល និងរូបិយប័ណ្ណផ្សេងមិនទទួលបានការប្រាក់ទេ។

នាថ្ងៃទី17 ខែមីនា ឆ្នាំ2020 ធនាគារជាតិនៃកម្ពុជា បានចេញសេចក្តីថ្លែងការណ៍ ដោយប្រកាសកាត់បន្ថយអត្រាទុនបម្រុងកាតព្វកិច្ចមកត្រឹម 7% ចំពោះប្រាក់បញ្ញើ និងប្រាក់កម្ចីជាប្រាក់រៀល និងរូបិយប័ណ្ណបរទេសដើម្បីចូលរួមកាត់បន្ថយផលប៉ះពាល់ពីការឆ្លងរាលដាលជម្ងឺកូវីដ-19 មកលើសេដ្ឋកិច្ចកម្ពុជា។

នាថ្ងៃទី9 ខែមករា ឆ្នាំ2023 ធនាគារជាតិនៃកម្ពុជា បានចេញប្រកាស លេខ ធ7-023-005 ប្រ.ក. តម្រូវឱ្យធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ មានទុនបម្រុងកាតព្វកិច្ច នៅធនាគារជាតិនៃកម្ពុជាជាទម្រុងប្រាក់តម្កល់តាមច្បាប់តាមអត្រា 9% និង 12.50 % ចំពោះរូបិយបណ្ណបរទេសលើប្រាក់បញ្ញើ និងប្រាក់កម្ចី មានប្រសិទ្ធភាពចាប់ពីថ្ងៃទី1 ខែមករា ឆ្នាំ2023 ដល់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 និង ចាប់ពីថ្ងៃទី1 ខែមករា ឆ្នាំ2024 តទៅ។ ចំពោះរូបិយប័ណ្ណជាប្រាក់រៀលនៅរក្សាអត្រា 7% ដដែល។

បន្ទាប់មកនាថ្ងៃទី23 ខែវិច្ឆិកា ឆ្នាំ2023 ធនាគារជាតិនៃកម្ពុជាបានអនុម័តលើប្រាក់បម្រុងកាតព្វកិច្ចតាមអត្រា 7% ចំពោះរូបិយប័ណ្ណបរទេសលើប្រាក់បញ្ញើ និងកម្ចីរហូតដល់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024។

8. ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន - សុទ្ធ

	2023		2022	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 2.4)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 2.4)
ឥណទានពាណិជ្ជកម្ម៖				
ឥណទានវិបារូបន៍	5,933,166	24,236,983	9,209,000	37,913,453
ឥណទានរយៈពេលខ្លី	12,997,472	53,094,673	2,024,994	8,336,900
ឥណទានរយៈពេលវែង	16,959,101	69,277,928	-	-
ឥណទានអ្នកប្រើប្រាស់៖				
កាតឥណទាន	342,291	1,398,259	276,479	1,138,264
ឥណទានវិបារូបន៍	20,496,732	83,729,150	25,699,578	105,805,163
ឥណទានរយៈពេលខ្លី	29,371,910	119,984,252	3,499,671	14,408,146
ឥណទានរយៈពេលវែង	85,137,509	347,786,724	77,803,426	320,316,704
ឥណទានសម្ព័ន្ធញាតិ	**-**	**-**	**1,016,675**	**4,185,651**
សរុបឥណទាន - ដុល	**171,238,181**	**699,507,969**	**119,529,823**	**492,104,281**
ដកៈសំវិធានធននៃការខាតបង់លើឱនភាពនៃតម្លៃ	(1,959,373)	(8,004,038)	(2,340,169)	(9,634,475)
ឥណទាន និងបុរេប្រទានផ្តល់ដល់អថិតិជន-សុទ្ធ	**169,278,808**	**691,503,931**	**117,189,654**	**482,469,806**

សំវិធានធនលើការខាតបង់លើឱនភាពនៃតម្លៃ ដែលបានទទួលស្គាល់ក្នុងចំណេញ ឬខាតត្រូវបានសង្ខេបដូចខាងក្រោម៖

	2023		2022	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 2.4)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 2.4)
(តំហយ)/កំណើនការខាតបង់សុទ្ធលើឱនភាពនៃតម្លៃលើឥណទាន និងបុរេប្រទាន	(380,796)	(1,565,072)	929,738	3,799,839
តំហយលើការខាតបង់សុទ្ធលើឱនភាពនៃតម្លៃលើសមតុល្យនៅធនាគារផ្សេងៗ (កំណត់សម្គាល់ 5)	(235,433)	(967,630)	(239,409)	(978,465)
ការខាតបង់សុទ្ធលើឱនភាពនៃតម្លៃនៃប្រាក់បញ្ញើនៅធនាគារផ្សេងៗ (កំណត់សម្គាល់ 6)	303,462	1,247,229	-	-
ការខាតបង់សុទ្ធលើឱនភាពនៃតម្លៃលើកិច្ចសន្យាក្រៅតារាងតុល្យការ	29,886	122,832	10,660	43,567
(តំហយ)/កំណើនការខាតបង់សុទ្ធលើឱនភាពនៃតម្លៃលើការវិនិយោគផ្សេងៗ (កំណត់សម្គាល់ 9)	(199,155)	(818,527)	59,180	241,869
	(482,036)	**(1,981,168)**	**760,169**	**3,106,810**

បម្រែបម្រួលនៃសំវិធានធនលើការខាតបង់លើឱនភាពនៃតម្លៃនៃឥណទាន និងបុរេប្រទានមានដូចខាងក្រោម៖

	2023		2022	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 2.4)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 2.4)
នាថ្ងៃទី1 ខែមករា	2,340,169	9,634,475	1,410,431	5,746,096
(តំហយ)/បន្ថែមសំវិធានធនក្នុងការិយបរិច្ឆេទ	(380,796)	(1,565,072)	929,738	3,799,839
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	(65,365)	-	88,540
នាថ្ងៃទី31 ខែធ្នូ	**1,959,373**	**8,004,038**	**2,340,169**	**9,634,475**

(ក) តាមប្រភេទឧស្សាហកម្ម៖

	2023		2022	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 2.4)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 2.4)
អចលនទ្រព្យ និងបញ្ចាំ	87,064,453	355,658,291	84,750,645	348,918,405
កម្ចីឯកជន	14,773	60,348	31,479	129,599
អគារ និងសំណង់	40,716,607	166,327,340	2,672,309	11,001,896
សេវាកម្ម	4,656,939	19,023,596	211,611	871,202
កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	3,971,667	16,224,260	-	-
គ្រឹះស្ថានហិរញ្ញវត្ថុ	1,112,471	4,544,444	452,798	1,864,169
	28,536,888	**6,107,142**	**34,735,896**	**33,683,129**	**83,534,202**	**12,175,444**	**292,150,754**	**490,923,455**	**2,005,422,313**	
បំណុលហិរញ្ញវត្ថុ										
ប្រាក់បញ្ញើរបស់អតិថិជន	198,523,661	12,544,848	26,391,051	15,843,299	284,015	-	-	253,586,874	1,035,902,380	0.5% - 9%
ប្រាក់បញ្ញើរបស់ធនាគារ	173,996,647	7,531,644	-	-	-	-	-	181,528,291	741,543,069	0.5% - 9%
បំណុលភតិសន្យា	-	-	-	598,166	7,349,367	-	-	7,947,533	32,465,672	6%
បំណុលផ្សេងៗ *	-	-	-	-	-	-	-	389,591	1,591,479	គ្មាន
បំណុលហិរញ្ញវត្ថុសរុប	**372,520,308**	**20,076,492**	**26,391,051**	**16,441,465**	**7,633,382**	**-**	**-**	**443,452,289**	**1,811,502,600**	
សរុបគំលាតការប្រាក់	**(343,983,420)**	**(13,969,350)**	**8,344,845**	**17,241,664**	**75,900,820**	**12,175,444**	**292,150,754**	**47,471,166**	**193,919,713**	

(*) មិនរាប់បញ្ចូលចំណាយបង់ឱ្យអាជ្ញាធរពន្ធដារ និងចំណាយបង់មុន។

2022	រហូតដល់ 1 ខែ	> 1 – 3 ខែ	> 3 – 6 ខែ	> 6 – 12 ខែ	> 1 – 5 ឆ្នាំ	លើសពី 5 ឆ្នាំ	ពុំមាន ការប្រាក់	សរុប		អត្រា ការប្រាក់
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 2.4)	%
ទ្រព្យសកម្មហិរញ្ញវត្ថុ										
សាច់ប្រាក់ និង សមតុល្យធនាគារ-ដុល	-	3,319,503	-	-	-	-	121,174,058	124,493,561	512,539,991	1% - 6%
ប្រាក់តម្កល់តាមបទប្បញ្ញត្តិ	-	-	-	-	-	7,500,000	16,371,072	23,871,072	98,277,203	0% - 0.04%
ឥណទាន និង បុរេប្រទានផ្តល់ដល់អតិថិជន - ដុល	20,133,118	24,339,675	840,187	62,417,105	7,677,260	1,211,096	2,911,382	119,529,823	492,104,281	5% - 12%
ការវិនិយោគផ្សេងៗ - ដុល	-	-	35,502,167	-	-	-	-	35,502,167	146,162,422	6%
ប្រាក់តម្កល់ធានា	-	-	-	-	-	-	1,802,192	1,802,192	7,419,624	គ្មាន
	20,133,118	**27,659,178**	**36,342,354**	**62,417,105**	**7,677,260**	**8,711,096**	**142,258,704**	**305,198,815**	**1,256,503,521**	
បំណុលហិរញ្ញវត្ថុ										
ប្រាក់បញ្ញើរបស់អតិថិជន	94,470,852	36,630,456	22,201,869	40,013,720	2,977,904	-	26,634,430	222,929,231	917,799,644	1%- 6.25%
ប្រាក់បញ្ញើរបស់ធនាគារ	2,290,078	7,525,041	3,088,849	-	-	-	14,265,575	27,169,543	111,857,009	2.5%- 5%
បំណុលភតិសន្យា	15,734	58,760	89,246	173,149	1,659,438	1,369,248	-	3,365,575	13,856,072	6%
បំណុលផ្សេងៗ *	-	-	-	-	-	-	209,200	209,200	861,276	គ្មាន
បំណុលហិរញ្ញវត្ថុសរុប	**96,776,664**	**44,214,257**	**25,379,964**	**40,186,869**	**4,637,342**	**1,369,248**	**41,109,205**	**253,673,549**	**1,044,374,001**	
សរុបគំលាតការប្រាក់	**(76,643,546)**	**(16,555,079)**	**10,962,390**	**22,230,236**	**3,039,918**	**7,341,848**	**101,149,499**	**51,525,266**	**212,129,520**	

(*) មិនរាប់បញ្ចូលចំណាយបង់ឱ្យអាជ្ញាធរពន្ធដារ និងចំណាយបង់មុន។

ហានិភ័យរូបិយប័ណ្ណបរទេស

ហានិភ័យរូបិយប័ណ្ណ គឺជាហានិភ័យដែលតម្លៃនៃឧបករណ៍ហិរញ្ញវត្ថុមានការប្រែប្រួលល បណ្តាលមកពីការប្រែប្រួល អត្រាប្តូររូបិយប័ណ្ណបរទេស។

ការប្រមូលផ្តុំហានិភ័យរូបិយប័ណ្ណ

ចំនួនទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុ តាមប្រភេទនៃរូបិយប័ណ្ណមានដូចខាងក្រោម៖

ប្រភេទនៃរូបិយប័ណ្ណ					
សមមូលដុល្លារអាមេរិក					
2023	រៀល	ដុល្លារអាមេរិក	ផ្សេងៗ	សរុប	
				ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 2.4)
ទ្រព្យសកម្មហិរញ្ញវត្ថុ					
សាច់ប្រាក់ និងសមតុល្យធនាគារ-ដុល	2,065,270	257,570,698	63,375	259,699,343	1,060,871,816
ប្រាក់បញ្ញើនៅធនាគារផ្សេងៗ-ដុល	-	20,034,520	-	20,034,520	81,841,014
ប្រាក់តម្កល់តាមបទប្បញ្ញត្តិ	6,218	36,865,000	-	36,871,218	150,618,926
ឥណទាន និងបុរេប្រទាន ផ្តល់ដល់អតិថិជន - ដុល	17,125,983	154,112,198	-	171,238,181	699,507,969
ប្រាក់តម្កល់ធានា	-	3,080,193	-	3,080,193	12,582,588
ទ្រព្យសកម្មហិរញ្ញវត្ថុសរុប	**19,197,471**	**471,662,609**	**63,375**	**490,923,455**	**2,005,422,313**
បំណុលហិរញ្ញវត្ថុ					
ប្រាក់បញ្ញើរបស់អតិថិជន	54,227	253,532,647	-	253,586,874	1,035,902,380
ប្រាក់បញ្ញើរបស់ធនាគារ	4,826	181,523,465	-	181,528,291	741,543,069
បំណុលភតិសន្យា	-	7,947,533	-	7,947,533	32,465,672
បំណុលផ្សេងៗ (*)	-	389,591	-	389,591	1,591,479
បំណុលហិរញ្ញវត្ថុសរុប	**59,053**	**443,393,236**	**-**	**443,452,289**	**1,811,502,600**
ស្ថានភាពទ្រព្យសកម្មសុទ្ធ	**19,138,418**	**28,269,373**	**63,375**	**47,471,166**	**193,919,713**

(*) មិនរាប់បញ្ចូលចំណាយបង់ឱ្យអាជ្ញាធរពន្ធដារ និងចំណាយបង់មុន។

ប្រភេទនៃរូបិយប័ណ្ណ					
សមមូលដុល្លារអាមេរិក					
2022	រៀល	ដុល្លារអាមេរិក	ផ្សេងៗ	សរុប	
				ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 2.4)
ទ្រព្យសកម្មហិរញ្ញវត្ថុ					
សាច់ប្រាក់ និងសមតុល្យធនាគារ-ដុល	600,399	123,825,667	67,495	124,493,561	512,539,991
ប្រាក់តម្កល់តាមបទប្បញ្ញត្តិ	6,072	23,865,000	-	23,871,072	98,277,203
ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន - ដុល	13,987,569	105,542,254	-	119,529,823	492,104,281
ការវិនិយោគផ្សេងៗ-ដុល	-	35,502,167	-	35,502,167	146,162,422
ប្រាក់តម្កល់ធានា	-	1,802,192	-	1,802,192	7,419,624
ទ្រព្យសកម្មហិរញ្ញវត្ថុសរុប	**14,594,040**	**290,537,280**	**67,495**	**305,198,815**	**1,256,503,521**
បំណុលហិរញ្ញវត្ថុ					
ប្រាក់បញ្ញើរបស់អតិថិជន	37,316	222,891,915	-	222,929,231	917,799,644
ប្រាក់បញ្ញើរបស់ធនាគារ	2,377	27,167,166	-	27,169,543	111,857,009
បំណុលភតិសន្យា	-	3,365,575	-	3,365,575	13,856,072
បំណុលផ្សេងៗ (*)	-	209,200	-	209,200	861,276
បំណុលហិរញ្ញវត្ថុសរុប	**39,693**	**253,633,856**	**-**	**253,673,549**	**1,044,374,001**
ស្ថានភាពទ្រព្យសកម្មសុទ្ធ	**14,554,347**	**36,903,424**	**67,495**	**51,525,266**	**212,129,520**

(*) មិនរាប់បញ្ចូលចំណាយបង់ឱ្យអាជ្ញាធរពន្ធដារ និងចំណាយបង់មុន។

ការវិភាគលើបម្រែបម្រួល

សន្មតថា ហានិភ័យអថេរផ្សេងទៀតនៅតែថេរជានិច្ច ការប្រែប្រួលនៃការប្តូររូបិយប័ណ្ណបរទេស សម្រាប់ធនាគារនា កាលបរិច្ឆេទរាយការណ៍ត្រូវបានសង្ខេបដូចខាងក្រោម (ដោយបង្ហាញតែរូបិយប័ណ្ណដែលមានចំនួនច្រើនជាង 5% នៃស្ថានភាពចំហសុទ្ធ ត្រូវបានបង្ហាញជារូបិយប័ណ្ណជាក់លាក់របស់វានៅក្នុងតារាងខាងក្រោម។ សម្រាប់រូបិយប័ណ្ណផ្សេងទៀត ការលាតត្រដាងទាំងនេះត្រូវបានដាក់ជាក្រុម “ផ្សេងៗ”)៖

	2023		2022	
	- 1% ការថយចុះ ដុល្លារអាមេរិក	+ 1% ការកើនឡើង ដុល្លារអាមេរិក	- 1% ការថយចុះ ដុល្លារអាមេរិក	+ 1% ការកើនឡើង ដុល្លារអាមេរិក
ប្រាក់រៀល	(191,384)	191,384	(145,543)	145,543
ផ្សេងៗ	(634)	634	(675)	675
	(192,018)	**192,018**	**(146,218)**	**146,218**
សមមូលពាន់រៀល (កំណត់សម្គាល់ 2.4)	**(784,394)**	**784,394**	**(601,980)**	**601,980**

(គ)   ហានិភ័យសាច់ប្រាក់ងាយស្រួល

“ហានិភ័យសាច់ប្រាក់ងាយស្រួល” គឺជាហានិភ័យដែលធនាគារនឹងជួបផលលំបាកក្នុងការបំពេញកាតព្វកិច្ចពាក់ព័ន្ធនឹងបំណុលហិរញ្ញវត្ថុរបស់ខ្លួន ដែលត្រូវបានទូទាត់តាមរយៈជាសាច់ប្រាក់ ឬទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងទៀត។ ហានិភ័យសាច់ប្រាក់ងាយស្រួល កើតឡើងពីភាពមិនស៊ីគ្នាទៅនឹងពេលវេលា និងចំនួនលំហូរសាច់ប្រាក់ដែលមាននៅក្នុងប្រតិបត្តិការ និងការវិនិយោគរបស់ធនាគារ។

ការគ្រប់គ្រងហានិភ័យសាច់ប្រាក់ងាយស្រួល

ធនាគារ គ្រប់គ្រងសាច់ប្រាក់ងាយស្រួលរបស់ខ្លួនតាមរយៈគណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម បំណុល ដែលទទួលខុសត្រូវក្នុងការបង្កើតគោលនយោបាយសាច់ប្រាក់ងាយស្រួល និងត្រួតពិនិត្យសាច់ប្រាក់ងាយស្រួលជាប្រចាំ។ តម្រូវការទ្រព្យសកម្មងាយស្រួលអប្បបរមា ត្រូវបានបង្កើតឡើងដើម្បីធានាថាអនុបាតនៃទ្រព្យសកម្មងាយស្រួល និងបំណុលដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ត្រូវទទួលបានកម្រិតអប្បបរមាគ្រប់ពេលវេលា។

តារាងខាងក្រោមសង្ខេបពីទ្រព្យសកម្ម និងបំណុលរបស់ធនាគារ ដោយផ្អែកលើឥណប្រតិទាន តាមកិច្ចសន្យាដែលនៅសល់។ លំហូរសាច់ប្រាក់ដែលបានរំពឹងទុកលើទ្រព្យសកម្ម និងបំណុលទាំងនេះ អាចខុសជាសារវន្តពីអ្វីដែលបានបង្ហាញនៅក្នុងតារាង។ ឧទាហរណ៍ ប្រាក់បញ្ញើរបស់អតិថិជនមិនត្រូវបានរំពឹងថានឹងត្រូវដកបានភ្លាមៗនោះទេ។

2023	រហូតដល់ 1 ខែ	> 1 – 3 ខែ	> 3 – 6 ខែ	> 6 – 12 ខែ	> 1 – 5 ឆ្នាំ	លើសពី 5 ឆ្នាំ	ពុំមាន ការប្រាក់	សរុប	
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 2.4)
បំណុលហិរញ្ញវត្ថុ									
ប្រាក់បញ្ញើរបស់អតិថិជន	198,523,661	12,544,848	26,391,051	15,843,299	284,015	-	-	253,586,874	1,035,902,380
ប្រាក់បញ្ញើរបស់ធនាគារ	173,996,647	7,531,644	-	-	-	-	-	181,528,291	741,543,069
បំណុលភតិសន្យា - មិនអប្បហារ	-	-	-	598,166	7,349,367	-	-	7,947,533	32,465,672
បំណុលហិរញ្ញវត្ថុសរុប	**372,520,308**	**20,076,492**	**26,391,051**	**16,441,465**	**7,633,382**	**-**	**-**	**443,062,698**	**1,809,911,121**
ទ្រព្យសកម្មហិរញ្ញវត្ថុ									
សាច់ប្រាក់ និងសមតុល្យធនាគារ-ដុល	-	-	-	-	-	-	259,699,343	259,699,343	1,060,871,816
ប្រាក់តម្កល់តាមបទប្បញ្ញត្តិ	-	-	-	-	-	7,500,000	29,371,218	36,871,218	150,618,926
ប្រាក់បញ្ញើនៅធនាគារផ្សេងៗ-ដុល	-	-	-	20,034,520	-	-	-	20,034,520	81,841,014
ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន - ដុល	28,536,888	6,107,142	34,735,896	13,648,609	83,534,202	4,675,444	-	171,238,181	699,507,969
ប្រាក់តម្កល់ធានា	-	-	-	-	-	-	3,080,193	3,080,193	12,582,588
ទ្រព្យសកម្មហិរញ្ញវត្ថុសរុប	**28,536,888**	**6,107,142**	**34,735,896**	**33,683,129**	**83,534,202**	**12,175,444**	**292,150,754**	**490,923,455**	**2,005,422,313**
គំលាតវិភាគអាយុកាល	**(343,983,420)**	**(13,969,350)**	**8,344,845**	**17,241,664**	**75,900,820**	**12,175,444**	**292,150,754**	**47,860,757**	**195,511,192**

2022	រហូតដល់ 1 ខែ	> 1 – 3 ខែ	> 3 – 6 ខែ	> 6 – 12 ខែ	> 1 – 5 ឆ្នាំ	លើសពី 5 ឆ្នាំ	ពុំមាន ការប្រាក់	សរុប	
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល
									(កំណត់សម្គាល់ 2.4)
បំណុលហិរញ្ញវត្ថុ									
ប្រាក់បញ្ញើរបស់អតិថិជន	57,498,635	36,630,456	22,201,869	40,013,720	2,977,904	-	63,606,647	222,929,231	917,799,644
ប្រាក់បញ្ញើរបស់ធនាគារ	2,102,082	7,525,041	3,088,849	-	-	-	14,453,571	27,169,543	111,857,009
បំណុលភតិសន្យា - មិនអប្បហារ	32,562	92,112	138,168	266,983	2,704,772	1,064,000	-	4,298,597	17,697,324
បំណុលផ្សេងៗ (*)	-	-	-	-	-	-	209,200	209,200	861,276
បំណុលហិរញ្ញវត្ថុសរុប	**59,633,279**	**44,247,609**	**25,428,886**	**40,280,703**	**5,682,676**	**1,064,000**	**78,269,418**	**254,606,571**	**1,048,215,253**
ទ្រព្យសកម្មហិរញ្ញវត្ថុ									
សាច់ប្រាក់ និងសមតុល្យធនាគារ-ដុល	-	3,319,503	-	-	-	-	121,174,058	124,493,561	512,539,991
ប្រាក់តម្កល់តាមបទប្បញ្ញត្តិ	-	-	-	-	-	7,500,000	16,371,072	23,871,072	98,277,203
ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន - ដុល	20,133,118	24,339,675	840,187	62,417,105	7,677,260	1,211,096	2,911,382	119,529,823	492,104,281
ការវិនិយោគផ្សេងៗ-ដុល	-	-	35,502,167	-	-	-	-	35,502,167	146,162,422
ប្រាក់តម្កល់ធានា	-	-	-	-	-	-	1,802,192	1,802,192	7,419,624
ទ្រព្យសកម្មហិរញ្ញវត្ថុសរុប	**20,133,118**	**27,659,178**	**36,342,354**	**62,417,105**	**7,677,260**	**8,711,096**	**142,258,704**	**305,198,815**	**1,256,503,521**
គំលាតវិភាគអាយុកាល	**(39,500,161)**	**(16,588,431)**	**10,913,468**	**22,136,402**	**1,994,584**	**7,647,096**	**63,989,286**	**50,592,244**	**208,288,268**

(*) មិនរាប់បញ្ចូលចំណាយបង់ឱ្យអាជ្ញាធរពន្ធដារ និងចំណាយបង់មុន។

(ឃ) តម្លៃសមស្របនៃទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុ

តម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុរបស់ធនាគារ មានដូចជាសាច់ប្រាក់ និងទុនរយៈពេលខ្លី សមតុល្យជាមួយធនាគារ ប្រាក់បញ្ញើជាមួយធនាគារផ្សេងៗ ប្រាក់បញ្ញើរបស់អតិថិជន និងធនាគារនានា ទ្រព្យសកម្មផ្សេងៗ និងបំណុលផ្សេងៗ និងប្រាក់កម្ចីរយៈពេលខ្លី មិនមានបម្រែបម្រួលជាសារវន្តចំពោះការផ្លាស់ប្តូរអត្រាប្រាក់ចំណេញក្នុង ទីផ្សារដោយសារតែឧបករណ៍ហិរញ្ញវត្ថុទាំងនេះមានរយៈពេលកំណត់ជាក់លាក់។ តម្លៃយោងនៃទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុទាំងនេះ នៅកាលបរិច្ឆេទរាយការណ៍មានតម្លៃប្រហាក់ប្រហែលនឹងតម្លៃសមស្របរបស់វា។

(ង) ហានិភ័យប្រតិបត្តិការ

ហានិភ័យប្រតិបត្តិការ គឺជាហានិភ័យនៃការបាត់បង់ដោយផ្ទាល់ ឬដោយប្រយោលដែលកើតមានឡើងពីការខ្វះខាត ឬការអនុវត្តមិនមានប្រសិទ្ធភាពនូវនីតិវិធីដំណើរការផ្ទៃក្នុង បុគ្គលិក បច្ចេកវិទ្យា ហេដ្ឋារចនាសម្ព័ន្ធ និងពីកត្តាខាងក្រៅ ក្រៅពីហានិភ័យឥណទាន ហានិភ័យទីផ្សារ និងហានិភ័យសាច់ប្រាក់ងាយស្រួល ទាំងនេះរួមមានហានិភ័យខាងផ្នែកច្បាប់ និងបទប្បញ្ញត្តិ និងស្តង់ដារទទួលយកជាទូទៅនៃឥរិយាបថសាជីវកម្ម។

ការគ្រប់គ្រងលើហានិភ័យប្រតិបត្តិការរបស់ធនាគារ តម្រូវឱ្យបង្កើតនូវរចនាសម្ព័ន្ធតួនាទី និងវិធីសាស្ត្រនៃការគ្រប់គ្រងរបស់អង្គភាពឱ្យបានច្បាស់លាស់។ គោលការណ៍ និងវិធានការត្រួតពិនិត្យផ្ទៃក្នុងជាច្រើនត្រូវបានអនុវត្តរួមមានការបង្កើតអ្នកមានសិទ្ធិចុះហត្ថលេខា ប្រព័ន្ធត្រួតពិនិត្យយ៉ាងហ្មត់ចត់លើការរៀបចំនូវនីតិវិធី និងឯកសារសំអាងនានា ព្រមទាំងការអនុវត្តតាមបទប្បញ្ញត្តិ និងតម្រូវការតាមច្បាប់នានា។

(ច) **ការគ្រប់គ្រងដើមទុន**

ដើមទុនតាមបទប្បញ្ញត្តិ

គោលដៅរបស់ធនាគារក្នុងការគ្រប់គ្រងដើមទុន មានន័យទូលំទូលាយជាង "មូលធន" ដែលបង្ហាញក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។ ការគ្រប់គ្រងដើមទុនមានដូចខាងក្រោម៖

- អនុលោមតាមតម្រូវការដើមទុនដែលកំណត់ដោយធនាគារជាតិ
- ការពារលទ្ធភាពរបស់ធនាគារដើម្បីបន្តនិរន្តរភាពអាជីវកម្ម ដូចនេះ ធនាគារអាចបន្តផ្តល់ផលប្រយោជន៍ដល់ភាគទុនិក និងអត្ថប្រយោជន៍របស់ភាគីដែលពាក់ព័ន្ធនឹងធនាគារ និង
- រក្សាមូលដ្ឋានដើមទុនរឹងមាំ ដើម្បីគាំទ្រដល់ការអភិវឌ្ឍអាជីវកម្ម។

គោលនយោបាយរបស់ធនាគារ គឺធានាឱ្យបាននូវមូលដ្ឋានដើមទុនរឹងមាំដើម្បីរក្សានូវទំនុកចិត្តទីផ្សារ និងដើម្បីធានាស្ថេរភាពនៃការអភិវឌ្ឍយូរអង្វែងរបស់អាជីវកម្ម។ ផលប៉ះពាល់ទៅលើកម្រិតដើមទុនលើភាគលាភរបស់ ភាគទុនិកក៏ត្រូវបានទទួលស្គាល់ ហើយធនាគារបានទទួលស្គាល់នូវតម្រូវការដើម្បីធានាបាននូវតុល្យភាពរវាងភាគលាភខ្ពស់ដែលអាចនឹងកើតមានឡើងជាមួយនឹងប្រាក់បម្រុងកម្រិតខ្ពស់អត្ថប្រយោជន៍ និងការធានាដែលផ្តល់ដោយស្ថានភាពដើមទុនល្អ។

ការបែងចែកដើមទុន

ការបែងចែកដើមទុនរវាងប្រតិបត្តិការ និងសកម្មភាពជាក់លាក់ គឺត្រូវបានគ្រប់គ្រងដោយកម្រិតភាគលាភដែលទទួលបានពីការបែងចែកនោះ។ ដើមទុនដែលបានបែងចែកទៅតាមប្រតិបត្តិការ ឬសកម្មភាពនីមួយៗ ត្រូវផ្អែកទៅតាមដើមទុនដែលកំណត់ដោយច្បាប់។

29. គោលនយោបាយគណនេយ្យសារវន្ត

29.1 ប្រតិបត្តិការរូបិយប័ណ្ណបរទេស

ប្រតិបត្តិការជារូបិយប័ណ្ណផ្សេងទៀតក្រៅពីដុល្លារអាមេរិក ត្រូវបានប្តូរទៅជាដុល្លារអាមេរិកតាមអត្រាប្តូរប្រាក់ដែលកំណត់តាមកាលបរិច្ឆេទនៃប្រតិបត្តិការ។ ទ្រព្យសកម្មរូបិយវត្ថុ និងបំណុលដែលគិតជារូបិយប័ណ្ណក្រៅពីប្រាក់ដុល្លារអាមេរិកនៅពេលកាលបរិច្ឆេទ ត្រូវបានប្តូរទៅជាដុល្លារអាមេរិកតាមអត្រាប្តូរប្រាក់ដែលបានកំណត់នៅ កាលបរិច្ឆេទនោះ។ លម្អៀងការប្តូរប្រាក់ដែលកើតឡើងត្រូវបានទទួលស្គាល់នៅក្នុងប្រាក់ចំណេញ ឬខាត។ វត្ថុមិនមែនរូបិយវត្ថុ ដែលត្រូវបានវាស់វែងដោយផ្អែកលើមូលដ្ឋានតម្លៃដើមជារូបិយប័ណ្ណបរទេសមិនត្រូវបានប្តូរទេ។

29.2 ឧបករណ៍ហិរញ្ញវត្ថុ

(ក) **ការទទួលស្គាល់ និងការឈប់ទទួលស្គាល់**

ឧបករណ៍ហិរញ្ញវត្ថុ ដែលរួមមានទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នៅពេលដែលធនាគារក្លាយជាភាគីនៃកិច្ចសន្យានៃឧបករណ៍នេះ។

ធនាគារ ឈប់ទទួលស្គាល់ ទ្រព្យសកម្មហិរញ្ញវត្ថុនៅពេលដែលកិច្ចសន្យាក្នុងការទទួលបានសាច់ប្រាក់ផុតកំណត់ ឬពេលផ្ទេរសិទ្ធិទទួលលំហូរសាច់ប្រាក់តាមកិច្ចសន្យាក្នុងប្រតិបត្តិការដែលហានិភ័យ និងសគុណជាម្ចាស់កម្មសិទ្ធិលើទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានផ្ទេរ ឬនៅពេលមិនមានការផ្ទេរ ឬរក្សាទុកនូវរាល់ហានិភ័យ និងសគុណនៃភាពជាម្ចាស់ និងបាត់បង់ការគ្រប់គ្រង។ នៅពេលការគ្រប់គ្រងត្រូវបានរក្សាទុក ធនាគារនៅតែបន្តទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ ត្រឹមកម្រិតនៃការបន្តចូលរួមគ្រប់គ្រងរបស់ខ្លួន។

ធនាគារ ឈប់ទទួលស្គាល់បំណុលហិរញ្ញវត្ថុ នៅពេលកាតព្វកិច្ចនៃកិច្ចសន្យាត្រូវបានរំសាយ លុបចោល ឬផុតកំណត់។

ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុត្រូវបានកាត់កង ហើយចំនួនទឹកប្រាក់សុទ្ធបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ តែនៅពេលបច្ចុប្បន្នធនាគារ មានសិទ្ធិអនុវត្តតាមច្បាប់ក្នុងការកំណត់បរិមាណដែលបានទទួលស្គាល់ ហើយមានបំណងទូទាត់ប្រាក់ទាំងនោះដោយផ្អែកលើមូលដ្ឋានសុទ្ធ ឬបញ្ចេញទ្រព្យ និងទូទាត់បំណុលក្នុងពេលដំណាលគ្នា។

(ខ) ការចាត់ថ្នាក់ និងការវាស់វែង

រាល់ទ្រព្យកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ទាំងអស់ត្រូវបានទទួលស្គាល់ដំបូងតាមតម្លៃសមស្រប ដែលជាធម្មតាគឺជាថ្លៃប្រតិបត្តិការបូក (បើសមស្រប) ចំណាយប្រតិបត្តិការ។

នៅក្នុងការទទួលស្គាល់ដំបូង ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានចាត់ថ្នាក់តាមការវាស់វែងៈ រំលស់ថ្លៃដើមលើតម្លៃសមស្របរួមនឹងចំណូលដទៃផ្សេងទៀត ("FVOCI") ឬរំលស់ថ្លៃដើមលើតម្លៃសមស្របរួមនឹងប្រាក់ចំណេញ ឬខាតសុទ្ធ ("FVTPL")។

ទ្រព្យសកម្មហិរញ្ញវត្ថុដែលវាស់វែងតាមរំលស់ថ្លៃដើម កើតឡើងពីកិច្ចសន្យាដែលធ្វើឱ្យមានលំហូរសាច់ប្រាក់តាមកិច្ចសន្យា ដែលបានធ្វើឡើងតាមគំរូអាជីវកម្មដែលកាន់កាប់ទ្រព្យសកម្មដើម្បីប្រមូលលំហូរសាច់ប្រាក់តាមកិច្ចសន្យា។

ទ្រព្យសកម្មហិរញ្ញវត្ថុដែលវាស់វែងតាមរំលស់ថ្លៃដើម (AC)៖

ទាំងនេះត្រូវបានវាស់ក្នុងចំណាយរំលស់ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព និងអាចមានការខាតបង់លើ ឱនភាពនៃតម្លៃ (សូមមើលខាងក្រោម)។

បំណុលហិរញ្ញវត្ថុដែលវាស់វែងតាមរំលស់ថ្លៃដើម៖

បំណុលហិរញ្ញវត្ថុត្រូវបានវាស់ក្នុងចំណាយរំលស់ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។

ទ្រព្យសកម្មហិរញ្ញវត្ថុ - ការវាយតម្លៃគំរូអាជីវកម្ម

ធនាគារ ធ្វើការវាយតម្លៃលើគោលបំណងនៃគំរូអាជីវកម្ម ដែលទ្រព្យសកម្មហិរញ្ញវត្ថុបានកាន់កាប់នៅកម្រិតមួយ ដោយសារតែវាជាការឆ្លុះបញ្ចាំងដ៏ល្អបំផុត ពីរបៀបគ្រប់គ្រងអាជីវកម្ម និងផ្តល់ព័ត៌មានជូនដល់អ្នកគ្រប់គ្រង។

ទ្រព្យសកម្មហិរញ្ញវត្ថុ - ការវាយតម្លៃតើលំហូរសាច់ប្រាក់តាមកិច្ចសន្យាគឺជាការទូទាត់ប្រាក់ដើមនិងការប្រាក់តែប៉ុណ្ណោះ ("SPPI")៖

សម្រាប់គោលបំណងនៃការវាយតម្លៃនេះ 'ប្រាក់ដើម' ត្រូវបានកំណត់តាមតម្លៃសមស្រប នៃទ្រព្យសកម្មហិរញ្ញវត្ថុ លើការទទួលស្គាល់ដំបូង។ 'ការប្រាក់' ត្រូវបានកំណត់ជាសាច់ប្រាក់សម្រាប់តម្លៃពេលវេលា និងសម្រាប់ហានិភ័យឥណទាន ជាមួយប្រាក់ដើម ដែលនៅមិនទាន់បានទូទាត់ក្នុងអំឡុងពេលជាក់លាក់ណាមួយ និងសម្រាប់ហានិភ័យកម្ចី និងថ្លៃចំណាយ (ឧទាហរណ៍៖ ហានិភ័យសាច់ប្រាក់ និងចំណាយរដ្ឋបាល) និងកម្រិតប្រាក់ចំណេញ។

ក្នុងការវាយតម្លៃថាតើលំហូរសាច់ប្រាក់តាមកិច្ចសន្យា គឺជាការទូទាត់សងតែមួយគត់សម្រាប់ប្រាក់ដើម និងការប្រាក់ ធនាគារពិចារណាលក្ខខណ្ឌកិច្ចសន្យានៃឧបករណ៍នេះ។ នេះរួមបញ្ចូលទាំងការវាយតម្លៃថាតើទ្រព្យសកម្មហិរញ្ញវត្ថុមានរួមបញ្ចូលលក្ខខណ្ឌកិច្ចសន្យា ដែលអាចផ្លាស់ប្តូរពេលវេលា ឬចំនួននៃលំហូរសាច់ប្រាក់កិច្ចសន្យាដែលវានឹងមិនបំពេញលក្ខខណ្ឌទាំងនេះ។

ក្នុងការវាយតម្លៃនេះធនាគារពិចារណាដូចខាងក្រោម៖

- ព្រឹត្តិការណ៍យថាភាព ដែលអាចនឹងផ្លាស់ប្តូរចំនួនទឹកប្រាក់ ឬពេលវេលានៃលំហូរសាច់ប្រាក់
- លក្ខខណ្ឌដែលអាចប្រែសម្រួលអត្រាគូប៉ុងកិច្ចសន្យា រួមទាំងអត្រាអថេរនៃលក្ខណៈពិសេស
- ការបង់ប្រាក់មុន និងការពន្យារលក្ខណៈពិសេស និង
- លក្ខខណ្ឌដែលកំណត់ការទាមទារសំណង ចំពោះលំហូរសាច់ប្រាក់ពីទ្រព្យជាក់លាក់របស់ធនាគា (ឧទាហរណ៍ លក្ខណៈពិសេសដែលមិនអាចប្រមូលវិញបាន)។

លក្ខណៈទូទាត់មុនពិសេស គឺស្របជាមួយនឹងការទូទាត់លើប្រាក់ដើម និងការប្រាក់ ប្រសិនបើចំនួននៃការទូទាត់មុន តំណាងឱ្យចំនួនសារវន្តនៃប្រាក់ដើមនិងការប្រាក់ដែលមិនបានបង់ ទៅលើចំនួនប្រាក់ដើមនៅសល់ ដែលអាចរួមបញ្ចូលសំណងបន្ថែមសម្រាប់ការបញ្ចប់កិច្ចសន្យាមុន។

ការចាត់ចំណាត់ថ្នាក់ឡើងវិញ

ទ្រព្យសកម្មហិរញ្ញវត្ថុមិនត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញ បន្ទាប់ពីការទទួលស្គាល់តម្លៃដំបូងឡើយ លើកលែងតែក្នុងអំឡុងពេលដែលធនាគារផ្លាស់ប្តូរគំរូអាជីវកម្មរបស់ខ្លួន ក្នុងការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ។

(គ) ការកែប្រែទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ

ប្រសិនបើលក្ខខណ្ឌនៃទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានកែប្រែ នោះធនាគារវាយតម្លៃថាតើលំហូរទឹកប្រាក់នៃទ្រព្យសកម្មដែលបានកែប្រែនោះ មានភាពខុសគ្នាខ្លាំង ឬទេ។

ប្រសិនបើលំហូរទឹកប្រាក់មានភាពខុសគ្នាខ្លាំង នោះសិទ្ធិតាមកិច្ចសន្យាចំពោះលំហូរទឹកប្រាក់ពីទ្រព្យសកម្មហិរញ្ញវត្ថុដើម ត្រូវបានចាត់ទុកថាផុតអាណត្តិ។ ក្នុងករណីនេះទ្រព្យសកម្មហិរញ្ញវត្ថុដើម ត្រូវឈប់ទទួលស្គាល់ ហើយទ្រព្យសកម្មហិរញ្ញវត្ថុថ្មី ត្រូវបានទទួលស្គាល់តាមតម្លៃសមស្របបូកនឹងថ្លៃចំណាយប្រតិបត្តិការពាក់ព័ន្ធ។

ធនាគារ ឈប់ទទួលស្គាល់បំណុលហិរញ្ញវត្ថុ នៅពេលដែលលក្ខខណ្ឌរបស់វាត្រូវបានកែតម្រូវ ហើយលំហូរទឹកប្រាក់នៃបំណុលដែលបានកែតម្រូវនោះមានភាពខុសគ្នាខ្លាំង។ ក្នុងករណីនេះ បំណុលហិរញ្ញវត្ថុថ្មីត្រូវបានទទួលស្គាល់តាមតម្លៃសមស្រប។ ភាពលម្អៀងរវាងតម្លៃយោងនៃបំណុលហិរញ្ញវត្ថុដែលមិនត្រូវបានទទួលស្គាល់ និងតម្លៃតបស្នងត្រូវបានទទួលស្គាល់នៅក្នុងចំណេញ និងខាត។ តម្លៃតបស្នងរួមមានទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុដែលបានផ្ទេរ (ប្រសិនបើមាន) និងការទទួលយកបំណុលរួមទាំងបំណុលហិរញ្ញវត្ថុដែលបានកែតម្រូវថ្មី។

ប្រសិនបើការកែតម្រូវបំណុលហិរញ្ញវត្ថុនេះមិនធ្វើឱ្យមានការឈប់ទទួលស្គាល់ទេ នោះរំលស់ថ្លៃដើមនៃបំណុល ត្រូវគណនាឡើងវិញដោយធ្វើអប្បហារលំហូរទឹកប្រាក់ ដែលបានកែប្រែតាមអត្រាការប្រាក់ប្រសិទ្ធិភាពដំបូងហើយលទ្ធផលនៃការចំណេញ ឬខាតត្រូវបានទទួលស្គាល់នៅក្នុងចំណេញ ឬខាត។ សម្រាប់បំណុលហិរញ្ញវត្ថុមានអត្រាអថេរ អត្រាការប្រាក់ប្រសិទ្ធភាពដំបូងដែលប្រើដើម្បីគណនាចំណេញ ឬខាតពីការកែតម្រូវ ត្រូវបានកែប្រែដើម្បីឆ្លុះបញ្ចាំងពីលក្ខខណ្ឌទីផ្សារបច្ចុប្បន្ននៅពេលដែលធ្វើការកែតម្រូវ។ រាល់ការចំណាយ និងថ្លៃសេវាដែលកើតមាន ត្រូវបានទទួលស្គាល់ជាការកែតម្រូវទៅលើតម្លៃយោងនៃបំណុល និងរំលស់តាមរយៈពេលដែលនៅសល់នៃបំណុលហិរញ្ញវត្ថុ ដែលបានកែតម្រូវដោយគណនាអត្រាការប្រាក់ប្រសិទ្ធភាពឡើងវិញលើឧបករណ៍ហិរញ្ញវត្ថុ។

(ឃ) ការវាស់វែងតម្លៃសមស្រប

តម្លៃសមស្រប គឺជាតម្លៃដែលនឹងទទួលបានដោយការលក់ទ្រព្យសកម្ម ឬតម្លៃដែលបានទូទាត់ចំពោះការផ្ទេរបំណុលនៅក្នុងប្រតិបត្តិការធម្មតា រវាងអ្នកចូលរួមក្នុងទីផ្សារ នាកាលបរិច្ឆេទនៃការវាស់វែងនៅក្នុងទីផ្សារគោល ឬក្នុងករណីមិនមានទីផ្សារគោល គឺយកទីផ្សារជាអាទិភាពបំផុត ដែលធនាគារអាចកំណត់រកបាននៅកាលបរិច្ឆេទនៃការវាស់វែងនោះ។ តម្លៃសមស្របរបស់បំណុល ឆ្លុះបញ្ចាំងពីហានិភ័យការមិនអនុវត្តកាតព្វកិច្ច។

ធនាគារវាស់វែងតម្លៃសមស្របរបស់ឧបករណ៍ហិរញ្ញវត្ថុមួយ ដោយប្រើសម្រង់តម្លៃនៅក្នុងទីផ្សារសកម្មរបស់ឧបករណ៍នោះ (ប្រសិនបើមាន)។ ទីផ្សារមួយចាត់ទុកជាទីផ្សារសកម្ម ប្រសិនបើប្រតិបត្តិការរបស់ទ្រព្យសកម្ម ឬបំណុលកើតឡើងញឹកញាប់ ហើយទំហំប្រតិបត្តិការមានភាពគ្រប់គ្រាន់ក្នុងការផ្តល់ព័ត៌មានតម្លៃជាទៀងទាត់។

ប្រសិនបើពុំមានសម្រង់តម្លៃនៅក្នុងទីផ្សារសកម្មទេនោះធនាគារត្រូវប្រើបច្ចេកទេសវាយតម្លៃណាដែលអាចប្រើប្រាស់ទិន្នន័យដែលអាចអង្កេតបានជាអតិបរមា និងកាត់បន្ថយនូវការប្រើប្រាស់ទិន្នន័យដែលមិនអាចអង្កេតបាន។ បច្ចេកទេសវាយតម្លៃដែលបានជ្រើសរើស ត្រូវរួមបញ្ចូលនូវកត្តាទាំងអស់ដែលអ្នកចូលរួមក្នុងទីផ្សារនឹងពិចារណានៅក្នុងការកំណត់តម្លៃ។

តម្លៃសមស្របនៃបំណុលហិរញ្ញវត្ថុមានលក្ខណៈអាចទាមទារសងតាមតម្រូវការ (ឧទាហរណ៍ ប្រាក់បញ្ញើចរន្ត) គឺមិនត្រូវតិចជាងចំនួនទឹកប្រាក់ដែលត្រូវបង់តាមតម្រូវការទេ ដោយត្រូវធ្វើអប្បហារចាប់ពីថ្ងៃដំបូងដែលចំនួនទឹកប្រាក់អាចត្រូវបានបង់។

(ង) ឱនភាពនៃតម្លៃ

ធនាគារទទួលស្គាល់សំវិធានធនលើការរំពឹងទុកលើការខាតបង់ឥណទាន (“ECL”) ចំពោះឧបករណ៍ហិរញ្ញវត្ថុដែលបានវាស់វែងតាមរំលស់ថ្លៃដើម។

ធនាគារវាស់វែងសំវិធានធនលើការខាតបង់ តាមចំនួនដែលស្មើនឹងការរំពឹងទុកលើការខាតបង់ឥណទានពេញអាយុកាល លើកលែងសាច់ប្រាក់ និងសាច់ប្រាក់សមមូលដែលមានហានិភ័យឥណទាន (ឧទាហរណ៍ ហានិភ័យនៃការខូចខាតដែលកើតឡើងលើអាយុកាលរំពឹងទុកនៃឧបករណ៍ហិរញ្ញវត្ថុ) មិនមានហានិភ័យឥណទានកើនឡើងជាសារវន្ត ចាប់តាំងពីការទទួលស្គាល់លើកដំបូង ដែលត្រូវវាស់វែងតាមការរំពឹងទុកលើការខាតបង់ឥណទានរយៈពេល 12 ខែ។

ការរំពឹងទុកលើការខាតបង់ឥណទានពេញមួយអាយុកាល គឺជាការរំពឹងទុកលើការខាតបង់ឥណទាន ដែលអាច បណ្តាលមកពីព្រឹត្តិការណ៍ខកខានសងប្រាក់ក្នុងរយៈពេលនៃអាយុកាលរំពឹងទុកនៃឧបករណ៍ហិរញ្ញវត្ថុ។

ការរំពឹងទុកលើការខាតបង់ឥណទាន 12ខែ គឺជាផ្នែកនៃការរំពឹងទុកលើការខាតបង់ឥណទានដែលបណ្តាលមកពីព្រឹត្តិការណ៍ខកខានសងប្រាក់ក្នុងរយៈពេល 12ខែ បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ (ឬមានរយៈពេលខ្លីជាងប្រសិនបើអាយុកាលរំពឹងទុកនៃឧបករណ៍ហិរញ្ញវត្ថុមានរយៈពេលតិចជាង 12ខែ។

រយៈពេលអតិបរមាដែលត្រូវយកមកពិចារណា ពេលធ្វើការប៉ាន់ស្មានលើការរំពឹងទុកលើការខាតបង់ឥណទាន គឺជារយៈពេលកិច្ចសន្យាអតិបរមាដែលធនាគារប្រឈមនឹងហានិភ័យឥណទាន។

នៅពេលកំណត់ថាតើហានិភ័យឥណទាននៃទ្រព្យសកម្មហិរញ្ញវត្ថុបានកើនឡើងជាសារវន្ត ចាប់តាំងពីការទទួលស្គាល់លើកដំបូង និងនៅពេលប៉ាន់ស្មានលើការរំពឹងទុកលើការខាតបង់ឥណទាន នោះធនាគារពិចារណាលើព័ត៌មានដែលសមហេតុសមផល និងព័ត៌មានគាំទ្រ ដែលពាក់ព័ន្ធ និងអាចរកបាន ដោយមិនចាំបាច់ចំណាយ ឬប្រឹងប្រែងខ្ពស់។ ព័ត៌មានទាំងនេះរួមបញ្ចូលព័ត៌មានបរិមាណ និងព័ត៌មានគុណភាព និងការវិភាគដោយផ្អែកលើបទពិសោធន៍របស់ធនាគារ និងការវាយតម្លៃឥណទាន ព្រមទាំងបញ្ចូលព័ត៌មានប្រមើលអនាគត។

ធនាគារចាត់ទុកទ្រព្យសកម្មហិរញ្ញវត្ថុដែលមានការខកខានសងនៅពេលដែល៖

- អ្នកខ្ចីមិនមានលទ្ធភាពសងចំពោះកាតព្វកិច្ចឥណទានរបស់ខ្លួនទាំងស្រុង ដោយមិនពឹងផ្អែកទៅលើការលក់ទ្រព្យដាក់ធានាដើម្បីទូទាត់សង (ប្រសិនបើមានទ្រព្យដាក់ធានា) ឬ
- ទ្រព្យសកម្មហិរញ្ញវត្ថុហួសកាលកំណត់សងច្រើនជាង 30 ថ្ងៃ សម្រាប់ឥណទានរយៈពេលខ្លី និង 90 ថ្ងៃ សម្រាប់ឥណទានរយៈពេលវែង។

ការវាស់វែងលើការរំពឹងទុកលើការខាតបង់ឥណទាន (ECLs)

ធនាគារនឹងវាស់ ECL ដោយប្រើវិធីសាស្រ្តទូទៅ។ វិធីសាស្រ្តទូទៅរួមមានការញែកអតិថិជនចេញជាបីដំណាក់កាលផ្សេងគ្នាយោងទៅតាមលក្ខណៈវិនិច្ឆ័យដំណាក់កាល ដោយវាយតម្លៃហានិភ័យឥណទាន។ ECL រយៈពេល 12ខែនឹងត្រូវបានគណនាសម្រាប់ដំណាក់កាលទី1 ខណៈអាយុកាល ECLនឹងត្រូវបានគណនាសម្រាប់ដំណាក់កាលទី2 និងដំណាក់កាលទី3។ នៅកាលបរិច្ឆេទរបាយការណ៍ ធនាគារនឹងវាយតម្លៃហានិភ័យឥណទានរបស់គណនីនីមួយៗដោយប្រៀបធៀបទៅនឹង កម្រិតហានិភ័យនៅកាលបរិច្ឆេទដើម។

ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុដែលមានរយៈពេលខ្លី វិធីសាស្រ្តសាមញ្ញ នឹងត្រូវបានអនុម័តនៅពេលដែលមិនចាំបាច់មានលក្ខណៈវិនិច្ឆ័យជាជំហានៗ។ ក្នុងករណីនេះវានឹងត្រូវចាត់ថាដំណើរការ (ដំណាក់កាលទី1) រឺក៏មិនចាត់ថាដំណើរការ។

ECLs គឺជាការប៉ាន់ប្រមាណថ្លឹងថ្លែង ការប៉ាន់ស្មាននៃការបាត់បង់ឥណទាន ។ ការខាតបង់ឥណទានត្រូវបានវាស់វែងតាមតម្លៃបច្ចុប្បន្ននៃភាពកង្វះខាតនៃសាច់ប្រាក់ទាំងអស់ (ពោលគឺភាពខុសគ្នារវាងលំហូរសាច់ប្រាក់ដែលបានមកពីអង្គភាពស្របតាមកិច្ចសន្យា និងលំហូរសាច់ប្រាក់ដែលធនាគាររំពឹងទុកថានឹងទទួលបាន)។

ដូចការរៀបរាប់ខាងលើ ដោយផ្អែកលើការប្រើប្រាស់ PD 12ខែ សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុដំណាក់កាលទី1ធនាគារវាស់វែងលើការរំពឹងទុកលើការខាតបង់ឥណទាន ដោយពិចារណាលើហានិភ័យនៃការខូចខាតលើរយៈពេល ពេញលេញនៃកិច្ចសន្យា (រួមបញ្ចូលទាំងរយៈពេលពន្យាប្រសិនបើមាន) ដែលមានហានិភ័យលើឥណទានទោះបី ជាក្នុងគោលបំណងគ្រប់គ្រងហានិភ័យឥណទានក៏ដោយធនាគារពិចារណាលើរយៈពេលដែលវែងជាង។ រយៈពេលដែលវែងបំផុត គឺគិតត្រឹមថ្ងៃដែលធនាគារមានសិទ្ធិដើម្បីទាមទារការសងត្រឡប់នៃឥណទាន ឬបញ្ចប់កិច្ចសន្យាផ្តល់ឥណទាន ឬការធានា។

ECLs ត្រូវបានធ្វើអប្បហារតាមអត្រាការប្រាក់ប្រសិទ្ធភាពនៃទ្រព្យសកម្មហិរញ្ញវត្ថុ។

ទិន្នន័យ ការសន្មត និងបច្ចេកទេសប្រើសម្រាប់ការវាយតម្លៃឱនភាពនៃតម្លៃ

សមាសធាតុសំខាន់ៗ ក្នុងការវាស់វែងលើការរំពឹងទុកលើការខាតបង់ឥណទាន គឺបានមកពីអថេរដូចខាងក្រោម៖

- ប្រូបាប៊ីលីតេនៃការខកខានសង (“PD”);
- ការបាត់បង់ដែលបណ្តាលមកពីការខកខានសង (“LGD”) និង
- ទំហំនៃការខកខានសង (“EAD”)

ECL សម្រាប់សមតុល្យក្នុងដំណាក់កាលទី1 ត្រូវបានគណនាដោយផលគុណនៃ PD 12ខែ នឹងLGD នឹងEAD។ ECL ពេញអាយុកាល ត្រូវបានគណនាដោយផលគុណនៃ PD ពេញអាយុកាល នឹងLGD នឹងEAD។

គំរូស្ថិតិត្រូវបានប្រើប្រាស់ដើម្បីវិភាគទិន្នន័យប្រមូលបាន រួចបង្កើតនូវការប៉ាន់ស្មាន PD ពេញអាយុកាលដែលនៅសល់ និងថាតើសមតុល្យទាំងនោះរំពឹងថាប្រែប្រួលយ៉ាងណាលើរយៈពេលនោះ។

ធនាគារនឹងប្រើព័ត៌មានហួសកាលកំណត់ (DPD) និងការធ្វើចំណាត់ថ្នាក់របស់ NBC សម្រាប់លក្ខណៈវិនិច្ឆ័យដំណាក់កាល។ សូមមើលកំណត់សម្គាល់4.1 (ឃ) សម្រាប់ព័ត៌មានលម្អិត។ ដោយអនុលោមតាមសេចក្តីណែនាំរបស់ធនាគារជាតិនៃកម្ពុជាលេខ ធ7-017-344 ចំណាត់ថ្នាក់ឥណទាននីមួយៗ យោងទៅតាមគុណភាពឥណទាន។

- **ឥណទានធម្មតា៖** ឥណទានដែលនៅសល់ ត្រូវបានទូទាត់សងទាន់ពេលវេលា និងមិនជាប់សង្ស័យសម្រាប់ការទូទាត់សងនាពេលអនាគត។ ការទូទាត់សងត្រូវបានធ្វើឡើងតាមកិច្ចសន្យា ហើយអតិថិជនមិនបង្ហាញពីភាពទន់ខ្សោយនៃលទ្ធភាពក្នុងការទូទាត់សង អាជីវកម្ម លំហូរទឹកប្រាក់ និងស្ថានភាពហិរញ្ញវត្ថុនោះឡើយ។
- **ឥណទានឃ្លាំមើល៖** ឥណទានដែលនៅក្នុងចំណាត់ថ្នាក់នេះ ត្រូវបានការពារនាពេលបច្ចុប្បន្ន ហើយប្រហែលជាមិនអាចហួសកាលកំណត់ទេ ប៉ុន្តែវាបង្ហាញពីភាពទន់ខ្សោយដែលអាចជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់ការទូទាត់សងរបស់កូនបំណុលនៅកាលបរិច្ឆេទនាពេលអនាគត ប្រសិនបើមិនបានកែតម្រូវឱ្យបានទាន់ពេលវេលា និងយកចិត្តទុកដាក់ពីគ្រឹះស្ថាន។
- **ឥណទានក្រោមស្តង់ដា៖** ឥណទានដែលបានចាត់ថ្នាក់នៅក្នុងចំណាត់ថ្នាក់នេះ បង្ហាញពីភាពទន់ខ្សោយគួរឱ្យកត់សម្គាល់ ហើយមិនត្រូវបានការពារគ្រប់គ្រាន់ដោយអាជីវកម្មបច្ចុប្បន្ន ឬស្ថានភាពហិរញ្ញវត្ថុ និងលទ្ធភាពសងរបស់កូនបំណុលទេ។ និយាយឱ្យចំទៅប្រភពដើមនៃការសងបំណុល គឺមិនគ្រប់គ្រាន់ដើម្បីទូទាត់បំណុលនោះទេដោយមិនគិតពីប្រាក់ចំណូលដែលបានមកពីប្រភពបន្ទាប់បន្សំដូចជាលក់ទ្រព្យបញ្ចាំជាដើម។
- **ឥណទានជាប់សង្ស័យ៖** ឥណទានដែលបានចាត់ថ្នាក់នៅក្នុងប្រភេទនេះ បង្ហាញពីភាពទន់ខ្សោយធ្ងន់ធ្ងរជាងចំណាត់ថ្នាក់ឥណទានក្រោមស្តង់ដា ដែលការប្រមូលបានមកវិញគ្រប់ចំនួន ផ្អែកលើមូលដ្ឋាននៃដំណើរហេតុដែលមានស្រាប់ លក្ខខណ្ឌ ឬតម្លៃនៃទ្រព្យបញ្ចាំមានការសង្ស័យខ្ពស់ ឬមិនអាចអាចប្រមូលបានវិញ។ ការរំពឹងទុកថានឹងបាត់បង់គឺខ្ពស់ ទោះបីជាចំនួនពិតប្រាកដនៅមិនទាន់បានកំណត់សម្រាប់ពេលនេះក៏ដោយ។
- **ឥណទានខាតបង់៖** ឥណទានដែលត្រូវបានចាត់ថ្នាក់ថាជាការបាត់បង់ គឺនៅពេលដែលវាមិនអាចប្រមូលបានមកវិញ ហើយការទូទាត់សងវិញអាចមានចំនួនតិចតួច ឬប្រមូលមិនបានសោះ។

LGD គឺជាតវិយាបទនៃភាពអាចបាត់បង់ប្រសិនបើមានការខកខានសង។ ធនាគារប៉ាន់ស្មានលក្ខខណ្ឌ LGD យោងតាមប្រវត្តិនៃអត្រាការប្រមូលត្រលប់ពីអតិថិជនខកខានសង។ គំរូ LGD ត្រូវបានពិចារណាលើរចនាសម្ព័ន្ធ អទិភាពនៃការទាមទារសំណង វិស័យដែលអតិថិជនស្ថិតនៅ ចំណាយលើការប្រមូលពីទ្រព្យបញ្ចាំ ដែលជាផ្នែកមួយនៃទ្រព្យសកម្មហិរញ្ញវត្ថុ។ សម្រាប់ឥណទានដែលការពារដោយទ្រព្យអនុបាតឥណទានធៀបនឹងតម្លៃទ្រព្យបញ្ចាំ ("LTV") គឺជាលក្ខខណ្ឌមួយក្នុងការកំណត់ LGD។ ការប៉ាន់ស្មាន LGD ត្រូវបានវាស់វែងសម្រាប់វិស័យផ្សេងៗគ្នា ហើយសម្រាប់ឥណទានគេហដ្ឋាន គឺអាស្រ័យលើការប្រែប្រួលតម្លៃអចលនទ្រព្យ។ តម្លៃទាំងនោះនឹងត្រូវបានគណនាដោយអប្បហារ ដោយផ្អែកលើអត្រាការប្រាក់ប្រសិទ្ធភាព។

EAD តំណាងឱ្យតម្លៃសមតុល្យនៅពេលមានការខកខានសង។ ធនាគារទាញយក EAD ពីសមតុល្យបច្ចុប្បន្នរបស់អតិថិជន និងភាពអាចប្រែប្រួលលើសមតុល្យបច្ចុប្បន្នពីការបង់សង ដែលអនុញ្ញាតតាមកិច្ចសន្យា និងកើតចេញពីការបង់រំលស់។ EAD នៃទ្រព្យសកម្មហិរញ្ញវត្ថុ គឺតម្លៃយោងដុលនៅពេលមានការខកខានសង។ សម្រាប់កាតព្វកិច្ចឱ្យខ្ចី EAD គឺសមតុល្យអនាគតដែលអាចដកប្រើប្រាស់តាមកិច្ចសន្យា ដែលត្រូវបានប៉ាន់ស្មានតាមការសង្កេតពីប្រវត្តិ និងការព្យាករណ៍នាពេលខាងមុខ។ សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុខ្លះ EAD ត្រូវបានកំណត់ដោយគំរូនៃសមតុល្យដែលអាចកើតឡើងនៅពេលវេលាផ្សេងគ្នាដោយប្រើបច្ចេកទេសស្ថិតិ។

ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពនៃតម្លៃ

នៅកាលបរិច្ឆេទរាយការណ៍នីមួយៗ ធនាគារវាយតម្លៃថាតើទ្រព្យសកម្មហិរញ្ញវត្ថុដែលបានកត់ត្រាតាមរំលស់ថ្លៃដើម និងបំណុលហិរញ្ញវត្ថុដែលបានកត់ត្រាតាម FVOCI មានឱនភាពនៃតម្លៃ ឬទេ (ដែលត្រូវបានកំណត់ជា "ទ្រព្យសកម្មហិរញ្ញវត្ថុដំណាក់កាលទី 3")។ ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានចាត់ទុកថាមានឱនភាពនៃតម្លៃនៅពេលដែលព្រឹត្តិការណ៍មួយ ឬច្រើនបានកើតឡើង ដែលនាំឱ្យមានផលប៉ះពាល់ជាអវិជ្ជមានទៅលើលំហូរទឹកប្រាក់នាពេលអនាគតដែលរំពឹងទុកនៃទ្រព្យសកម្មហិរញ្ញវត្ថុ។

ភស្តុតាងដែលបញ្ជាក់ថាទ្រព្យសកម្មហិរញ្ញវត្ថុមានឱនភាពនៃតម្លៃរួមមាន:

- ការយឺតយាវ ឬការមិនទូទាត់សងរបស់កូនបំណុល
- ការរៀបចំឡើងវិញនូវលក្ខខណ្ឌទូទាត់សង ដែលធនាគារមិនបានរំពឹងទុក
- ការបង្ហាញថាកូនបំណុល ឬអ្នកឱ្យខ្ចីនឹងក្ស័យធន
- ការផ្លាស់ប្តូរអវិជ្ជមានក្នុងស្ថានភាពទូទាត់របស់អ្នកខ្ចី ឬអ្នកឱ្យខ្ចី
- ការបាត់ខ្លួនពីទីផ្សារសកម្មសម្រាប់ភាគហ៊ុន ឬ
- ទិន្នន័យដែលអាចអង្កេតបាន បង្ហាញថាមានការថយចុះដែលអាចវាស់វែងបាននៅក្នុងលំហូរសាច់ប្រាក់ដែលរំពឹងទុកពីក្រុមនៃទ្រព្យសកម្មហិរញ្ញវត្ថុ។

ទ្រព្យសកម្មហិរញ្ញវត្ថុដែលបានរៀបចំឡើងវិញ

ប្រសិនបើលក្ខខណ្ឌនៃទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានចរចា ឬកែតម្រូវ ឬទ្រព្យសកម្មហិរញ្ញវត្ថុដែលមានស្រាប់ត្រូវបានជំនួសដោយទ្រព្យសកម្មហិរញ្ញវត្ថុថ្មីដោយសារស្ថានភាពលំបាកផ្នែកហិរញ្ញវត្ថុរបស់អតិថិជននោះ ការវាយ តម្លៃត្រូវបានធ្វើឡើង ដើម្បីវាយតម្លៃថាតើទ្រព្យសកម្មហិរញ្ញវត្ថុគួរតែត្រូវឈប់ទទួលស្គាល់ ឬទេ ហើយ ECL ត្រូវបានវាស់វែងដូចខាងក្រោម៖

- ប្រសិនបើការរៀបចំឡើងវិញ មិននាំឱ្យឈប់ទទួលស្គាល់ទ្រព្យសកម្មដែលមានស្រាប់ទេនោះលំហូរទឹកប្រាក់ដែលរំពឹងទុកថាកើតមានពីទ្រព្យសកម្មហិរញ្ញវត្ថុដែលបានកែតម្រូវ ត្រូវបានបញ្ចូលនៅក្នុងការគណនាកង្វះខាតនៃសាច់ប្រាក់ពីទ្រព្យសកម្មដែលមានស្រាប់។
- ប្រសិនបើការរៀបចំឡើងវិញ នាំឱ្យមានការឈប់ទទួលស្គាល់ទ្រព្យសកម្មដែលមានស្រាប់ នោះតម្លៃសមស្របរំពឹងទុកនៃទ្រព្យសកម្មថ្មីនោះ ត្រូវបានចាត់ទុកជាលំហូរទឹកប្រាក់ចុងក្រោយទទួលបានពីទ្រព្យសកម្មហិរញ្ញវត្ថុបច្ចុប្បន្ន នៅពេលដែលឈប់ទទួលស្គាល់។ ចំនួនទឹកប្រាក់នេះត្រូវបានបញ្ចូលទៅក្នុងការគណនាកង្វះខាតសាច់ប្រាក់ពីទ្រព្យសកម្មហិរញ្ញវត្ថុបច្ចុប្បន្ន ដែលត្រូវបានធ្វើអប្បហារពីកាលបរិច្ឆេទរំពឹងទុកនៃការឈប់ទទួលស្គាល់ ទៅកាលបរិច្ឆេទរាយការណ៍ ដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាពដើមនៃទ្រព្យសកម្មហិរញ្ញវត្ថុបច្ចុប្បន្ន។

ឥណទានមួយត្រូវបានចរចាឡើងវិញ ដោយសារតែស្ថានភាពកាន់យ៉ាប់យឺននៃលក្ខខណ្ឌរបស់អ្នកខ្ចី ជាធម្មតាវាត្រូវបានចាត់ទុកជាឥណទានដែលមានឱនភាព លុះត្រាតែមានភស្តុតាងដែលបង្ហាញថាហានិភ័យនេះមិនទទួលរងផលប៉ះលើលំហូរសាច់ប្រាក់តាមកិច្ចសន្យាដែលបានកាត់បន្ថយយ៉ាងខ្លាំង ហើយក៏មិនមាននិយ័តករផ្សេងទៀតនៃឱនភាពតម្លៃនោះទេ។ លើសពីនេះទៀត ឥណទានដែលហួសកាលកំណត់លើស 90ថ្ងៃ ឬច្រើនជាងនេះត្រូវបានចាត់ទុកជាឥណទានដែលមានឱនភាព បើទោះបីជាការកំណត់តាមបទប្បញ្ញត្តិមានភាពខុសគ្នាក៏ដោយ។

ការបង្ហាញនៃសំវិធានធនសម្រាប់ ECL នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

សំវិធានធនការខាតបង់ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុដែលវាស់វែងតាមរំលស់ថ្លៃដើម ត្រូវដកចេញពីតម្លៃយោងនៃទ្រព្យសកម្មសរុប ។

ការលុបចោល

តម្លៃយោងសរុបរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានលុបចោលនៅពេលដែលធនាគារមិនមានការរំពឹងទុកសម ហេតុផលពីភាពដែលអាចប្រមូលបានមកវិញនូវទ្រព្យសកម្មហិរញ្ញវត្ថុទាំងស្រុង ឬផ្នែកមួយនៃទ្រព្យ។ សម្រាប់អតិថិជនជាឯកត្តជន ធនាគារមានគោលនយោបាយលុបចោលតម្លៃយោងសរុប ដោយផ្អែកលើបទពិសោធន៍ ប្រវត្តិសាស្ត្រនៃការប្រមូលបានមកវិញនៃទ្រព្យស្រដៀងគ្នា។ ចំពោះអតិថិជនជានីតិបុគ្គល ធនាគារធ្វើការវាយតម្លៃនីមួយៗផ្អែកលើពេលវេលា និងបរិមាណនៃការលុបចោល ដោយផ្អែកលើថាតើមានការរំពឹងទុកនៃប្រមូលបានមកវិញ។ ធនាគារមិនរំពឹងថានឹងមានការប្រមូលបានមកវិញពីចំនួនទឹកប្រាក់ដែលលុបចោលឡើយ។ ទោះជា យ៉ាងណាក៏ដោយ ទ្រព្យសកម្មហិរញ្ញវត្ថុដែលត្រូវបានលុបចោលនៅតែអាចត្រូវបានអនុវត្តតាមសកម្មភាពដើម្បីអនុវត្តតាមនីតិវិធីរបស់ធនាគារដើម្បីក្នុងការប្រមូលមកវិញនៃចំនួនដែលនៅជំពាក់។

ទឹកប្រាក់ប្រមូលបានមកវិញលើចំនួនដែលបានលុបចេញពីបញ្ជី ត្រូវបញ្ចូលទៅក្នុងខ្ទង់ “ការខាតបង់សុទ្ធពីឱនភាពនៃតម្លៃឧបករណ៍ហិរញ្ញវត្ថុ” នៅក្នុងចំណេញ ឬខាត។

(ច) រំលស់ថ្លៃដើម និងតម្លៃយោងដុល

‘រំលស់ថ្លៃដើម’ របស់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ គឺជាចំនួនដែលទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ត្រូវបានវាស់វែងនៅពេលទទួលស្គាល់ជាលើកដំបូង ដកការទូទាត់សងប្រាក់ដើម បូក ឬដករំលស់បង្គរ ដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាព ចំពោះភាពខុសគ្នារវាងចំនួនដែលទទួលស្គាល់ជាលើកដំបូង និងចំនួននៅពេលដល់កាលកំណត់ និងត្រូវធ្វើនិយ័តភាពចំពោះសំវិធានធនលើការខាតបង់ឥណទានដែលបានរំពឹងទុកចំពោះទ្រព្យសកម្មហិរញ្ញវត្ថុ។

‘តម្លៃយោងដុលរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ’ គឺជារំលស់ថ្លៃដើមរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ មុនពេលកែតម្រូវសំវិធានធនសម្រាប់ការខាតបង់ឥណទានដែលបានរំពឹងទុក។

29.3 សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សាច់ប្រាក់ និងសាច់ប្រាក់សមមូលរួមមាន សាច់ប្រាក់ក្នុងដៃ និងសមតុល្យធនាគារ និងប្រាក់បញ្ញើនៅធនាគារ ដែលមានកាលវសាន្តនៅពេលតម្កល់ដំបូងមានរយៈពេល 3ខែ ឬតិចជាង និងការវិនិយោគរយៈពេលខ្លី និងដែលអាចប្តូរជាសាច់ប្រាក់ពេលណាក៏បានដោយមានហានិភ័យតិចតួចចំពោះការផ្លាស់ប្តូរតម្លៃ។

29.4 ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារផ្សេងៗ

ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារ ត្រូវបានកត់ត្រាតាមតម្លៃដើមរំលស់នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ដកការខាតបង់ឥណទានដែលរំពឹងទុក។

29.5 ឥណទាន និងបុរេប្រទាន

“ឥណទាន និងបុរេប្រទាន” ដែលបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ រួមបញ្ចូលឥណទាន និងបុរេប្រទានដែលត្រូវបានវាស់វែងតាមរំលស់ថ្លៃដើម។ ឥណទាន និងបុរេប្រទានត្រូវបានវាស់វែងលើកដំបូងតាមតម្លៃសមស្រប បូកចំណាយប្រតិបត្តិការដែលកើតឡើងដោយផ្ទាល់ ហើយនាពេលបន្ទាប់ត្រូវកត់ត្រាតាមរំលស់ថ្លៃដើមដោយប្រើវិធីសាស្ត្រអត្រាការប្រាក់ប្រសិទ្ធភាព ដកការខាតបង់ឥណទានដែលរំពឹងទុក។

29.6 ដើមទុន-ភាគហ៊ុនធម្មតា

ថ្លៃដើមកើតឡើងដោយផ្ទាល់ពីការបោះផ្សាយភាគហ៊ុនធម្មតា ដកផលប៉ះពាល់នៃពន្ធត្រូវបានទទួលស្គាល់ដោយកាត់ពីមូលធន។

29.7 ទុនបម្រុងតាមបទប្បញ្ញត្តិ

ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ ត្រូវបានតម្រូវឱ្យគណនាសំវិធានធនតាមច្បាប់ អនុលោមទៅតាមប្រកាសលេខធ7-017-344 ប្រ.ក ចុះថ្ងៃទី1 ខែធ្នូ ឆ្នាំ2017 និងសារាចរណែនាំលេខ ធ7-018-001 ចុះថ្ងៃទី16 ខែកុម្ភៈ ឆ្នាំ2018 ស្តីពី "ចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអិមតែរមិន"។ ប្រសិនបើសំវិធានធនតាមច្បាប់បង្គរ មានចំនួនខ្ពស់ជាងការថយចុះតម្លៃបង្គរផ្អែកតាម CIFRS 9 នោះ "ការបំពេញបន្ថែម - Topping up" នឹងត្រូវបានកត់ត្រា ជាទុនបម្រុងតាមច្បាប់ និងត្រូវបានដាក់បង្ហាញនៅក្នុងមូលធន។ បន្ទាប់មក ទុនបម្រុងត្រូវបានកត់ត្រាត្រឡប់ទៅវិញ (រហូតដល់សូន្យ) ប្រសិនបើសំវិធានធនតាមច្បាប់បង្គរ មានចំនួនស្មើគ្នា ឬទាបជាងការថយចុះតម្លៃបង្គរដែលផ្អែកតាម CIFRS 9។ ទុនបម្រុងតាមច្បាប់ត្រូវបានតម្កល់ទុកមួយឡែក ជាទ្រទាប់ដើមទុន ហើយមិនអាចបែងចែកបាន និងមិនត្រូវបានអនុញ្ញាតឱ្យរួមបញ្ចូលនៅក្នុងការគណនាមូលនិធិផ្ទាល់សុទ្ធទេ។

29.8 ទ្រព្យ និងបរិក្ខារ

(ក) ការទទួលស្គាល់ និងការវាស់វែង

ផ្នែកនៃទ្រព្យ និងបរិក្ខារ ត្រូវបានកត់ត្រាតាមវិធីសាស្ត្រថ្លៃដើម ដករំលស់បង្គរ និងការខាតបង់បង្គរលើឱនភាពនៃតម្លៃបង្គរប្រសិនបើមាន។

នៅពេលផ្នែកនៃទ្រព្យ និងបរិក្ខារមានអាយុកាលប្រើប្រាស់ខុសៗគ្នា ជាតុទាំងនោះត្រូវបាន ចាត់ទុកជាផ្នែកផ្សេងៗ (សមាសធាតុចម្បងៗ) នៃទ្រព្យ និងបរិក្ខារ។

ចំណេញ ឬខាតពីការលក់ចេញនៃទ្រព្យ និងបរិក្ខារណាមួយ ត្រូវបានគណនាដោយប្រៀបធៀបតម្លៃលក់ចេញជាមួយតម្លៃយោងនៃទ្រព្យ និងបរិក្ខារ ហើយទទួលស្គាល់ជាប្រាក់ចំណេញសុទ្ធ នៅក្នុងរបាយការណ៍ចំណេញ ឬខាត។

(ខ) ការចំណាយបន្ទាប់

ថ្លៃដើមនៃការផ្លាស់ប្តូរជាតុមួយនៃទ្រព្យ និងបរិក្ខារដែលបានទទួលស្គាល់រួចមកហើយត្រូវបានបូកបញ្ចូលនៅក្នុងតម្លៃយោងនៃផ្នែកនោះ ប្រសិនបើវាអាចមានលទ្ធភាពផ្តល់នូវអត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតដល់ធនាគារ ហើយតម្លៃរបស់វាអាចវាស់វែងបានដោយភាពជឿជាក់ ។ តម្លៃយោងនៃជាតុ ដែលបានជំនួសនោះត្រូវបានលុបចោល ។ រាល់ចំណាយក្នុងការថែទាំប្រចាំថ្ងៃផ្សេងៗ ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាតក្នុងការិយបរិច្ឆេទដែលបានកើតឡើង ។

(គ) រំលស់

រំលស់ ត្រូវបានគណនាដើម្បីកាត់ចោលថ្លៃដើមនៃទ្រព្យសកម្ម និងបរិក្ខារដកតម្លៃកាកសំណល់ប៉ាន់ស្មានតាមមូលដ្ឋានរំលស់ថេរលើអាយុកាលប្រើប្រាស់ប៉ាន់ស្មាន។ អាយុកាលរំលស់មានដូចខាងក្រោម៖

ការកែលម្អអគារជួល	ឬរយៈពេលកិច្ចសន្យាមួយណាខ្លីជាង
គ្រឿងសង្ហារឹម និងគ្រឿងបំពាក់	60ខែ
បរិក្ខារ	60ខែ
បរិក្ខារកុំព្យូទ័រ និងព័ត៌មានវិទ្យា	36ខែ
យានយន្ត	60ខែ

ប្រសិនបើមានការកែប្រែជាសារវន្តទៅលើអត្រារំលស់ អាយុកាលប្រើប្រាស់ តម្លៃនៅសល់នៃទ្រព្យ និងបរិក្ខារនោះរំលស់ត្រូវបានកំណត់ឡើងវិញ ដើម្បីឆ្លុះបញ្ចាំងនូវការប៉ាន់ស្មានថ្មី។

29.9 ទ្រព្យសកម្មអរូបី

ទ្រព្យសកម្មអរូបី រួមមានគេហទំព័រ និងសូហ្វវែរ ត្រូវបានកំណត់ដោយតម្លៃដើមដករំលស់បង្គរ និងឱនភាពនៃតម្លៃបង្គរប្រសិនបើមាន។

ទ្រព្យសកម្មអរូបីត្រូវបានរំលស់ទៅតាមអាយុកាលប្រើប្រាស់ប៉ាន់ស្មានរយៈពេល 36ខែ ដោយប្រើវិធីសាស្ត្រនៃការរំលស់ថេរ។ ប្រសិនបើមានការកែប្រែជាសារវន្តទៅលើអត្រារំលស់ អាយុកាលប្រើប្រាស់ តម្លៃនៅសល់នៃទ្រព្យសកម្មអរូបីនោះរំលស់ត្រូវបានកំណត់ឡើងវិញដើម្បីឆ្លុះបញ្ចាំងនូវការប៉ាន់ស្មានថ្មី។

29.10 ឱនភាពនៃតម្លៃនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

នាកាលបរិច្ឆេទរាយការណ៍នីមួយៗ ធនាគារពិនិត្យតម្លៃយោងនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ ដើម្បីកំណត់សញ្ញាណនៃឱនភាពនៃតម្លៃ។ ក្នុងករណីដែលមានកត្តាទាំងនោះកើតឡើងចំនួននៃទ្រព្យសកម្ម ដែលអាចប្រមូលបានវិញនឹងត្រូវបានប៉ាន់ស្មាន។

សម្រាប់ការធ្វើតេស្តឱនភាពនៃតម្លៃ ទ្រព្យសកម្មត្រូវបានដាក់បញ្ចូលគ្នាជាក្រុម ដែលអាចបង្កើតសាច់ប្រាក់តូចបំផុតពីការបន្តការប្រើប្រាស់ ដោយមិនពឹងផ្អែកខ្លាំងលើលំហូរសាច់ប្រាក់នៃទ្រព្យសកម្មដទៃទៀត ឬក្រុមទ្រព្យសកម្មដទៃទៀត ហៅកាត់ថា (“ឯកតាបង្កើតសាច់ប្រាក់”)។

តម្លៃដែលអាចប្រមូលមកវិញបាននៃទ្រព្យសកម្ម ឬឯកតាបង្កើតសាច់ប្រាក់ គឺជាតម្លៃដែលខ្ពស់ជាងគេនៃតម្លៃប្រើប្រាស់ និងតម្លៃសមស្របដកតម្លៃដើមក្នុងការលក់ចេញតម្លៃប្រើប្រាស់ គឺអាស្រ័យលើការប៉ាន់ស្មាននូវលំហូរសាច់ប្រាក់នាពេលអនាគតអប្បហារទៅតម្លៃបច្ចុប្បន្ន ដោយប្រើប្រាស់អត្រាអប្បហារមុនដកពន្ធ ដែលឆ្លុះបញ្ចាំងពីការប៉ាន់ប្រមាណទីផ្សារបច្ចុប្បន្ននៃតម្លៃពេលវេលា និងហានិភ័យជាក់លាក់ សម្រាប់ទ្រព្យសកម្មទាំងនោះ ឬឯកតាបង្កើតសាច់ប្រាក់។

ការខាតបង់លើឱនភាពនៃតម្លៃ ត្រូវបានទទួលស្គាល់ប្រសិនបើតម្លៃយោងមានចំនួនលើសពីតម្លៃ ដែលអាចប្រមូលបានវិញនៃឯកតាបង្កើតសាច់ប្រាក់។

29.11 កម្ចី និងប្រាក់បញ្ញើពីអតិថិជន

ប្រាក់កម្ចី និងប្រាក់បញ្ញើពីអតិថិជន ត្រូវបានវាស់វែងដំបូងតាមតម្លៃសមស្រប ដកថ្លៃដើមប្រតិបត្តិការបន្ថែមដោយផ្ទាល់ និងវាស់វែង បន្ទាប់តាមរំលស់ថ្លៃដើម ដោយប្រើប្រាស់វិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។

ប្រាក់កម្ចីត្រូវបានចាត់ទុកជាបំណុលរយៈពេលខ្លី លើកលែងតែធនាគារមានសិទ្ធិគ្មានលក្ខខណ្ឌក្នុងការពន្យាពេលនៃការទូទាត់បំណុលយ៉ាងតិច 12 ខែបន្ទាប់ពីការិយបរិច្ឆេទរាយការណ៍។

29.12 សំវិធានធន

សំវិធានធនត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នៅពេលដែលធនាគារមានកាតព្វកិច្ចតាមផ្លូវច្បាប់ ឬកាតព្វកិច្ចប្រយោលនាពេលបច្ចុប្បន្ន ដែលជាលទ្ធផលនៃព្រឹត្តិការណ៍កន្លងផុតទៅ ហើយវាមានលទ្ធភាពដែលតម្រូវឱ្យមានលំហូរចេញនូវអត្ថប្រយោជន៍សេដ្ឋកិច្ច ក្នុងការបំពេញនូវកាតព្វកិច្ចនោះ ហើយនឹងចំនួនដែលត្រូវបានគេប៉ាន់ប្រមាណដោយភាពជឿជាក់។ សំវិធានធនត្រូវបានវាស់វែងតាមតម្លៃទីផ្សារបច្ចុប្បន្ននៃចំណាយដែលរំពឹងថានឹងត្រូវទូទាត់នាពេលអនាគត ដើម្បីបំពេញកាតព្វកិច្ចដោយប្រើអត្រាមុនបង់ពន្ធដែលឆ្លុះបញ្ចាំងពីការប៉ាន់ស្មាននៃតម្លៃពេលវេលា ក្នុងលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន និងហានិភ័យជាក់លាក់ចំពោះបំណុលទាំងនោះ។ ការកើនឡើងសំវិធានធនដោយសាររយៈពេល គឺត្រូវបានទទួលស្គាល់ជាថ្លៃដើមហិរញ្ញប្បទាន។

29.13 អត្ថប្រយោជន៍របស់និយោជិត

(ក) អត្ថប្រយោជន៍របស់និយោជិតរយៈពេលខ្លី

អត្ថប្រយោជន៍និយោជិតរយៈពេលខ្លី ត្រូវបានចាត់ទុកជាចំណាយនៅពេលនិយោជិតផ្តល់សេវាកម្មពាក់ព័ន្ធ។ បំណុល ត្រូវបានទទួលស្គាល់លើចំនួនដែលរំពឹងថានឹងត្រូវទូទាត់ ប្រសិនបើធនាគារមានកាតព្វកិច្ចផ្លូវច្បាប់ ឬប្រយោលក្នុងការទូទាត់ចំនួននេះ ដែលជាលទ្ធផលនៃសេវាកម្មដែលបានផ្តល់រួចដោយនិយោជិត ហើយកាតព្វកិច្ចទូទាត់អាចប៉ាន់ស្មានដោយភាពជឿជាក់។

(ខ) អត្ថប្រយោជន៍និយោជិតរយៈពេលវែងផ្សេងៗ

កាតព្វកិច្ចទូទាត់សុទ្ធរបស់ធនាគារទៅលើអត្ថប្រយោជន៍រយៈពេលវែងរបស់និយោជិត គឺជាចំនួនទឹកប្រាក់នៃអត្ថប្រយោជន៍ដែលនិយោជិតទទួលបានពីការផ្តល់សេវាកម្មរបស់ខ្លួនក្នុងអំឡុងពេលបច្ចុប្បន្ន និងអតីតកាល។ អត្ថប្រយោជន៍នេះ ត្រូវបានធ្វើអប្បហាដើម្បីកំណត់តម្លៃបច្ចុប្បន្ន។ ការវាស់វែងឡើងវិញត្រូវបានទទួលស្គាល់ក្នុង ចំណេញ ឬខាតក្នុងអំឡុងពេលដែលបានកើតឡើង។

29.14 ចំណូលការប្រាក់ និងចំណាយការប្រាក់

ចំណូលការប្រាក់ និងចំណាយការប្រាក់ត្រូវបានទទួលស្គាល់នៅក្នុងចំណេញ ឬខាត ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។ “អត្រាការប្រាក់ប្រសិទ្ធភាព” គឺជាអត្រាដែលអាចធ្វើអប្បហារសាច់ប្រាក់ដែលរំពឹងថានឹងទូទាត់ ឬនឹងត្រូវទទួល តាមរយៈអាយុកាលរំពឹងទុករបស់ឧបករណ៍ហិរញ្ញវត្ថុនោះ ឱ្យមកស្មើនឹង៖

- តម្លៃយោងដុលរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬ
- រំលស់តម្លៃដើមរបស់បំណុលហិរញ្ញវត្ថុ។

ការគណនាអត្រាការប្រាក់ប្រសិទ្ធភាព រួមបញ្ចូលនូវថ្លៃដើមប្រតិបត្តិការ និងកម្រៃទាំងអស់ដែលបានបង់ ឬទទួល ដែលជាផ្នែកនៃអត្រាការប្រាក់ប្រសិទ្ធភាព។ ថ្លៃដើមប្រតិបត្តិការរួមមាន ការចំណាយបន្ថែមដែលពាក់ព័ន្ធផ្ទាល់ទៅនឹងការទិញ ឬការបោះផ្សាយទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ។

អត្រាការប្រាក់ប្រសិទ្ធភាពរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ត្រូវបានគណនានៅពេលទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុជាលើកដំបូង។ ក្នុងការគណនាចំណូលការប្រាក់ និងចំណាយការប្រាក់ អត្រាការប្រាក់ប្រសិទ្ធភាពត្រូវបានប្រើផ្អែកលើតម្លៃយោងដុលរបស់ទ្រព្យសកម្ម (នៅពេលដែលទ្រព្យសកម្មមិនត្រូវបានចាត់ទុកថាមានឱនភាពនៃតម្លៃ) ឬរំលស់ថ្លៃដើមនៃបំណុល។ អត្រាការប្រាក់ប្រសិទ្ធភាពត្រូវធ្វើការកែប្រែឡើងវិញ ដោយការប៉ាន់ស្មានឡើងវិញនូវលំហូរទឹកប្រាក់របស់ឧបករណ៍ហិរញ្ញវត្ថុដែលមានអត្រាការប្រាក់ប្រែប្រួលដើម្បី ឆ្លុះបញ្ចាំងពីការផ្លាស់ប្តូររបស់អត្រាការប្រាក់ទីផ្សារ។

ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពនៃតម្លៃ បន្ទាប់ពីបានទទួលស្គាល់ជាលើកដំបូង ចំណូលការប្រាក់ត្រូវបានគណនាដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាព ផ្អែកលើរំលស់ថ្លៃដើមរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ។ ប្រសិនបើទ្រព្យសកម្មហិរញ្ញវត្ថុលែងមានឱនភាពនៃតម្លៃ នោះការគណនាការប្រាក់ត្រូវផ្អែកលើមូលដ្ឋានតម្លៃដុលវិញ។

ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពនៃតម្លៃ ចាប់តាំងពីទទួលស្គាល់ជាលើកដំបូង ចំណូលការប្រាក់ត្រូវបានគណនាដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាពដែលត្រូវបានកែតម្រូវនូវហានិភ័យ ផ្អែកលើរំលស់ថ្លៃដើមនៃទ្រព្យសកម្មហិរញ្ញវត្ថុនោះ។ ការគណនាចំណូលការប្រាក់នេះ មិនត្រូវប្តូរទៅមូលដ្ឋានតម្លៃដុលវិញនោះទេ ទោះបីជាហានិភ័យឥណទានរបស់ទ្រព្យសកម្មនោះ មានភាពប្រសើរក៏ដោយ។

29.15 កម្រៃ និងជើងសារ

ចំណូល និងចំណាយកម្រៃ និងជើងសារ ដែលជាផ្នែកនៃអត្រាការប្រាក់ប្រសិទ្ធភាព របស់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ត្រូវបានរួមបញ្ចូលទៅក្នុងអត្រាការប្រាក់ប្រសិទ្ធភាព។

ចំណូលកម្រៃ និងជើងសារផ្សេងទៀត រួមបញ្ចូលទាំងថ្លៃសេវាកម្មត្រូវបានទទួលស្គាល់នៅពេលបានបំពេញសេវាកម្ម។

29.16 ភតិសន្យា

ធនាគារវាយតម្លៃថាតើកិច្ចសន្យាមាន ឬមានភតិសន្យាជួលនៅពេលចាប់ផ្តើមកិច្ចសន្យា។ ធនាគារទទួលស្គាល់សិទ្ធិប្រើប្រាស់ទ្រព្យ និងបំណុលភតិសន្យាដែលត្រូវគ្នានឹងកិច្ចព្រមព្រៀងភតិសន្យាទាំងអស់ដែលខ្លួនជាអ្នកជួលលើកលែងតែភតិសន្យារយៈពេលខ្លី (កំណត់ថាជាកិច្ចសន្យាភតិសន្យាដែលមានរយៈពេលជួល12ខែ ឬតិចជាងនេះ) និងការជួលទ្រព្យក្នុងតម្លៃទាប។ ចំពោះកិច្ចសន្យាភតិសន្យាទាំងនេះ ធនាគារនឹងទទួលស្គាល់ការទូទាត់ភតិសន្យា ជាចំណាយប្រតិបត្តិការដោយឈរលើមូលដ្ឋានថេរលើលក្ខខណ្ឌនៃភតិសន្យា លើកលែងតែមិនមានមូលដ្ឋានជាប្រព័ន្ធផ្សេងទៀតតំណាងឱ្យពេលវេលាដែលផលប្រយោជន៍សេដ្ឋកិច្ចពីទ្រព្យសកម្មភតិសន្យា ត្រូវបានប្រើប្រាស់។

បំណុលភតិសន្យា ត្រូវបានវាស់ដំបូងតាមតម្លៃបច្ចុប្បន្ននៃការជួលដែលមិនត្រូវបានបង់នៅកាលបរិច្ឆេទចាប់ផ្តើមដោយត្រូវបញ្ចុះដោយប្រើអត្រាការប្រាក់ជាក់ស្តែងនៅក្នុងភតិសន្យា។ ប្រសិនបើអត្រានេះមិនអាចកំណត់បាន ធនាគារនឹងប្រើប្រាស់អត្រាប្រាក់កម្ចីបន្ថែមរបស់ខ្លួន។

បំណុលភតិសន្យា ត្រូវបានបង្ហាញនៅជួរដាច់ដោយឡែកនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

បំណុលភតិសន្យា ត្រូវបានវាស់ជាបន្តបន្ទាប់ដោយការបង្កើនតម្លៃយោង ដែលឆ្លុះបញ្ចាំងពីការប្រាក់លើបំណុល ភតិសន្យា (ដោយប្រើអត្រា ការប្រាក់ប្រសិទ្ធភាព) និងដោយកាត់បន្ថយតម្លៃយោងដែលត្រូវយកមកឆ្លុះបញ្ចាំងពី ការទូទាត់ភតិសន្យា។

សិទ្ធិប្រើប្រាស់ទ្រព្យរួមមានការវាស់វែងដំបូងនៃបំណុលភតិសន្យា ការទូទាត់ការភតិសន្យាដែលធ្វើឡើងមុន ឬនៅពេលចាប់ផ្តើម និងនៅថ្លៃដើមដំបូងណាមួយ។ បន្ទាប់មកពួកវាត្រូវបានវាស់វែងដោយយកតម្លៃដើមដករំលស់បង្គរ និងការខាតបង់លើឱនភាព។

នៅពេលណាដែលធនាគារមានកាតព្វកិច្ចចំពោះតម្លៃដើមក្នុងការរំលាយ និងដកហូតទ្រព្យសកម្មភតិសន្យាជួសជុល ទីតាំងដែលវាមានទីតាំង ឬស្តារឡើងវិញនូវទ្រព្យសកម្មមូលដ្ឋានទៅនឹងលក្ខខណ្ឌដែលតម្រូវដោយលក្ខខណ្ឌនៃភតិសន្យា សំវិធានធនត្រូវបានទទួលស្គាល់និងវាស់វែងក្រោម CIAS 37។ ការចំណាយត្រូវបានរាប់បញ្ចូលសិទ្ធិប្រើប្រាស់ទ្រព្យសកម្ម លើកលែងតែការចំណាយទាំងនោះត្រូវបានកើតឡើងក្នុងការផលិតសន្និធិ។

សិទ្ធិប្រើប្រាស់ទ្រព្យសកម្មត្រូវបានរំលស់ក្នុងរយៈពេលខ្លីជាងរយៈពេលជួល និងអាយុកាលប្រើប្រាស់របស់ទ្រព្យមូលដ្ឋាន។ ប្រសិនបើភតិសន្យាផ្ទេរកម្មសិទ្ធិនៃទ្រព្យមូលដ្ឋាន ឬថ្លៃដើមនៃសិទ្ធិប្រើប្រាស់ទ្រព្យនោះវានឹងឆ្លុះបញ្ចាំងថា ធនាគាររំពឹងថានឹងប្រើជម្រើសទិញទ្រព្យសកម្មសិទ្ធិប្រើប្រាស់ទ្រព្យត្រូវបានរំលស់លើអាយុកាលប្រើប្រាស់នៃទ្រព្យមូលដ្ឋាន។ រំលស់ចាប់ផ្តើមពីកាលបរិច្ឆេទចាប់ផ្តើមនៃការជួល។

ការប៉ាន់ស្មានអាយុកាលប្រើប្រាស់សម្រាប់អំឡុងការិយបរិច្ឆេទបច្ចុប្បន្ន មានដូចខាងក្រោម៖

- អគារ និងសាខាការិយាល័យ 10 ឆ្នាំ និង 5 ឆ្នាំ រៀងគ្នា។

សិទ្ធិប្រើប្រាស់ទ្រព្យសកម្មត្រូវបានបង្ហាញមួយបន្ទាត់ដាច់ដោយឡែកក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

29.17 ពន្ធលើប្រាក់ចំណេញ

ពន្ធលើប្រាក់ចំណេញរួមមានពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ និងពន្ធពន្យារ។ ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ និង ពន្ធពន្យារត្រូវបានទទួលស្គាល់ជាចំណេញ ឬខាតនៅក្នុងរបាយការណ៍លទ្ធផលលម្អិត លើកលែងតែក្នុងករណីដែលវាទាក់ទងទៅនឹងការរួមបញ្ចូលគ្នានៃអាជីវកម្ម ឬធាតុណាដែលបានទទួលស្គាល់ក្នុងរបាយការណ៍លទ្ធផលលម្អិតផ្សេងទៀត។

ធនាគារបានកំណត់ថាការប្រាក់ និងដាក់ទណ្ឌកម្មដែលទាក់ទងនឹងពន្ធលើប្រាក់ចំណេញរួមមាន ភាពមានមន្ទិលទៅលើការទទួលស្គាល់ពន្ធ មិនគ្រប់និយមន័យរបស់ពន្ធលើប្រាក់ចំណេញ នឹងត្រូវបានទទួលស្គាល់ក្រោម CIAS 37 សំវិធានធន បំណុលយថាហេតុ និងទ្រព្យសកម្មយថាហេតុ។

ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ គឺជាពន្ធដែលរំពឹងថាត្រូវបង់ទៅលើប្រាក់ចំណេញជាប់ពន្ធប្រចាំឆ្នាំដោយប្រើអត្រាពន្ធដែលបានអនុម័ត ឬបានអនុម័តជាអាទិ៍នៅកាលបរិច្ឆេទនៃការរាយការណ៍ និងនិយ័តភាពទាំងឡាយទៅលើពន្ធត្រូវបង់ពីឆ្នាំមុនៗ។

ពន្ធពន្យារត្រូវបានកំណត់ទៅលើភាពលម្អៀងរវាងតម្លៃយោងនៃទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ និងតម្លៃយោងសម្រាប់ការគិតពន្ធ (ហៅថាភាពលម្អៀងបណ្ដោះអាសន្ន)។ ពន្ធពន្យារដែលជាបំណុលត្រូវទទួលស្គាល់លើភាពលម្អៀងបណ្ដោះអាសន្នដែលរំពឹងថានឹងបង្កើនប្រាក់ចំណេញ ដែលជាប់ពន្ធនាពេលអនាគត។ ពន្ធពន្យារជាទ្រព្យសកម្មត្រូវបានទទួលស្គាល់សម្រាប់ភាពលម្អៀងបណ្ដោះអាសន្នទាំងឡាយណាដែលរំពឹងថានឹងកាត់បន្ថយប្រាក់ចំណេញជាប់ពន្ធនាពេលអនាគតរួមទាំងការខាតពន្ធ ឬឥណទានពន្ធដែលមិនទាន់បានប្រើប្រាស់ផ្សេងៗ។ ពន្ធពន្យារជាទ្រព្យសកម្មត្រូវបានទទួលស្គាល់តាមចំនួនដែលគិតថាអាចប្រើប្រាស់បានខ្ពស់បំផុតដោយផ្អែកលើមូលដ្ឋានប្រាក់ចំណេញជាប់ពន្ធនាពេលបច្ចុប្បន្ន ឬនាពេលអនាគតហើយមានលទ្ធភាពខ្ពស់ក្នុងការអាចយកមកប្រើប្រាស់បាន។

តម្លៃយោងសុទ្ធនៃពន្ធពន្យារជាទ្រព្យសកម្មត្រូវបានត្រួតពិនិត្យឡើងវិញនៅរៀងរាល់ កាលបរិច្ឆេទរាយការណ៍ និងត្រូវបានធ្វើនិយ័តភាពដើម្បីឆ្លុះបញ្ចាំងពីការវាយតម្លៃប្រាក់ចំណេញជាប់ពន្ធនាពេលអនាគត។ និយ័តភាពទាំងនោះត្រូវបានទទួលស្គាល់ជាចំណេញ ឬខាតនៅក្នុងរបាយការណ៍លទ្ធផលលម្អិត លើកលែងតែនិយ័តភាពដែលពាក់ព័ន្ធនឹងខ្ទង់ចំណូល ឬចំណាយដែលត្រូវទទួលស្គាល់ក្នុងរបាយការណ៍លទ្ធផលលម្អិតផ្សេងៗ ដោយនិយ័តភាពនោះត្រូវតែទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលលម្អិតផ្សេងៗ។

ពន្ធពន្យារ ត្រូវបានគណនាតាមអត្រាពន្ធដែលប្រើសម្រាប់ការគណនាប្រាក់ចំណេញជាប់ពន្ធ (ការខាតពន្ធ) ក្នុងការិយបរិច្ឆេទដែលពន្ធពន្យារជាទ្រព្យសកម្មរំពឹងថានឹងប្រើប្រាស់បាន ឬបំណុលជាពន្ធពន្យាររំពឹងថានឹង ត្រូវទូទាត់ដោយប្រើអត្រាពន្ធដែលបានអនុម័ត ឬបានកំណត់ជាអាទិ៍សម្រាប់កាលបរិច្ឆេទរាយការណ៍។

29.18 សម្ព័ន្ធញាតិ

សហគ្រាស និងបុគ្គលដែលទាក់ទងផ្ទាល់ ឬមិនផ្ទាល់តាមរយៈអន្តរការីមួយឬច្រើន ឬត្រូវបានគ្រប់គ្រង ក្រោមការគ្រប់គ្រងរួមជាមួយធនាគារ រួមទាំងក្រុមហ៊ុនមេ បុត្រសម្ព័ន្ធ និងក្រុមហ៊ុនសម្ព័ន្ធផ្សេងទៀតដែលជាភាគី ពាក់ព័ន្ធរបស់ធនាគារ។ ក្រុមហ៊ុនសមាគត និងបុគ្គលដែលកាន់កាប់ដោយផ្ទាល់ ឬប្រយោលលើសិទ្ធបោះឆ្នោតរបស់ធនាគារ ដែលផ្តល់ឱ្យពួកគេមានឥទ្ធិពលយ៉ាងសំខាន់មកលើសហគ្រាស គណៈគ្រប់គ្រងសំខាន់ៗរួមមាននាយក និងបុគ្គលិកធនាគារ និងសមាជិកជិតស្និទ្ធជាមួយក្រុមគ្រួសាររបស់បុគ្គលនោះ ក៏ដូចជាក្រុមហ៊ុនដែលសហការជាមួយបុគ្គលទាំងនេះ ត្រូវបានចាត់ទុកជាភាគីពាក់ព័ន្ធផងដែរ។

ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក

អគារលេខ ៤៦២ មហាវិថីព្រះមុនីវង្ស
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

023 901 338

www.bicbank.com.kh